Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

# បច្ចុប្បន្នភាព សេដ្ឋកិច្ច កម្ពុជា

## រក្សា ភាពប្រកួតប្រជែង តាមរយៈ ការបង្កើន ផលិតភាព

ខែមេសា ឆ្នាំ២០១៧



ប្រធានបទជម្រើស:

**ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ**

ក្រុមធនាគារពិភពលោក

# បច្ចុប្បន្នភាព
# សេដ្ឋកិច្ចកម្ពុជា

## រក្សាភាពប្រកួតប្រជែង
## តាមរយៈការបង្កើនផលិតភាព

ខែមេសា ឆ្នាំ២០១៧

ប្រធានបទជម្រើស:

**ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ**

# អារម្ភកថា និងសេចក្តីថ្លែងអំណរគុណ

របាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា (CEU) គឺជាផលិតផលរបស់បុគ្គលិករបស់ធនាគារពិភពលោក។ របាយការណ៍នេះត្រូវបានរៀបចំដោយលោក **លី សូដេត** និងរួមចំណែកដោយលោក **មីហ្គែល អេឌូអាដូ សាន់ឆេស ម៉ាទីន (Miguel Eduardo Sánchez Martín)** ទាំងផ្នែកម៉ាក្រូសេដ្ឋកិច្ច និងផ្នែកអនុវត្តសាកលនៃការគ្រប់គ្រងសារពើពន្ធ (MFM GP) ។ កញ្ញា **គី លីនណា** ជាជំនួយការស្រាវជ្រាវ ចំណែកឯលោក **ភឹម រុនស៊ីណារិទ្ធិ** ជាកុងស៊ុលតង់ STC បានផ្តល់មតិ ធាតុចូល និងយោបល់ចំពោះប្រធានបទជំពីស។ ផ្នែកស្តីពីការគ្រប់គ្រងវិនិយោគសាធារណៈដែលជាផ្នែកមួយនៃប្រធានបទជំពីស ក្រោមចំណងជើងថា "ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ" ត្រូវបានរួមចំណែកដោយ **ទួន មិញឡេ (Tuan Minh Le)** ម៉ាក្រូសេដ្ឋកិច្ច និងគ្រប់គ្រងសារពើពន្ធផ្នែកអនុវត្តសាកល និង **ជេ យុងគីម (Jay Hyung Kim)** (GP អភិបាលកិច្ច)។ ក្រុមការងារនេះធ្វើការក្រោមការដឹកនាំរបស់លោក **ម៉ាធូ អា ជីហ្គីស (Mathew A. Verghis)** ប្រធានគ្រប់គ្រងការអនុវត្តន៍ម៉ាក្រូ សេដ្ឋកិច្ច និងគ្រប់គ្រងសារពើពន្ធផ្នែកអនុវត្តសាកល។ ក្រុមការងារសូមថ្លែងអំណរគុណចំពោះ មតិយោបល់ ដំបូន្មាន និងការណែនាំដែលផ្តល់ដោយលោក **អ៊ុលរិច ហ្សាកឆាវ (Ulrich Zachau)** នាយកប្រចាំកម្ពុជា លោក **អ៊ីងហ្គូណា ដូប្រាចា (Inguna Dobraja)** ប្រធានគ្រប់គ្រងប្រចាំកម្ពុជា និង **ស្ហាប៊ី អាលី ម៉ូហ៊ីប (Shabih Ali Mohib)** ប្រធានកម្មវិធី។

របាយការណ៍នេះត្រូវបានផលិតរៀងរាល់ឆមាស ដើម្បីផ្តល់ព័ត៌មានថ្មីៗអំពីការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា។ របាយការណ៍នេះត្រូវបានបោះពុម្ព និងចែកចាយទូលំទូលាយទៅដល់អាជ្ញាធរកម្ពុជា សហគមន៍ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ក្រុមអ្នកស្រាវជ្រាវ អង្គការសង្គមស៊ីវិល និងសកលវិទ្យាល័យ។ បច្ចុប្បន្នភាពនេះត្រូវបានកំណត់ពេលឲ្យត្រូវគ្នាជាមួយការបោះពុម្ពផ្សាយរៀងរាល់ប្រាំមួយខែម្តងនូវបច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីខាងកើត និងប៉ាស៊ីហ្វិក ដោយក្រុមម៉ាក្រូសេដ្ឋកិច្ច និងគ្រប់គ្រងសារពើពន្ធនៃធនាគារពិភពលោក។

យើងទទួលបានធាតុចូល គំនិត និងមតិយោបល់ និងដ៏មានតម្លៃពី **នីកូឡា អិល ស្ប៉ាតាហ្វ៉ា (Nikola L. Spatafora)** ប្រធានផ្នែកសេដ្ឋកិច្ចអាស៊ីខាងកើត និងតំបន់ប៉ាស៊ីហ្វិក និង **ខល់លីន ម៉ាសឺនិក (Colleen Mascenik)** អ្នកឯកទេសហិរញ្ញវត្ថុ និងទីផ្សារផ្នែកអនុវត្តសាកល។ ផ្នែកស្តីពីភាពក្រីក្រ ត្រូវបានរួមចំណែកដោយ លោក **គុង គីមស៊ុន** អ្នកឯកទេសភាពក្រីក្រ។ របាយការណ៍នេះក៏បានទទួលដំបូន្មាន មតិយោបល់ និងទស្សនៈរបស់ភាគីពាក់ព័ន្ធនានាក្នុងរាជរដ្ឋាភិបាលកម្ពុជា វិស័យឯកជន ស្ថាប័នដៃគូអភិវឌ្ឍន៍ និងស្ថាប័នសិក្សាស្រាវជ្រាវផងដែរ។ ក្រុមរៀបរៀងរបាយការណ៍នេះ សូមថ្លែងអំណរគុណជាពន្លឹកចំពោះពេលវេលា និងធាតុចូលរបស់អ្នកទាំងនោះ។

យើងខ្ញុំសូមថ្លែងនូវសេចក្តីដឹងគុណដ៏ជ្រាលជ្រៅចំពោះអាជ្ញាធរកម្ពុជា ពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជាចំពោះកិច្ចសហប្រតិបត្តិការ និងការគាំទ្រក្នុងការរៀបចំរបាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជានេះ។

ក្រុមទំនាក់ទំនង នៃការិយាល័យធនាគារពិភពលោកនៅកម្ពុជា រួមមាន លោក **ប៊ូ សារឿន** និង**សំអឿន សុភីនិត** បានរៀបចំការផ្តល់ព័ត៌មានដល់ប្រព័ន្ធផ្សព្វផ្សាយ ការបង្ហាញលើបណ្តាញអ៊ីនធើនែត និងការផ្សព្វផ្សាយ។

ចំពោះព័ត៌មានអំពីធនាគារពិភពលោក និងសកម្មភាពរបស់ធនាគារនេះនៅកម្ពុជា សូមចូលមើលគេហទំព័ររបស់យើងតាមអាស័យដ្ឋាន www.worldbank.org/cambodia។

ដើម្បីឲ្យមានឈ្មោះនៅក្នុងបញ្ជីចែកចាយ តាមសារអេឡិកត្រូនិក នូវរបាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជានេះ និងឯកសារបោះពុម្ពផ្សាយពាក់ព័ន្ធ សូមទាក់ទង កញ្ញា គី **លីនណា** (lky@worldbank.org) ។ ចំពោះសំណួរអំពីខ្លឹមសារនៃការបោះពុម្ពផ្សាយនេះ សូមទាក់ទង លោក **ប៊ូ សារឿន** (sbou@worldbank.org) ។

# មាតិកា


**អារម្ភកថា និងសេចក្តីថ្លែងអំណរគុណ....4**

**A. ខ្លឹមសារសង្ខេប....7**

**B. ស្ថានភាពអភិវឌ្ឍសេដ្ឋកិច្ចថ្មីៗ....13**

វិស័យពិត....13

*a) វិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង....13*

*b) សំណង់និងអចលនទ្រព្យ....15*

*c) វិស័យទេសចរណ៍....16*

*d) វិស័យកសិកម្ម....18*

ភាពក្រីក្រ....19

វិស័យពាណិជ្ជកម្មក្រៅប្រទេស....20

*a) ការនាំចេញទំនិញ....20*

*b) ចំណូលពីការបង្វែរប្រាក់របស់កម្មករ....21*

*c) ការនាំចូលទំនិញ....21*

*d) គណនីចរន្ត....22*

អតិផរណា....22

វិស័យរូបិយវត្ថុ....23

*a) រូបិយវត្ថុសរុប អត្រាការប្រាក់ និងអត្រាប្តូរប្រាក់....23*

*b) វិស័យធនាគារ....25*

*c) មីក្រូហិរញ្ញវត្ថុ....26*

*d) ភាពជំពាក់បំណុល....27*

វិស័យសារពើពន្ធ....29

*a) ចំណូលក្នុងស្រុក....29*

*b) ចំណាយសាធារណៈ....30*

*c) តុល្យភាពសារពើពន្ធ....31*

*d) ថវិកាឆ្នាំ 2017....31*

**C. ទស្សនវិស័យ និងហានិភ័យ....33**

**D. សារនិងជម្រើសគោលនយោបាយសំខាន់ៗ....36**

**E. ប្រធានបទជម្រើស: ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ....39**

ការលើកទឹកចិត្ត....39

និន្នាការនៃចំណាយសាធារណៈ....40

ការចំណាយ និងប្រសិទ្ធភាពនៃការវិភាជន៍ជាមួយការប្រៀបធៀបក្នុងតំបន់....41

ការគ្រប់គ្រងវិនិយោគសាធារណៈ....44

*a) មុខងារនៃវិនិយោគមូលធន....44*

*b) កិច្ចប្រតិបត្តិអំពីការគ្រប់គ្រងវិនិយោគសាធារណៈបច្ចុប្បន្នរបស់កម្ពុជា....44*

*c) វិធានការកែលម្អការគ្រប់គ្រងវិនិយោគសាធារណៈ....45*

សន្និដ្ឋាន....46

**F. កម្ពុជា: សូចនាករសំខាន់ៗ....47**




ROYAL RAILWAY




# A. ខ្លឹមសារសង្ខេប

*សេដ្ឋកិច្ចកម្ពុជានៅតែមានសភាពរឹងមាំធៀប មានកំណើនស្មើនឹង 6,9 ភាគរយ នៅឆ្នាំ 2016 បន្ទាប់ពីកំណើន 7 ភាគរយ នៅឆ្នាំ 2015 កន្លងទៅ។ សកម្មភាពសេដ្ឋកិច្ចកម្ពុជាបន្តកើនឡើងក្នុងកំរិតខ្លាំងក្លា។ សំណង់នៅតែជាកត្តាមួយក្នុងចំណោមកត្តាចម្បងនានាដែលជំរុញឲ្យមានកំណើន។ ការនាំចេញសម្លៀកបំពាក់បានថយចុះបន្តិច ដោយសារភាពប្រកួតប្រជែងនៅក្រៅប្រទេសរបស់កម្ពុជាបានធ្លាក់ចុះ បណ្តាលមកការកើនឡើងនៃប្រាក់ដុល្លារអាមេរិក ការឡើងនៃកម្រៃពលកម្ម និងកំណើននៃការប្រកួតប្រជែងពីបណ្តាប្រទេសក្នុងតំបន់ ដែលមានឈ្នួលពលកម្មទាប។ ស្ថានភាពល្អប្រសើរនៃធាតុអាកាសនាឆ្នាំកន្លងទៅ បានធ្វើឲ្យមានកំណើនផលិតកម្មកសិកម្ម ទោះជាថ្លៃទំនិញកសិកម្មនៅតែមានតម្លៃថោកក្តី។ កំណើនពិតត្រូវបានព្យាករថានឹងនៅតែមានសភាពរឹងមាំកើនឡើងក្នុងអត្រា 6.9 ភាគរយ សម្រាប់ឆ្នាំ2017 និង 2018 មួយផ្នែកនៃការលូតលាស់នេះត្រូវបានទ្រទ្រង់ដោយចំណាយរដ្ឋាភិបាល។ ហានិភ័យអាក្រក់សម្រាប់ទស្សនវិស័យនេះ រួមមាន ផលអវិជ្ជមានពីការកើនឡើងបន្ថែមទៀតនៃអត្រាការប្រាក់សហរដ្ឋអាមេរិក ការងើបឡើងវិញនៃសេដ្ឋកិច្ចអឺរ៉ុបយឺតយ៉ាវជាងការរំពឹងទុក និងភាពមិនប្រាកដប្រជានៃពាណិជ្ជកម្មសាកល។ ការកាត់បន្ថយភាពក្រីក្រត្រូវបានរំពឹងថានឹងមានជាបន្តក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ ជំរុញជាចម្បងដោយវិស័យកាត់ដេរសម្លៀកបំពាក់ វិស័យសំណង់ និងវិស័យសេវាកម្ម ព្រមទាំងការកើនឡើងនៃការបង្វែរប្រាក់ពីបរទេស។*

## ការអភិវឌ្ឍថ្មីៗ

**ការប៉ាន់ស្មានជំហានដំបូងបង្ហាញថា កំណើនសេដ្ឋកិច្ចនៅមានភាពរឹងមាំ ក្នុងកម្រិត 6,9 ភាគរយ ក្នុងឆ្នាំ 2016 ធៀបនឹងកំណើន 7 ភាគរយក្នុងឆ្នាំ 2015។** កំណើន បន្តទ្រទ្រង់ដោយសកម្មភាពរឹងមាំនៃវិស័យសំណង់ ទោះជាការនាំចេញសម្លៀកបំពាក់មានការថមថយល្បឿនក្តី។ កំណើតនៃចំនួនភ្ញៀវទេសចរថយចុះបន្តិចត្រូវបានប៉ះប៉ូវដោយការកើនឡើងនៃវិស័យកសិកម្ម ពិសេសគឺផលិតកម្មស្រូវ ដោយសារធាតុអាកាសអំណោយនាឆ្នាំកន្លង ទោះជាថ្លៃទំនិញកសិកម្មនៅតែមានកម្រិតទាបក្តី។

**ខណៈនៅតែមានកំណើនខ្ពស់កំណើនការនាំចេញសម្លៀកបំពាក់ប្រចាំឆ្នាំ បានថមថយចុះមកត្រឹម 8.4 ភាគរយក្នុងឆ្នាំ 2016 (ជាទឹកប្រាក់) ពី 12.3 ភាគរយ ក្នុងឆ្នាំ 2015 ។** ការឡើងថ្លៃឈ្នួលពលកម្ម ដែលបណ្តាលមួយផ្នែកមកពីការឡើងថ្លៃជីវភាពរស់នៅ ការឡើងថ្លៃប្រាក់ដុល្លារអាមេរិក និងការប្រកួតប្រជែងពីបណ្តាប្រទេសក្នុងតំបន់ដែលមានប្រាក់កម្រៃពលកម្មទាប ជាពិសេសប្រទេសភូមា នៅតែបន្តដាក់សម្ពាធធ្លាក់ចុះមកលើថ្លៃនៃផលិតផលសម្លៀកបំពាក់នាំចេញ។ ខណៈដែលដំណាក់កាលបញ្ចប់នៃគម្រោងសំណង់លំនៅដ្ឋាន និងគម្រោងសំណង់ពាណិជ្ជកម្មទំនើបខ្ពស់ៗជាច្រើនដែលបាន

ជម្រុញសន្ទុះរីកចម្រើន កំពុងឈានចូលមកដល់ ការនាំចូលសម្ភារៈសំណង់ជាមូលដ្ឋានបានថមថយចុះ។ កំណើននាំចូលដែកសំណង់ (គិតជាបរិមាណ) បានថយចុះពី 32.8 ភាគរយនៅឆ្នាំ 2015 មកត្រឹម 28 ភាគរយនៅឆ្នាំ 2016។

**ផលិតកម្មកសិកម្មបានប្រសើរឡើង មួយផ្នែកធំបណ្តាលមកពីធាតុអាកាសល្អប្រសើរ ក្រោយពេលដែលប្រទេស កម្ពុជាបានជួបប្រទះគ្រោះរាំងស្ងួតធ្ងន់ធ្ងរអស់រយៈច្រើនឆ្នាំ។** ផលិតកម្មស្រូវវស្សាបានកើនឡើងដល់ 7.3 លានតោន នៅឆ្នាំ 2016 ឬបានកើនឡើង 8.9 ភាគរយ ពីឆ្នាំ 2015។ ទោះជាយ៉ាងនេះក្តី ថ្លៃទំនិញកសិកម្មនៅតែទាប ធ្វើឲ្យកំណើននាំចេញសរុបនៃវិស័យកសិកម្មមានកម្រិត។ សកម្មភាពទេសចរណ៍បានថមថយបន្តិច ដោយកំណើនភ្ញៀវទេសចរបរទេសបានធ្លាក់មកត្រឹម 5.0 ភាគរយ ក្នុងឆ្នាំ 2016 ធៀបនឹង 6.1 ភាគរយ ក្នុងឆ្នាំ2015។មកដល់ពេលនេះ ជោគជ័យក្នុងការធ្វើពិពិធកម្មមណ្ឌលទេសចរលើសពីប្រាសាទអង្គរមានកម្រិតតិចតួចប៉ុណ្ណោះ។

**គ្រួសារជនបទបានបង្កើនការធ្វើពិពិធកម្ម លើរបរចិញ្ចឹមជីវិតដោយទាញប្រយោជន៍ពីរបរសេដ្ឋកិច្ចមិនមែនកសិកម្មនៅជនបទ និងប្រាក់បង្វែរ(មកផ្ទះ) ដើម្បីជួយទ្រទ្រង់កាត់បន្ថយភាពក្រីក្រ។** ការធ្លាក់ថ្លៃកសិផល គួបផ្សំជាមួយនឹងព្រឹត្តិការណ៍អាកាសធាតុអាក្រក់ខ្លាំងក្នុងឆ្នាំ 2013 និង 2015 ធ្វើឲ្យផលស វិស័យកសិកម្មធ្លាក់ចុះ និងនៅទ្រឹងកាលពីប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ។ នៅឆ្នាំ 2015 ចំណូលប្រាក់កម្រៃពីវិស័យមិនមែនកសិកម្ម មានចំនួនច្រើនជាងមួយភាគបីនៃចំណូលជនបទ ធៀបនឹងចំនួនតិចជាងមួយភាគប្រាំក្នុងឆ្នាំ 2007។ ក្នុងរយៈពេលដូចគ្នា ចំណូល វិស័យកសិកម្ម រាប់ទាំងប្រាក់ឈ្នួលកសិកម្ម បានធ្លាក់ចុះពី 63 ភាគរយ មកត្រឹម 43 ភាគរយ នៃចំណូលជនបទសរុប។

**ស្ថានភាពពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជាបានប្រសើរឡើងដោយសារការនាំចេញនៅតែរឹងមាំ និងដោយសារប្រេងឥន្ធនៈធ្លាក់ថ្លៃ។** ឱនភាពគណនីចរន្ត (មិនគិតប្រាក់បង្វែរផ្លូវការ) ត្រូវបានប៉ាន់ស្មានថាបានថយចុះពី 10.6 ភាគរយ នៅឆ្នាំ 2015 មកត្រឹម 9.5 ភាគរយ នៃ ផផស នៅឆ្នាំ 2016 ហើយត្រូវបានហិរញ្ញប្បទានដោយលំហូរវិនិយោគផ្ទាល់ពីបរទេស ដែលបានកើនឡើងពី 9.1 ភាគរយក្នុងឆ្នាំ 2015 ដល់ 10.2 ភាគរយ នៅឆ្នាំ 2016។ ជាលទ្ធផលរូបិយបណ្ណបម្រុងបរទេសដុលបានកើនឡើងបន្ថែមទៀត រហូតដល់ 6.4 ពាន់លានដុល្លារ (ឬស្មើនឹងការនាំចូលនាពេលអនាគតប្រហែល 5.4 ខែ) នៅចុងឆ្នាំ 2016 ធៀបនឹង 5.6 ពាន់លានដុល្លារក្នុងឆ្នាំ 2015។

**កិច្ចអភិវឌ្ឍន៍ជាវិជ្ជមាននៃម៉ាក្រូហិរញ្ញវត្ថុ រួមមានការធ្វើឲ្យមានការថមថយចុះនៃឥណទាន នៅកំពុងមានកំណើនរឹងមាំអមដោយការបង្កើនប្រាក់បញ្ញើរបស់វិស័យឯកជន។** ដើម្បីគាំទ្រដល់កំណើនសេដ្ឋកិច្ច កំណើនរូបិយវត្ថុទូទៅបានកើនឡើងពី 14.7 ភាគរយក្នុងឆ្នាំ 2015 ដល់ 17.9 ភាគរយ នៅចុងឆ្នាំ 2016 ដោយសារការកើនឡើងនូវប្រាក់បញ្ញើរូបិយប័ណ្ណបរទេស។ ទោះជាយ៉ាងណាក្តី កំណើនឥណទានបានថយចុះ ដែលឆ្លុះបញ្ចាំងមួយផ្នែកនូវការថយល្បឿននៃសកម្មភាពសេដ្ឋកិច្ច ដែលធ្វើឲ្យតម្រូវការឥណទានពីវិស័យលក់ដុំកម្មន្តសាល និងកសិកម្មថយចុះ។វិធានការម៉ាក្រូមានលក្ខណៈប្រយ័ត្ន ដែលណែនាំដោយធនាគារកណ្តាលកាលពីឆ្នាំមុនប្រហែលជាអាចបានរួមចំណែកបន្ថយកំណើនឥណទានក្នុងស្រុកដែរ។ក្នុងស្ថានភាពនេះ កំណើនឥណទាននៃវិស័យធនាគារបានថយចុះពី 28.6 ភាគរយ ក្នុងឆ្នាំ 2015 មកត្រឹម 25.8 ភាគរយ ក្នុងឆ្នាំ 2016។ កំណើនទំនុកចិត្តក្នុងវិស័យធនាគារបានជួយទាក់ទាញប្រាក់បញ្ញើពីវិស័យឯកជនឲ្យកើនពី 16.6 ភាគរយ ក្នុងឆ្នាំ 2015 ទៅ 19.9 ភាគរយនៅចុងឆ្នាំ 2016។ អត្រាឥណទានមិនដំណើរការបានកើនបន្តិចពី 2.3 ភាគរយ ក្នុងឆ្នាំ 2015 ទៅ 2.7 ភាគរយ ក្នុងឆ្នាំ 2016។

**សម្ពាធអតិផរណាបានកើនឡើង ជំរុញដោយភាពខ្លាំងក្លានៃតម្រូវការក្នុងស្រុកនាំមុខដោយចំណាយទៅលើការប្រើប្រាស់របស់គ្រួសារ ដោយសារប្រាក់ចំណូលបានកើនឡើង។** សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ បានកើនឡើងពី 2.8 ភាគរយ ក្នុងឆ្នាំ 2015 ដល់ 4.3 ភាគរយ ក្នុងឆ្នាំ 2017 ដែលជំរុញដោយកំណើនតម្រូវការក្នុងស្រុក។ ជាពិសេស ការនាំចូលយានយន្តក្នុងរយៈពេលមួយឆ្នាំបានកើនឡើង 21.4 ភាគរយ (គិតជាទឹកប្រាក់) ធៀបនឹង 20 ភាគរយ ក្នុងឆ្នាំ 2015 ហើយការនាំចូលប្រេងឥន្ធនៈក្នុងរយៈពេលមួយឆ្នាំ បានកើនពី 3.6 ភាគរយ ក្នុងឆ្នាំ 2015 ដល់ 14.2 ភាគរយ នៅឆ្នាំ 2016។ ប្រាក់រៀល

បានឡើងថ្លៃធៀបនឹងប្រាក់ដុល្លារ អាមេរិក ប្រាក់បាតថៃ និងប្រាក់ដុងវៀតណាម។ អត្រាប្តូរប្រាក់រៀល/ដុល្លារអាមេរិកបានឡើងថ្លៃ ស្មើនឹង 3,990 រៀលក្នុងខែមីនា ឆ្នាំ 2017 ធៀបនឹង 4,050 រៀល កាលពីខែធ្នូ ឆ្នាំ 2016។

**កំណើនចំណាយលើប្រាក់បៀវត្សវិស័យសាធារណៈ បានធ្វើឲ្យឱនភាពសារពើពន្ធរីកធំជាងមុន ប៉ុន្តែនៅតែស្ថិតក្នុងកម្រិតទាបនៅឡើយ។** កំណើនសារពើពន្ធ ដែលមានគោលដៅចម្បងដើម្បីបង្កើនប្រាក់បៀវត្សវិស័យសាធារណៈត្រូវបានប៉ាន់ស្មានថាបានកើនឡើងពី 6.5 ភាគរយ នៃផសស ក្នុងឆ្នាំ 2015 ដល់ 7.4 ភាគរយ នៃ ផសស ក្នុងឆ្នាំ 2016។ ជាមួយគ្នានេះ ចំណាយមូលធនសាធារណៈបានបន្តធ្លាក់ចុះបន្ថែមទៀត ពី 7.8 ភាគរយ នៃ ដល់ 7.2 ភាគរយ នៃ ផសស មួយផ្នែកធំគឺ បណ្តាលមកពីការកាត់បន្ថយជាបណ្តើរៗនៃសមាសធាតុមូលនិធិ ដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍។ ក្នុងឆ្នាំ 2016 ចំណាយសាធារណៈត្រូវបានប៉ាន់ស្មានថាបានកើនឡើងដល់ 21.4 ភាគរយ នៃ ផសស ពី 20.5 ភាគរយ ក្នុងឆ្នាំ 2015 ។ ការប្រមូលចំណូលនៅតែមានភាពរឹងមាំ គឺស្មើនឹង 18.5 ភាគរយ នៃ ផសស ដែលមានកម្រិតទាបបន្តិចធៀបនឹងការប្រមូលចំណូលឆ្នាំ 2015 ដែលមានអត្រា 18.7 ភាគរយ នៃ ផសស ដោយសារការធ្លាក់ចុះនៃចំណូលមិនមែនពន្ធ។ ដូច្នេះ ឱនភាពសារពើពន្ធសរុប (គិតទាំងជំនួយឥតសំណង) បានឡើងដល់ 1.4 ភាគរយ នៃ ផសស ក្នុងឆ្នាំ 2016 ធៀបនឹងតុល្យភាពសារពើពន្ធក្នុងឆ្នាំ 2015។ ចំណាត់ថ្នាក់កង្វល់បំណុលរបស់កម្ពុជា តាមរយៈការវិភាគចុងក្រោយបំផុត អំពីនិរន្តរភាពបំណុលរបស់ធនាគារពិភពលោក/មូលនិធិរូបិយវត្ថុអន្តរជាតិក្នុងឆ្នាំ 2016 នៅតែមានកម្រិតទាប គោលការណ៍ចម្បងនៃការខ្ចីដែលមានលក្ខណៈសម្បទាន។

## ទស្សនវិស័យនាពេលអនាគត

**កំណើនសេដ្ឋកិច្ចត្រូវបានព្យាករថានៅមានកម្រិតខ្ពស់ មានកំណើន 6.9 ភាគរយក្នុងឆ្នាំនេះ និងឆ្នាំក្រោយ ប៉ុន្តែអាចថយចុះបន្តិចមកត្រឹម 6.7 ភាគរយ នៅឆ្នាំ 2019។** សកម្មភាពសេដ្ឋកិច្ចមួយផ្នែកកើនឡើង ដោយសារការបង្កើនចំណាយរបស់រដ្ឋាភិបាល។ ប៉ុន្តែទោះជាយ៉ាងណាក្តី គេកំពុងឃើញមានសញ្ញាធ្លាក់ចុះមួយចំនួន ពិសេសក្នុងវិស័យសំណង់។ ការធ្លាក់ចុះបន្តិចនៃការនាំចេញសម្លៀកបំពាក់ត្រូវបានរំពឹងថានឹងប៉ះប៉ូវដោយសារការរីកចម្រើនជាបណ្តើរៗ នៃវិស័យកសិកម្ម អាស្រ័យដោយកិច្ចប្រឹងប្រែងរួមគ្នាក្នុងការជួយធ្វើឲ្យវិស័យនេះមានដំណើរការឡើងវិញ។ វិស័យទេសចរណ៍ក៏អាចងើបឡើងវិញជាបណ្តើរៗ មួយផ្នែកគឺដោយសារការបង្កើតជើងហោះហើរត្រង់ រួមជាមួយគំនិតផ្តួចផ្តើមមួយចំនួនក្នុងការជំរុញការមកដល់ នៃភ្ញៀវទេសចរ ដូចជាគម្រោង “ត្រៀមខ្លួនជាស្រេចដើម្បីទទួលទេសចរចិន” ជាដើម។

**ក្នុងរយៈពេលមធ្យម ទស្សនវិស័យអំពីកំណើននៅតែមានលក្ខណៈល្អប្រសើរ មួយផ្នែកធំគឺដោយសារពិពិធកម្មនៃការនាំចេញ។** ទោះជាយ៉ាងណាក្តី ការជំរុញការវិនិយោគ ដែលមានផលិតភាពលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលទ្រទ្រង់គោលនយោបាយកំណើន (និងផ្តោតលើពលរដ្ឋ ក្រីក្រ) តាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ 2014-18 នឹងមានសារៈសំខាន់ ខណៈដែលហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់ជាឧបសគ្គចម្បងយូរអង្វែងរបស់កម្ពុជា ហើយកង្វះហេដ្ឋារចនាសម្ព័ន្ធនេះត្រូវបានមើលឃើញថាជាបញ្ហាសំខាន់ផងដែរ។ ក្រោយពីការបង្កើនចំណាយសាធារណៈលើវិស័យសង្គមកិច្ចកាលពីពេលថ្មីៗ ជំហានសំខាន់បន្ទាប់គឺត្រូវបង្កើនប្រសិទ្ធភាពចំណាយ។ ការលើកកម្ពស់ផលិតភាពការងារ ក៏ដូចជាសមិទ្ធិកម្មនៃវិស័យសាធារណៈ នឹងក្លាយជាមូលដ្ឋានគ្រឹះ ដើម្បីឲ្យប្រទេសកម្ពុជារក្សាភាពប្រកួតប្រជែង ខណៈមានការប្រកួតប្រជែងកាន់តែខ្លាំង ពីបណ្តាប្រទេសនាំចេញសម្លៀកបំពាក់ក្នុងតំបន់ ដែលមានប្រាក់ឈ្នួលទាប។

**ការកាត់បន្ថយភាពក្រីក្រត្រូវបានរំពឹងថានឹងមានជាបន្តក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ ដោយសារតែវិស័យកាត់ដេរសម្លៀកបំពាក់ វិស័យសំណង់ និងវិស័យសេវាកម្ម ព្រមទាំងការកើនឡើងនូវការបង្វែរប្រាក់។** សេដ្ឋកិច្ចមិនមែនកសិកម្មនៅជនបទ (សម្លៀកបំពាក់ សេវាកម្ម និងការបង្វែរប្រាក់) អាចជាកត្តារួមចំណែកដ៏សំខាន់ចំពោះការកាត់បន្ថយភាពក្រីក្រ និងវិបុលភាពរួមនៅកម្ពុជាជាបន្តក្នុងបណ្តាឆ្នាំខាងមុខ។ ប្រទេសកម្ពុជាមានលក្ខណៈស្រដៀងនឹងប្រទេសវៀតណាមក្នុងន័យដែលការធ្វើពិពិធកម្ម លើការចិញ្ចឹមជីវិតនៅតំបន់ជនបទ បានរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងវិបុលភាពរួម។

**ហានិភ័យអវិជ្ជមានចំពោះទស្សនវិស័យនេះ រួមមានផលអវិជ្ជមានកំណើនជាបន្តនៃអត្រាការប្រាក់របស់សហរដ្ឋអាមេរិក ការងើបឡើងវិញយឺតជាងការរំពឹងទុកនៃសេដ្ឋកិច្ចនៅអឺរ៉ុប និងភាពមិនប្រាកដប្រជាចំពោះពាណិជ្ជកម្មសកល។** ចំពោះទិដ្ឋភាពក្នុងស្រុក ភាពមិនប្រាកដប្រជាទាក់ទងនឹងការបោះឆ្នោតអាចកើតមានឡើងក្នុងពេល និងក្រោយពេលបោះឆ្នោតសាកល ដែលគ្រោងប្រព្រឹត្តទៅនៅពាក់កណ្តាលឆ្នាំ 2018។

## សារនិងជម្រើសគោលនយោបាយសំខាន់ៗ

**ការរក្សាឲ្យនៅមានភាពប្រកួតប្រជែង តាមរយៈការបង្កើនផលិតភាពការងារ គឺជាគន្លឹះសម្រាប់ឆ្លើយតបនឹងការឡើងថ្លៃប្រាក់ឈ្នួលនៃវិស័យឯកជន។** អាទិភាពចម្បងគឺត្រូវធ្វើការកែលម្អ ការអប់រំកម្រិតមូលដ្ឋានការលើកកម្ពស់ជំនាញវិជ្ជាជីវៈ ទន្ទឹមនឹងការកាត់បន្ថយថ្លៃថាមពល ដើម្បីទាក់ទាញ និងប្រកួតប្រជែងក្នុងផ្នែកកម្មន្តសាលដែលមានតម្លៃបន្ថែមខ្ពស់ និងកាន់តែមានលក្ខណៈស្មុគស្មាញ។ ការវិនិយោគក្នុងពេលបច្ចុប្បន្ន ដើម្បីលើកស្ទួយលទ្ធផលនៃការរៀនសូត្របន្ថែមទៀត គួបផ្សំជាមួយការបង្កើនអត្រាសិស្សចូលរៀននៅកំរិតមធ្យមសិក្សា មានសារសំខាន់ជាសារវន្តសម្រាប់ជោគជ័យ ក្នុងការធ្វើពិពិធកម្មនៃសេដ្ឋកិច្ចនាពេលអនាគត។

**កំណែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីកែលម្អការផ្តល់សេវាសាធារណៈ មានសារៈសំខាន់ ពិសេសក្រោយពេលបង្កើនប្រាក់បៀវត្សមន្ត្រីរាជការកាលពីពេលកន្លងទៅថ្មីៗ។** ដោយសារតែវិស័យសាធារណៈគឺជាវិស័យផ្តល់ និងជួយសម្រួលសេវាសំខាន់ៗ វាមានសារៈសំខាន់ក្នុងការផ្សាភ្ជាប់កំណើនប្រាក់បៀវត្សយ៉ាងច្រើននៃវិស័យសាធារណៈ ទៅនឹងការកែលម្អ ការផ្តល់សេវាសាធារណៈរបស់ខ្លួន។ ការបង្កើនផលិតភាពនៃវិស័យសាធារណៈគាំទ្រដល់ការអភិវឌ្ឍវិស័យឯកជនដើម្បីជំរុញកំណើន និងការកាត់បន្ថយភាពក្រីក្រ។

**ក្នុងបរិបទនៃការធ្លាក់ចុះថវិកាមូលធនដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍កម្ពុជាត្រូវពង្រឹងការគ្រប់គ្រងវិនិយោគសាធារណៈ ដើម្បីបង្កើនការចំណាយមូលធនដែលផ្តល់ហិរញ្ញប្បទានដោយរដ្ឋាភិបាល។** ការវិនិយោគដែលជំរុញកំណើន និងផ្តល់អត្ថប្រយោជន៍ដល់ពលរដ្ឋក្រីក្រ ពិសេសគឺការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធបន្តអាចផ្តល់អត្ថប្រយោជន៍ពីការវិភាជន៍បន្ថែមក្នុងការប៉ះប៉ូវការកាត់បន្ថយថវិការបស់ដៃគូអភិវឌ្ឍន៍។ ប៉ុន្តែការលើកកម្ពស់ក្របខណ្ឌគតិយុត្តសម្រាប់ការគ្រប់គ្រងវិនិយោគសាធារណៈ និងកសាងសមត្ថភាពនៅតាមក្រសួង និងស្ថាប័នពាក់ព័ន្ធគឺជាអាទិភាពទីមួយ ដែលជាបុរេលក្ខខណ្ឌសម្រាប់បង្កើនប្រសិទ្ធភាពវិនិយោគ។ ចំពោះព័ត៌មានលម្អិតបន្ថែមទៀតស្តីពីការគ្រប់គ្រងវិនិយោគសាធារណៈ សូមអានត្រង់ផ្នែក "ការវិនិយោគលើកំណើន និងលើសេវាសាធារណៈ" ។

# ស្វែងយល់សេដ្ឋកិច្ចកម្ពុជាមួយរំពេច

### កំណើនពិតនៅតែមានសន្ទុះខ្លាំងក្លា...
រួមចំណែកចំពោះកំណើន (ភាគរយ)




ប្រភព: អាជ្ញាធរកម្ពុជា

### ...ប៉ុន្តែកំណើនការនាំចេញសំខាន់បានធ្លាក់ចុះ
នាំចេញសម្លៀកបំពាក់ និងនាំចូលក្រណាត់




ប្រភព: អាជ្ញាធរកម្ពុជា

### ប្រាក់បំរុងអន្តរជាតិដុលបានកើនឡើងពីការបង្កើនស្ថានភាពពាណិជ្ជកម្មក្រៅប្រទេស...




ប្រភព: អាជ្ញាធរកម្ពុជា

### ...ឱនភាពគណនីចរន្តថយចុះដោយសារហិរញ្ញប្បទានពីវិនិយោគផ្ទាល់ពីបរទេសរឹងមាំ
គណនីចរន្ត ជញ្ជីងពាណិជ្ជកម្ម វិនិយោគផ្ទាល់ពីបរទេស (ភាគរយនៃផសស)




ប្រភព: អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

### ការប្រមូលចំណូលបានច្រើនបានកាត់បន្ថយឱនភាពថវិកា...
ឱនភាពសារពើពន្ធទូទៅ (ភាគរយនៃ ផសស)




ប្រភព: អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

### ...ប៉ុន្តែវិនិយោគមូលធនបានធ្លាក់ចុះខណៈដែលប្រាក់ខែបានកើនឡើង
ចំណាយមូលធន និងបៀវត្ស (ភាគរយនៃ ផសស)




ប្រភព: អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក


T.S. LINES
TS



# B. ស្ថានភាពអភិវឌ្ឍសេដ្ឋកិច្ចថ្មីៗ

## វិស័យពិត

### a) វិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង

**ទោះជានៅតែមានភាពរឹងមាំក្តី ការនាំចេញសម្លៀកបំពាក់បានធ្លាក់សន្ទុះចាប់តាំងពីឆមាសទីពីរមកម្ល៉េះ។** ការកើនឡើងនៃថ្លៃពលកម្មដែលបណ្តាលមកពីការកើនឡើងនៃថ្លៃជីវភាពរស់នៅ ការឡើងថ្លៃនៃប្រាក់ដុល្លារអាមេរិក និងការប្រកួតប្រជែងពីបណ្តាប្រទេសក្នុងតំបន់ ដែលមានប្រាក់ឈ្នួលទាប ពិសេសគឺមីយ៉ាន់ម៉ា នៅតែបន្តមានសម្ពាធអវិជ្ជមានមកលើថ្លៃផលិតផលសម្លៀកបំពាក់នាំចេញ។ ជាលទ្ធផល កំណើនប្រចាំឆ្នាំនៃការនាំចេញសម្លៀកបំពាក់(គិតជាទឹកប្រាក់) បានថយចុះពី 12.3 ភាគរយ ក្នុងឆ្នាំ 2015 មកត្រឹម 8.4 ភាគរយ (រូបលេខ 1) គិតជាទឹកប្រាក់មានចំនួន 6.6 ពាន់លានដុល្លារក្នុងឆ្នាំ 2016។

**បរិមាណនាំចេញសម្លៀកបំពាក់របស់កម្ពុជាបានកើនឡើងពី 8.9 ភាគរយ ក្នុងឆ្នាំ 2015 ដល់ 12.3 ភាគរយ ក្នុងឆ្នាំ 2016 (រូបលេខ 2) បង្ហាញថាមានការប្រឹងប្រែងកាន់តែខ្លាំងដើម្បីរក្សាចំណែកទីផ្សារ។** ការកើនឡើងនូវការប្រកួតប្រជែងបាននាំមក នូវការកាត់បន្ថយថ្លៃនាំចេញសម្លៀកបំពាក់ទៅកាន់រាល់ប្រទេសគោលដៅចម្បងៗ។ ថ្លៃនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិកត្រូវបាន ប៉ះពាល់ខ្លាំងជាងគេ ធ្លាក់ចុះអស់ 7.2 ភាគរយ ក្នុងឆ្នាំ 2016 (រូបលេខ 3)។ ការនាំចេញសម្លៀកបំពាក់របស់កម្ពុជា ទៅកាន់សហរដ្ឋអាមេរិកបានឡើងដល់កម្រិតខ្ពស់បំផុតក្នុងឆ្នាំ 2013 ខណៈដែលទឹកប្រាក់នាំចេញសម្លៀកបំពាក់សរុបឡើងដល់2.03ពាន់លានដុល្លារអាមេរិក។ ចាប់តាំងពីពេលនោះមក ការនាំចេញទៅកាន់សហរដ្ឋអាមេរិកបានធ្លាក់ចុះជាបណ្តើរៗមកត្រឹម 1.7 ពាន់លានដុល្លារ ក្នុងឆ្នាំ 2016 (រូបលេខ4)។

**រូបលេខ 1: ខណៈនៅមានភាពរឹងមាំ ការនាំចេញសម្លៀកបំពាក់បានធ្លាក់ចុះ (លានដុល្លារអាមេរិក)**




ប្រភព: អាជ្ញាធរកម្ពុជា

**រូបលេខ 2: បរិមាណនាំចេញសម្លៀកបំពាក់កើនឡើង ប៉ុន្តែកំណើនទឹកប្រាក់នាំ ចេញសម្លៀកបំពាក់ថយល្បឿន**




ប្រភព: អាជ្ញាធរកម្ពុជា

**រូបលេខ 3: ថ្លៃនាំចេញសម្លៀកបំពាក់ជាមធ្យម (ដុល្លារអាមេរិក/ឡូ) កំពុងធ្លាក់ចុះ**




ប្រភព: អាជ្ញាធរកម្ពុជា

**រូបលេខ 4: ការនាំចេញសម្លៀកបំពាក់ទៅសហរដ្ឋអាមេរិកបានធ្លាក់ចុះ**
ការនាំចេញសម្លៀកបំពាក់តាមគោលដៅសំខាន់ (លានដុល្លារអាមេរិក)




ប្រភព: អាជ្ញាធរកម្ពុជា

**ទោះជាលំហូរវិនិយោគផ្ទាល់ប្រចាំឆ្នាំមកកាន់វិស័យកាត់ដេរបានធ្លាក់ចុះជាបណ្តើរៗ ពី 490 លានដុល្លារអាមេរិកក្នុងឆ្នាំ 2012 មកត្រឹម 160 លានដុល្លារអាមេរិកក្នុងឆ្នាំ 2016 (រូបលេខ 5) ក៏ដោយក៏ការនាំចេញសម្លៀកបំពាក់សរុបបានបន្តកើនឡើង។** ប៉ុន្តែការធ្លាក់ចុះបន្តទៀតនៃលំហូរវិនិយោគផ្ទាល់ពីបរទេសមកកាន់វិស័យនេះ ជាសញ្ញាអវិជ្ជមាន សម្រាប់ការពង្រីកវិស័យកាត់ដេរទៅអនាគត ដោយហេតុថាវិស័យនេះកំពុងឈានទៅរកផលិតផលដែលមានតម្លៃបន្ថែមខ្ពស់ ហើយនឹងអាចក្លាយទៅជាវិស័យអតិមូលធន ប្រសិនបើត្រូវប្រឈមមុខនឹងការកើនឡើងថ្លៃពលកម្ម ដោយការបង្កើនផលិតភាព។

**ដូចករណីនាំចេញសម្លៀកបំពាក់នេះ ការនាំចេញស្បែកជើងក៏ត្រូវបានប្រឈមមុខនឹងការប្រកួតប្រជែងតម្លៃយ៉ាងតឹងតែងដែរ។** ជាលទ្ធផល ក្នុងឆ្នាំ 2016 ថ្លៃស្បែកជើងជាមធ្យមនៅទ្រឹង (រូបលេខ 6)។ ទោះជាយ៉ាងណាក្តី ការនាំចេញស្បែកជើងរបស់កម្ពុជារក្សាបានភាពរឹងមាំ ជាមួយនឹងកំណើន 15.6 ភាគរយធៀបនឹងឆ្នាំមុន ជាទឹកប្រាក់កើនដល់ 763 លានដុល្លារអាមេរិកក្នុងឆ្នាំ 2016។ ការនាំចេញស្បែកជើងទៅកាន់ទីផ្សារសហភាពអឺរ៉ុបមានចំនួន 43 ភាគរយ នៃការនាំចេញស្បែកជើងសរុប មានកំណើន 9.2.ភាគរយ ក្នុងឆ្នាំ 2016 ធៀបនឹង 30.2 ភាគរយ ក្នុងឆ្នាំ 2015។ ប្រការនេះអាចពន្យល់ដោយតថភាព ដែលថាការនាំចេញស្បែកជើងទើបតែចាប់ផ្តើមពីកម្រិតទាប។

**ការបន្តធ្លាក់សន្ទុះក្នុងការនាំចេញសម្លៀកបំពាក់ ត្រូវបានមើលឃើញក្នុងរយៈពេលពីរបីខែដំបូងនៃឆ្នាំនេះ។** ទោះជាយ៉ាងណា នៅមិនទាន់ដល់ពេលសន្និដ្ឋានថាព្រឹត្តការណ៍នេះនឹងប៉ះពាល់ ឬមិនប៉ះពាល់ដល់ការព្យាករណ៍កំណើនឆ្នាំ 2017 នៅឡើយ។

**រូបលេខ 5: វិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ កំពុងធ្លាក់ចុះ** (អចលកម្ម គិតជាលានដុល្លារអាមេរិក)




ប្រភព: អាជ្ញាធរកម្ពុជា

**រូបលេខ 6: កំណើននាំចេញស្បែកជើងបានធ្លាក់ចុះ រីឯថ្លៃនាំចេញស្បែកជើងជាមធ្យមបានថយចុះដោយសារការប្រកួតប្រជែង**




ប្រភព: អាជ្ញាធរកម្ពុជា

## b) សំណង់និងអចលនទ្រព្យ

**សកម្មភាពសំណង់ បន្តមានសភាពរស់រវើក ដោយសារវិនិយោគិន នៅតែមានចំណាប់អារម្មណ៍ខ្លាំង ជាមួយអចលនទ្រព្យលំនៅស្ថាន និងអចលនទ្រព្យពាណិជ្ជកម្ម សំអាងលើកំណើនជាបន្តបន្ទាប់ នូវចំនួននិងតម្លៃទឹកប្រាក់នៃគម្រោងសាងសង់ដែលបានទទួលការយល់ព្រម (រូបលេខ 7)**[1]។ យោងតាមទិន្នន័យដែលមានចុងក្រោយបំផុតបង្ហាញថា ធៀបនឹងរយ:ពេលដូចគ្នានាឆ្នាំកន្លងមក បរិមាណទឹកប្រាក់សរុបនៃគម្រោងសំណង់ដែលបានទទួលការយល់ព្រមបានធ្លាក់ចុះក្នុងត្រីមាសទីមួយនៃឆ្នាំ 2017 ចំណែកឯទំហំសរុបគិតជាម៉ែត្រការ៉េនៃគម្រោងសំណង់ ដែលបានទទួលការឯកភាពក៏ធ្លាក់ចុះផងដែរ។[2] នេះបង្ហាញឲ្យឃើញសក្តានុពលនៃការធ្លាក់ចុះនៃសកម្មភាពសាងសង់ក្នុងរយ:ពេលខ្លី និងរយ:ពេលមធ្យម។

**រូបលេខ 7: ចំនួននិងទឹកប្រាក់នៃគម្រោងសាងសង់ដែលបាន យល់ព្រមបានកើនឡើង មួយផ្នែកបណ្តាលមកពីគម្រោងធំដែលបានឯកភាពក្នុងខែមេសា ឆ្នាំ 2016 (លានដុល្លារអាមេរិក)**




ប្រភព: អាជ្ញាធរកម្ពុជា

ផ្ទុយទៅវិញ ការនាំចូលសម្ភារ:ដទៃសម្រាប់សំណង់ ដូចជាគ្រឿងបំពាក់សម្ភារ:សំណង់ចាំបាច់និងសង្ហារឹមបានកើនឡើងបន្ថែមទៀត (រូបលេខ 8) គឺកើនឡើងពី 38.5 ភាគរយក្នុងឆ្នាំ 2015 ដល់ 54.3 ភាគរយ ក្នុងឆ្នាំ 2016។

**រូបលេខ 8: ការនាំចូលដែកបានធ្លាក់ចុះខណ:ដែលការនាំចូលគ្រឿងបំពាក់ (បរិក្ខារបំពាក់គ្រឿងឧបភោគ សង្ហារឹម) នៅតែមានចំនួនច្រើន** (% បំរែបំរួលធៀបឆ្នាំមុន)




ប្រភព: អាជ្ញាធរកម្ពុជា

**សន្ទុះរីកចម្រើននៃវិស័យសំណង់ និងអចលនទ្រព្យកាលពីពេលកន្លងទៅថ្មីៗ ត្រូវបានជម្រុញមួយផ្នែកធំដោយលំហូរវិនិយោគផ្ទាល់ពីបរទេស និងដោយសារការបង្កើនឥណទានក្នុងស្រុក (រូបលេខ 9)**។ វិនិយោគផ្ទាល់ពីបរទេស (អចលនទ្រព្យ) ក្នុងវិស័យសំណង់មានចំនួន 1.3ពាន់លានដុល្លារអាមេរិក នៅឆ្នាំ 2016។ ឥណទានក្នុងស្រុកដែលបានផ្តល់ឲ្យវិស័យនេះបានកើនឡើងយ៉ាងឆាប់រហ័សក្នុងរយ:ពេលប្រាំឆ្នាំ ក្នុងមួយឆ្នាំមានកំណើនជាមធ្យមចំនួន 32 ភាគរយ។ បរិមាណទឹកប្រាក់វិនិយោគផ្ទាល់ពីបរទេសសរុបក្នុងវិស័យសំណង់ពីឆ្នាំ 2000-15 ត្រូវបានប៉ាន់ស្មានថាបានកើនដល់ 3.5 ពាន់លានដុល្លារអាមេរិក[3] (ឬ 19ភាគរយនៃផសស) ចំណែកឥណទានក្នុងស្រុកដែលបានផ្តល់ឲ្យវិស័យសំណង់មានចំនួន 3 ពាន់លានដុល្លារអាមេរិក (ឬ 17.4 ភាគរយនៃ ផសស) នៅចុងឆ្នាំ 2016។

**រូបលេខ 9: លំហូវិនិយោគផ្ទាល់ពីបរទេស និងឥណទានក្នុងស្រុកផ្តល់ឲ្យវិស័យសំណង់ទ្រទ្រង់ដោយសន្ទុះរីកចម្រើននៃសំណង់ (លានដុល្លារអាមេរិក)**




ប្រភព: អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក
* មិនរាប់បញ្ចូលគម្រោងធំៗ

1 មិនរួមបញ្ចូលចំនួនគម្រោងធំៗដែលទទួលបានការយល់ព្រមក្នុងខែមេសា ឆ្នាំ 2016 ចំនួន និងទឹកប្រាក់នៃគម្រោងសាងសង់នឹងកើនឡើងប្រហែល 30 ភាគរយក្នុងឆ្នាំ 2016 ធៀបនឹងឆ្នាំមុន (ប៉ាន់ស្មានផ្អែកលើទឹកប្រាក់វិនិយោគដែលបានទទួលការយល់ព្រមពី 300-600 លានដុល្លារអាមេរិក)

2 យោងតាមរបាយការណ៍វឌ្ឍនភាពត្រីមាសទីមួយឆ្នាំ 2017 នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បរិមាណទឹកប្រាក់សរុបនៃគម្រោងសាងសង់ដែលបានឯកភាពធ្លាក់ចុះ 22.1 ភាគរយក្នុងត្រីមាសទីមួយនៃឆ្នាំ 2017 ធៀបនឹងឆ្នាំមុន ខណ:ដែលទំហំសរុបគិតជាម៉ែត្រការ៉េដែលបានឯកភាពធ្លាក់ចុះ 45.4 ភាគរយធៀបនឹងឆ្នាំមុន

3 អង្កេតវិនិយោគផ្ទាល់ពីបរទេស ខែកក្កដា ឆ្នាំ 2016 ដោយធនាគារជាតិនៃកម្ពុជា

## c) វិស័យទេសចរណ៍

**កំណើននៃចំនួនមកដល់នៃភ្ញៀវទេសចរធៀបនឹងឆ្នាំមុនបានបន្តធ្លាក់ចុះ ពី 6.1 ភាគរយ ក្នុងឆ្នាំ 2015 មកត្រឹម 5.0 ភាគរយ (រូបលេខ 10)។** ចំនួនភ្ញៀវមកដល់តាមជើងអាកាសបានកើនឡើង 9.2 ភាគរយ ក្នុងឆ្នាំ 2016 មានកំណើនដូចឆ្នាំ 2015 ដែរ។ ភ្ញៀវទេសចរមកពីតំបន់អាស៊ីនៅតែជាប្រភពទេសចរចម្បង ហើយប្រទេសអាស៊ីធំបំផុតទាំងប្រាំ ដែលជាទីផ្សារធំដូចឆ្នាំ 2015 មានចំណែកប្រហែល 60 ភាគរយនៃចំណែកទីផ្សារក្នុងឆ្នាំ 2016។ ប្រទេសវៀតណាម ចិន និងប្រទេសថៃគឺជាប្រទេសប្រភពទេសចរណ៍ចម្បង មានចំណែក 19.1 ភាគរយ 16.6 ភាគរយ និង 7.8 ភាគរយនៃចំណែកទីផ្សារទេសចរណ៍សរុបរៀងៗគ្នា។

**រូបលេខ 10: ការមកដល់នៃភ្ញៀវទេសចរអន្តរជាតិបានធ្លាក់ចុះ (លាននាក់)**




ប្រភព: អាជ្ញាធរកម្ពុជា

**សេចក្ដីត្រូវប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីទាក់ទាញភ្ញៀវទេសចរបន្ថែមទៀត តាមរយៈការថែមជើងហោះហើរត្រង់** និងតាមរយៈការអនុវត្តគំនិតផ្ដួចផ្ដើមថ្មីៗដូចជាកម្មវិធី "China Ready-ត្រៀមខ្លួនទទួលទេសចរចិន" និងកញ្ចប់ទេសចរណ៍រួមគ្នា។ មុខងារ និងអង្គការលេខរបស់ក្រសួងទេសចរណ៍ត្រូវបានពង្រឹង[4]។ ក្រសួងនេះត្រូវបានផ្ដល់តួនាទីដឹកនាំ ក្នុងការគ្រប់គ្រង និងអភិវឌ្ឍវិស័យទេសចរណ៍ រួមទាំងការអភិវឌ្ឍធនធានមនុស្ស និងសហការជាមួយស្ថាប័នដទៃទៀតរបស់រដ្ឋាភិបាល និងឯកជនផងដែរ ដើម្បីអនុវត្តច្បាប់ស្ដីពីទេសចរណ៍ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍។

**រូបលេខ 11: ទាំងប្រទេសថៃ និងវៀតណាមបានទាក់ទាញភ្ញៀវអន្តរភាពបានល្អក្នុងឆ្នាំ 2016** (% បំរែបំរួលធៀបនឹងឆ្នាំមុន)




ប្រភព: អាជ្ញាធរកម្ពុជា

**នៅដើមឆ្នាំនេះ គេឃើញមានសញ្ញាងើបឡើងវិញជាបណ្ដើរៗនៃវិស័យទេសចរណ៍។** ការមកដល់នៃភ្ញៀវទេសចរណ៍ពីអឺរ៉ុបខាងលិច និងពីតំបន់អាមេរិកខាងជើងបានកើនឡើងដល់កំពូល ទោះបីជាអាស៊ី នៅតែជាទីផ្សារទេសចរណ៍ចម្បង សម្រាប់ប្រទេសកម្ពុជាក្ដី[5]។

**ការធ្វើពិពិធកម្មនៃមណ្ឌលទាក់ទាញទេសចរ លើសពីឧទ្យានបុរាណអង្គរមានសារសំខាន់។** នាពេលបច្ចុប្បន្ននេះ ការមកដល់នៃភ្ញៀវទេសចរអន្តរជាតិ មួយផ្នែកធំគឺដោយសារប្រាសាទអង្គរដែលស្ថិតនៅភាគឥសាននៃខេត្តសៀមរាប (រូបលេខ 10) ទោះជាកម្ពុជាសម្បូរណ៍រមនីយដ្ឋានទេសចរណ៍ប្រវត្តិសាស្ត្រ វប្បធម៌ និងធម្មជាតិ រាប់មិនអស់ក្ដី។ ក្នុងន័យនេះ ការសម្របសម្រួលអន្តរស្ថាប័ន ក៏ដូចជាកិច្ចសហការជាមួយវិស័យឯកជនក្នុងការអភិវឌ្ឍ និងការធ្វើផ្លូវចូលទៅកាន់មណ្ឌលទេសចរណ៍ថ្មីៗដែលមានលក្ខណៈទាក់ទាញ និងកែលម្អមណ្ឌលទេសចរណ៍ដែលមិនសូវមានការអភិវឌ្ឍក្នុងពេលបច្ចុប្បន្ន គឺជាកិច្ចការសំខាន់ជាសារវន្ត។ ខណៈកំពុងរីចំរើន វិស័យសំណង់ជួយប្រែក្លាយតំបន់ទីក្រុងអភិវឌ្ឍថ្មីៗ ឲ្យក្លាយជាតំបន់គោលដៅទេសចរណ៍ ជាមួយនឹងការកែលម្អហេដ្ឋារចនាសម្ព័ន្ធ មណ្ឌលសេវានានា និងកសាងផ្លូវចូលទៅដល់ទីទាំងនោះ នឹងជួយគាំទ្រដល់ការធ្វើពិពិធកម្មក្នុងវិស័យទេសចរណ៍។

---

4 អនុក្រឹត្យចុះថ្ងៃទី 16 ខែ ធ្នូ ឆ្នាំ 2016 ស្ដីពីរចនាសម្ព័ន្ធ និងមុខងាររបស់ក្រសួងទេសចរណ៍

5 របាយការណ៍ស្ថិតិទេសចរណ៍ខែមករា ឆ្នាំ 2017 ក្រសួងទេសចរណ៍







## d) វិស័យកសិកម្ម

**កាលពីឆ្នាំមុនផលិតកម្មស្រូវបានកើនឡើង ដោយសារធាតុអាកាសអំណោយផលល្អ។** ផលិតកម្មស្រូវវស្សា ដែលមានទំហំ 80 ភាគរយនៃផលិតកម្មស្រូវសរុបរបស់កម្ពុជា បានរីកចម្រើនយ៉ាងច្រើនជាលើកដំបូង ចាប់តាំងពីឆ្នាំ 2013 (រូបលេខ 12) កើនឡើងចំនួន 0.38 លានតោន នៅឆ្នាំ 2016 (និងកើនឡើងដល់ 7.5 លានតោន ឬកើនឡើង 5.3 ភាគរយ ធៀបនឹងឆ្នាំមុន)។ កំណើននេះកើនឡើងដោយសារការពង្រីកផ្ទៃដីប្រមូលផលចំនួន 0.08 លានតោន និងដោយសារកំណើនទិន្នផលចំនួន 0.03 លានតោន។

**រូបលេខ 12 : ការរួមចំណែកធ្វើឲ្យផលិតកម្មស្រូវវស្សាកើនឡើង** (លានតោន)




ប្រភព: អាជ្ញាធរកម្ពុជា

ផ្ទៃដីប្រមូលផលបានកើនឡើង 1.1 ភាគរយ ស្មើនឹង 22.6 លានហិកតា ចំណែកឯទិន្នផលបានកើនឡើង 4.2 ភាគរយ ជាមធ្យមស្មើនឹង 3.2 តោនក្នុងមួយហិកតា (98 ភាគរយនៃផ្ទៃដីដាំដុះត្រូវបានប្រមូលផលរួច)[6]។ ទោះជាយ៉ាងណាក្តី ល្បឿននៃការធ្វើស្រែប្រាំងក្នុងឆ្នាំ 2017 បានថយចុះដោយសារផ្ទៃដីដាំដុះបានធ្លាក់ចុះចំនួន 11.3 ភាគរយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដោយសារ រដូវភ្លៀងវែង ក្រោយពីការបញ្ចប់ការដាំដុះរដូវវស្សាធម្មតាត្រូវបញ្ចប់។ ការដាំដុះដំណាំដទៃទៀត ដូចជា ដំឡូងមី ពោត សណ្តែក និងបន្លែក៏ថយចុះផងដែរ។

**ថ្លៃទំនិញប្រើប្រាស់កសិកម្មភាគច្រើននៅតែមានកម្រិតទាប ថ្វីបើថ្លៃកៅស៊ូធម្មជាតិ បានឡើងថ្លៃកាលពីពេលថ្មីៗ (រូបលេខ 13)។** ថ្លៃទំនិញកសិកម្មទាំងមូលត្រូវបានរំពឹងថានឹងកើនឡើងតិចជាង 1 ភាគរយក្នុងឆ្នាំ 2017 ប៉ុន្តែថ្លៃធញ្ញជាតិត្រូវបានព្យាករថានឹងធ្លាក់ចុះជិត 3 ភាគរយដោយសារការផ្គត់ផ្គង់មានភាពប្រសើរនាពេលខាងមុខ[7]។ ថ្លៃកៅស៊ូធម្មជាតិបានកើនឡើងដល់ 1.92 ដុល្លារអាមេរិកក្នុងមួយគីឡូក្រាម ក្នុងត្រីមាសទីបួន នៃឆ្នាំ 2016 កើនឡើងពី 1.57 ដុល្លារអាមេរិកក្នុងមួយគីឡូក្រាមកាលពីត្រីមាសទីបី។ ថ្លៃកៅស៊ូត្រូវបានតម្រូវការទិញខ្ពស់ពីប្រទេសចិន ខណៈដែលការផ្គត់ផ្គង់មានឧបសគ្គដោយការអូសបន្លាយការជៀរជ័រនៅប្រទេសម៉ាឡេស៊ី (និងនៅប្រទេសថៃ) បណ្តាលមកពីឥទ្ធិពលអាកាសធាតុអែលនីញ្ញូក្នុងដើមឆ្នាំ 2016។ បណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ រួមមានឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងប្រទេសថៃ បានឯកភាពគ្នាដើម្បីចាត់វិធានការគ្រប់គ្រងការផ្គត់ផ្គង់កៅស៊ូក្នុងកិច្ចប្រឹងប្រែងធ្វើឲ្យកៅស៊ូមានតម្លៃខ្ពស់។

**រូបលេខ 13 : ថ្លៃទំនិញកសិកម្ម លើកលែងតែថ្លៃកៅស៊ូធម្មជាតិនៅតែថោក**




ប្រភព: ធនាគារពិភពលោក

6 របាយការណ៍ប្រចាំសប្តាហ៍របស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ នាយកដ្ឋានរុក្ខកម្មនិងនេសាទ ថ្ងៃទី 19 ខែ មករា ឆ្នាំ 2016 http://www.maff.gov.kh/reports/69-cropingsta-tus/1771-weekly-report-18-01-17.html

7 តម្លៃទំនិញឧស្សាហកម្មនិងកើនឡើងក្នុងឆ្នាំ2017, ធនាគារពិភពលោក, សូមមើល http://www.worldbank.org/en/news/pressrelease/2017/01/24/Industrial-commodities-prices-to-surge-in-2017-world-bank

## ភាពក្រីក្រ

**សំណង់ជាវិស័យមួយដែលរីកចម្រើនថ្មី វិស័យនេះមានមុខងារកាន់តែសំខាន់ ក្នុងការផ្តល់នូវជំរើសប្រភពប្រាក់ចំណូលផ្សេងទៀតចំពោះកម្មករចំណាកស្រុក មកពីគ្រួសារជនបទដើម្បីទទួលបានការងារនៅតាមទីប្រជុំជន។** នេះជាចំណូលបន្ថែមលើប្រភពចំណូលដែលតែងបានទទួលពី វិស័យកាត់ដេរ និងស្បែកជើងពីមុន។ ការងារដែលបង្កើតឡើងដោយវិស័យសំណង់មានចំនួនប្រហែល 200,000 ក្នុងឆ្នាំ 2016 មានកំណើន 33.3 ភាគរយ ធៀបនឹងឆ្នាំមុន[8]។ ចំនួននេះត្រូវជា 10 ភាគរយនៃចំនួនការងារសរុបក្នុងវិស័យឧស្សាហកម្ម ឬប្រមាណជាមួយភាគបីនៃចំនួនការងារសរុប ដែលបង្កើតដោយវិស័យកាត់ដេរ សម្លៀកបំពាក់ និងស្បែកជើង។ ប្រាក់កម្រៃរបស់កម្មករគ្មានជំនាញក្នុងវិស័យសំណង់ឡើងដល់ 200 ដុល្លារអាមេរិកក្នុងមួយខែ មានចំនួនខ្ពស់ជាងយ៉ាងច្រើនធៀបនឹងប្រាក់ឈ្នួលអប្បរមានៃឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង ដែលស្មើនឹង 153 ដុល្លារអាមេរិកក្នុងមួយខែ មានកំណើន 9.2 ភាគរយ ធៀបនឹងឆ្នាំមុន។ ប្រាក់ឈ្នួលកម្មករជំនាញក្នុងវិស័យសំណង់មានចំនួនច្រើនជាងពីរដងធៀបនឹងប្រាក់ឈ្នួលអប្បស្ថិតក្នុងចន្លោះពី 300 ទៅ 450 ដុល្លារអាមេរិកក្នុងមួយខែ។

**ការធ្វើពិពិធកម្មមុខរបរចិញ្ចឹមជីវិតជួយកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។** ក្នុងឆ្នាំ 2015 ប្រាក់ចំណូលពីវិស័យមិនមែនកសិកម្មមានចំនួនច្រើនជាងមួយភាគបីនៃប្រាក់ចំណូលជនបទ ធៀបនឹងតិចជាងមួយភាគប្រាំក្នុងឆ្នាំ 2007 (រូបលេខ 14)។ ក្នុងរយៈពេលដូចគ្នា ចំណូលកសិកម្មរួមមានប្រាក់ឈ្នួលកសិកម្មបានធ្លាក់ចុះពី 63ភាគរយ មកត្រឹមតែ 43 ភាគរយនៃចំណូលសរុបនៅជនបទប៉ុណ្ណោះ។ ហេតុនេះ ភាពក្រីក្រត្រូវបានរំពឹងថានឹងបន្តធ្លាក់ចុះ ទោះបីជាកសិកម្មស្ថិតក្នុងសភាពនៅទ្រឹងក្តី វិស័យនេះបានកាត់បន្ថយភាពក្រីក្ររហូតដល់ឆ្នាំ 2012។ និន្នាការនេះមានន័យថាសកម្មភាពសេដ្ឋកិច្ចមិនមែនកសិកម្មនៅជនបទ ដូចជាវិស័យកាត់ដេរសម្លៀកបំពាក់វិស័យសំណង់ និងសេវាកម្ម ហើយក្នុងកម្រិតទាបជាងនេះ ការបង្វែរ

8 របាយការណ៍ប្រចាំឆ្នាំ2016 និងផែនការសមរាប់ឆ្នាំ 2017 ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ថ្ងៃ 13 មករា ឆ្នាំ 2017

### ប្រអប់លេខ 1: ផលិតភាព

សារៈសំខាន់នៃផលិតភាពក្នុងសភាពជាទស្សនទានមិនអាចមើលស្រាលបានឡើយ ព្រោះផលិតភាពឆ្លុះបញ្ចាំងប្រសិទ្ធភាពដែលសេដ្ឋកិច្ចប្រែក្លាយធនធានឲ្យទៅជាផលិតផល។ ជាមួយនឹងផលិតភាពខ្ពស់ ប្រទេសមួយអាចមានកម្រិតជីវភាពរស់នៅល្អប្រសើរ។ កំណើនផលិតភាពច្រើនតែសំដៅដល់ការកើននៃផលិតផលដែលបានផលិតជាមួយកម្រិតធាតុចូលដដែលនិងក្នុងអំឡុងពេលដូចគ្នា។ ការប្រើប្រាស់ឧបករណ៍បំបែកកំណើន (វិធីសាស្រ្ត Shapley) និងប្រើប្រាស់ទិន្នន័យពីអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាកំណើនប្រចាំឆ្នាំនៃតម្លៃបន្ថែមក្នុងពលរដ្ឋម្នាក់ត្រូវបានបំបែកទៅជាបួនសមាសធាតុ ពោលគឺការរួមចំណែកដល់កំណើនផលិតភាព កំណើនឱកាសការងារ កំណើនកម្លាំងពលកម្ម និងបំរែបំរួលចំនួនប្រជាជនក្នុងវ័យធ្វើការងារពីឆ្នាំ 2007-14។

លទ្ធផលបង្ហាញថាកំណើនប្រចាំឆ្នាំនៃតម្លៃបន្ថែមក្នុងពលរដ្ឋម្នាក់ចាប់ពីឆ្នាំ 2007-14 មានភាពល្អប្រសើរ។ កំណើនផលិតភាពប្រចាំឆ្នាំស្មើ 6.0 ភាគរយត្រូវបានពិនិត្យឃើញថាជាកត្តារួមចំណែកធំជាងគេក្នុងកំណើនប្រចាំឆ្នាំនៃតម្លៃបន្ថែមក្នុងពលរដ្ឋម្នាក់ស្មើនឹង 4.2 ភាគរយ (តារាង B1)។ ប៉ុន្តែការធ្លាក់ចុះនៃអត្រាមានការងារបានទាញទម្លាក់កំណើនតម្លៃបន្ថែមក្នុងពលរដ្ឋម្នាក់ដល់ 2.8 ភាគរយ ភាគច្រើនបណ្តាលមកពីការធ្លាក់ចុះនៃអត្រាមានការងារធ្វើក្នុងវិស័យ កសិកម្ម។

1/htttp://globalpractices.worldbank.org/mfm/Pages/SitePages/MFM%20Online%20Tools.aspx

**តារាងB1:** ការបំបែកកំណើនតម្លៃបន្ថែមក្នុងពលរដ្ឋម្នាក់ (តាមវិធី Shapley) ឱកាសការងារតាមវិស័យសំខាន់ៗ ក្នុងឆ្នាំ 2007--14

| | ភាគរយ | រួមចំណែកជា% |
|---|---|---|
| កំណើនប្រចាំឆ្នាំនៃតម្លៃបន្ថែមក្នុងពលរដ្ឋម្នាក់ | 4.26 | 100% |
| បំរែបំរួលផលិតភាព | 5.99 | 141% |
| បំរែបំរួលអត្រាការងារ | -2.86 | -67% |
| កសិកម្ម | -3.69 | -87% |
| ឧស្សាហកម្ម | 0.88 | 21% |
| កសិកម្ម | -0.05 | -1% |
| បំរែបំរួលអត្រាចូលរួម | 0.32 | 8% |
| កសិកម្ម | 0.81 | 19% |

ប្រភព: ការគណនារបស់បុគ្គលិកធនាគារពិភពលោក

ប្រាក់ អាចជាកត្តារួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ និងនាំមកនូវវិបុលភាពរួមនៅកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំទៅមុខ។ ក្នុងន័យនេះ ប្រទេសកម្ពុជាមានលក្ខណៈស្រដៀងគ្នានឹងប្រទេសវៀតណាម ដែលការធ្វើពិពិធកម្មការចិញ្ចឹមជីវិតនៅតំបន់ជនបទបានរួមចំណែកយ៉ាងច្រើនក្នុងការកាត់បន្ថយភាពក្រីក្រ និងធ្វើឲ្យមានវិបុលភាពរួម។

**រូបលេខ 14: ចំណូលកសិកម្មមានត្រឹមតែ 43 ភាគរយប៉ុណ្ណោះនៃចំណូលសរុប ចំណូលជនបទ (%)**




ប្រភព: អាជ្ញាធរកម្ពុជា

## វិស័យពាណិជ្ជកម្មក្រៅប្រទេស

### a) ការនាំចេញទំនិញ

**ការនាំទំនិញចេញ ជាទូទៅនៅតែមានភាពរឹងមាំ ជាមួយនឹងកំណើន ជាបន្តនៃការនាំចេញសម្លៀកបំពាក់ និងទំនិញផ្សេងទៀត។** ការនាំចេញទំនិញ ត្រូវបានប៉ាន់ស្មានថាមានកំណើន 11 ភាគរយក្នុងឆ្នាំ 2016 ធៀបនឹងឆ្នាំមុន ស្មើនឹង 45 ភាគរយនៃ ផសស (រូបលេខ 15) នាំមុខដោយសារ ការនាំចេញសម្លៀកបំពាក់ និងស្បែកជើង ដែលបានកើនឡើង 8.4 ភាគរយ និង 14.8 ភាគរយ រៀងគ្នា។ អត្រានេះធៀបនឹងកំណើនប្រចាំឆ្នាំ 8.3 ភាគរយក្នុងឆ្នាំ 2015។ ការនាំចេញទំនិញកសិកម្ម ពិសេសការនាំចេញស្រូវ ត្រូវបានគេជឿថាមានការជំរុញដោយការបង្កើនផលិតកម្មស្រូវវស្សា ដែលបានកើនឡើង 5.3 ភាគរយធៀបនឹងឆ្នាំមុន ឬមានកំណើនជិត 0.4 លានតោនក្នុងឆ្នាំ 2016។

### ប្រអប់លេខ 1: ផលិតភាព (ត)

**ក្នុងកំណើន 6.0 ភាគរយនៃផលិតភាពក្នុងអំឡុងឆ្នាំ 2007-14 កំណើននៃផលិតភាពក្នុងវិស័យកសិកម្មរួមចំណែកធំបំផុតលំដាប់ទីពីរ បន្ទាប់ពីអចលនទ្រព្យ (តារាង B2)។** ដោយប្រើទិន្នន័យការងារតាមវិស័យ (និងអនុវិស័យ) អត្រាកំណើនផលិតភាពប្រចាំឆ្នាំលឿនបំផុត ឃើញមានក្នុងវិស័យអចលនទ្រព្យដែលបានកើនឡើងក្នុងអត្រាមធ្យមប្រចាំឆ្នាំ 2.7 ភាគរយក្នុងអំឡុងឆ្នាំ 2007-14។ កំណើននេះទំនងជាជំរុញដោយសន្ទុះវិស័យអចលនទ្រព្យក្នុងអំឡុងក្រោយវិបត្តិហិរញ្ញវត្ថុពិភពលោក។ កំណើនផលិតភាពក្នុងវិស័យកសិកម្មស្ថិតក្នុងលំដាប់បន្ទាប់ កើនឡើងជាមធ្យមក្នុងមួយឆ្នាំចំនួន 1.8 ភាគរយជាមួយនឹងបច្ចេកវិទ្យាកសិកម្មកាន់តែទំនើប និងជាមួយធាតុចូល។ កំណើនផលិតភាពលឿនបំផុតលំដាប់ទីបីស្មើ 0.7 ភាគរយគឺវិស័យពាណិជ្ជកម្ម (លក់ដុំ និងលក់រាយ)។

**តារាងលេខ B2:** ការបំបែកកំណើនតម្លៃបន្ថែមក្នុងពលរដ្ឋម្នាក់ៗ (តាមវិធីសាស្ត្រ Shapley) ការងារតាមវិស័យក្នុងអំឡុងឆ្នាំ 2007-14

| | ភាគរយ | រួមចំណែកជា% |
|---|---|---|
| កំណើនតម្លៃបន្ថែមក្នុងពលរដ្ឋម្នាក់ៗប្រចាំឆ្នាំ | 4.26 | 100% |
| បំរែបំរួលនៃផលិតភាព | 5.99 | 141% |
| កសិកម្ម | 1.87 | 44% |
| រ៉ែនិងកម្មន្តសាលផ្សេងទៀត | 0.05 | 1% |
| ទឹកភ្លើងឧទ្ទេសព្ទ(យូធីលីធី) | 0.03 | 1% |
| សម្លៀកបំពាក់ និងស្បែកជើង | 0.16 | 4% |
| សំណង់ | -0.27 | -6% |
| ពាណិជ្ជកម្ម | 0.72 | 17% |
| ដឹកជញ្ជូន និងគមនាគមន៍ | 0.31 | 7% |
| អចលនទ្រព្យ | 2.70 | 63% |
| សកម្មភាពដទៃទៀត | 0.02 | 0% |
| ឥទ្ធពលនៃបុនរិភាជន៍អន្តរវិស័យ | 0.40 | 9% |
| បំរែបំរួលអត្រាការងារ | -2.86 | -67% |
| បំរែបំរួលអត្រាចូលរួម | 0.32 | 8% |
| បំរែនៃចំណែកប្រជាជនក្នុងវ័យបំពេញការងារ | 0.81 | 19% |

ប្រភព: ការគណនារបស់បុគ្គលិកធនាគារពិភពលោក

**រូបលេខ 15: ឱនភាពពាណិជ្ជកម្មកំពុងរួមតូច នាំចេញ នាំចូល និងឱនភាពពាណិជ្ជកម្ម** (ភាគរយនៃ ផសស)




ប្រភព: អាជ្ញាធរកម្ពុជា
e = ប៉ាន់ស្មាន

## b) ចំណូលពីការបង្វែរប្រាក់របស់កម្មករ

**ប្រាក់បង្វែររបស់កម្មករនៅតែមានភាពរឹងមាំ។** ក្នុងឆ្នាំ 2016 លំហូរប្រាក់បង្វែរត្រូវបានប៉ាន់ស្មានថាបានឡើងដល់ 431 លានដុល្លារអាមេរិក[9]។ កម្មករចំណាកស្រុកកម្ពុជាមួយចំនួនធំត្រូវបានទាក់ទាញដោយប្រាក់ឈ្នួលខ្ពស់នៅប្រទេសថៃ ទន្ទឹមនឹងការរងផលអវិជ្ជមានពីការធ្លាក់ចុះនៃថ្លៃទំនិញកសិកម្ម ចំពោះផលិតកម្មកសិកម្មរបស់ពួកគេនៅឯស្រុក បានផ្ញើប្រាក់មកផ្ទះបង្កើតបានជាលំហូរប្រាក់បង្វែរ។ ការណ៍នេះបានជួយជំរុញសន្ទុះប្រាក់បង្វែរមកកាន់គ្រួសារ ពិសេសតំបន់ជនបទ ចាប់តាំងពីឆ្នាំ 2014 មក (រូបលេខ 16)។

**រូបលេខ 16: ប្រាក់បង្វែររបស់កម្មករនៅតែមានស្ថានភាពល្អល្អសើរ** (លានដុល្លារអាមេរិក)




ប្រភព: អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក
e = ប៉ាន់ស្មាន

### ប្រអប់លេខ 1: ផលិតភាព (ត)

**ការប្រៀបធៀបប្រចាំតំបន់ក៏បង្ហាញផងដែរថាកំណើនតម្លៃបន្ថែមសម្រាប់ពលរដ្ឋម្នាក់ៗប្រចាំឆ្នាំរបស់កម្ពុជាក្នុងអំឡុងឆ្នាំ 2007-14 មានកម្រិតខ្ពស់ជាបង្គួរ (តារាង B3)។** ដោយប្រើប្រភពទិន្នន័យពីសូចនាករអភិវឌ្ឍន៍ពិភពលោក កំណើនតម្លៃបន្ថែមក្នុងពលរដ្ឋម្នាក់ៗប្រចាំឆ្នាំសម្រាប់ប្រទេសឡាវ វៀតណាម ថៃ និងឥណ្ឌូនេស៊ីត្រូវបានប្រៀបធៀបជាមួយកំណើនតម្លៃបន្ថែមក្នុងពលរដ្ឋម្នាក់ៗរបស់កម្ពុជា។ ក្នុងចំណោម ប្រទេសទាំងប្រាំ ឡាវមានកំណើនតម្លៃបន្ថែមក្នុងពលរដ្ឋម្នាក់ៗប្រចាំឆ្នាំស្មើនឹង 6.1 ភាគរយ។ ទោះជាយ៉ាងណាក្តី កំណើនផលិតភាពមានត្រឹមតែ 5.1 ភាគរយ ធៀបនឹង 6.0 ភាគរយនៅកម្ពុជា។ យ៉ាងណាក្តី គួរបញ្ជាក់ថាកម្ពុជាស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍន៍ជាង បណ្តាប្រទេសគូប្រៀបធៀបភាគច្រើនលើកលែងតែប្រទេសឡាវ។

**តារាងលេខ B3:** កំណើនតម្លៃបន្ថែមក្នុងពលរដ្ឋម្នាក់ៗប្រចាំឆ្នាំ (ការប្រៀបធៀបធៀបប្រចាំតំបន់ក្នុងអំឡុងឆ្នាំ 2007-14

| | កម្ពុជា | ឡាវ/1 | វៀតណាម/2 | ថៃ/2 | ឥណ្ឌូនេស៊ី |
|---|---|---|---|---|---|
| សរុប | 4.3 | 6.1 | 2.5 | 2.9 | 3.9 |
| | | | | | |
| ផលិតភាព | 6.0 | 5.1 | 1.8 | 2.5 | 3.2 |
| អត្រាមានការងារធ្វើ | -2.9 | 0.0 | 0.0 | 0.1 | 0.5 |
| អត្រាចូលរួម | 0.3 | -0.2 | 0.2 | -0.3 | 0.0 |
| បំរែបំរួលប្រជាសាស្ត្រ | 0.8 | 1.1 | 0.6 | 0.6 | 0.3 |

ប្រភព: ការគណនារបស់បុគ្គលិកធនាគារពិភពលោក. 1/ 2007-10; 2/ 2007-13

## c) ការនាំចូលទំនិញ

**តម្រូវការនាំចូលបានថយចុះ** ដោយសារការថយចុះនៃការនាំចូលសម្ភារ:សំណង់សំខាន់ៗ ពិសេសដែកសរសៃ (និងស៊ីម៉ង់ត៍) ខណ:ដែលដំណាក់កាលបញ្ចប់នៃគម្រោងសំណង់លំនៅស្ថាន និងពាណិជ្ជកម្មទំនើបខ្ពស់ៗឈានខិតចូលមក

9 ស្ថិតិជញ្ជីងទូទាត់ ធនាគារកណ្តាល

ជិត។ បន្ថែមលើនេះ មានកំណើនកិច្ចប្រឹងប្រែងជំនួសការនាំចូល ពិសេសចំពោះផលិតផលម្ហូបអាហារ និងភេសជ្ជៈ និងស៊ីម៉ង់ត៍។ កំណើនការនាំចូលត្រូវបានប៉ាន់ស្មានថានៅមានកម្រិតប្រមាណជា 9 ភាគរយក្នុងឆ្នាំ 2016 ធៀបនឹងឆ្នាំមុនត្រូវជា 56.9 ភាគរយនៃ ផសស។

**ទោះជាយ៉ាងណាក្តី បង្ហាញឲ្យឃើញនូវការប្រើប្រាស់រឹងមាំជាបន្តចំពោះផលិតផលនាំចូលមួយចំនួន ដូចជាយានយន្ត ប្រេងម៉ាស៊ូត គ្រឿងបរោភោគបរិភោគ នៅតែមានលក្ខណៈរឹងមាំ។** ការនាំចូលយានយន្ត (មិនរាប់បញ្ចូលម៉ូតូ) នៅតែមានចំនួនច្រើន មានកំណើន 21.4 ភាគរយ (គិតជាទឹកប្រាក់) ក្នុងឆ្នាំ 2016 ធៀបនឹង 21.1 ភាគរយ ក្នុងឆ្នាំ 2015 (រូបលេខ 17)។ ការនាំចូលប្រេង ម៉ាស៊ូតបានកើនខ្ពស់ គឺកើនពី 3.0 ភាគរយ ក្នុងឆ្នាំ 2015 ដល់ 14.2 ភាគរយ ក្នុងឆ្នាំ 2016 ធៀបនឹងឆ្នាំមុន។

**រូបលេខ 17: នាំចូលយានយន្ត ប្រេងឥន្ធនៈ និងឧបភោគបរិភោគ នៅតែរឹងមាំ** (% បំរែបំរួលធៀបនឹងឆ្នាំមុន))




ប្រភព: អាជ្ញាធរកម្ពុជា

## d) គណនីចរន្ត

**ជាទូទៅ ស្ថានភាពពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជាបានប្រសើរឡើងបន្ថែមទៀត ដោយសារឱនភាពពាណិជ្ជកម្មបានរួមតូច និង មួយផ្នែកគឺដោយសារថ្លៃប្រេងឥន្ធនៈ នៅតែមានកម្រិតទាប។** ឱនភាពគណនីចរន្ត (មិនរួមបញ្ចូលបង្វែរផ្លូវការ) ដែលហិរញ្ញប្បទានជាចម្បង ពីលំហូរវិនិយោគផ្ទាល់ពីបរទេស ដែលត្រូវបានប៉ាន់ស្មានថា មានទំហំ 10.2 ភាគរយនៃ ផសស ក្នុងឆ្នាំ 2016 ធៀបនឹង 9.1ភាគរយ ក្នុងឆ្នាំ 2015។ ឱនភាពគណនីចរន្តបានប៉ាន់ស្មានថាបានថយចុះពី 10.6 ភាគរយនៅឆ្នាំ 2015 ដល់ 9.5 ភាគរយ នៃ ផសស ក្នុងឆ្នាំ 2016 (រូបលេខ 18)។

**រូបលេខ 18: វិនិយោគផ្ទាល់ពីបរទេសបំពេញឱនភាពគណនីចរន្តយ៉ាងច្រើនធ្វើឲ្យឱនភាពថយចុះជាបណ្តើរៗ** (ជាភាគរយ)




ប្រភព: អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

**លំហូរមូលធន និងគណនីចរន្តមានលក្ខណៈកាន់តែប្រសើរ បានរួមចំណែកចំពោះការបង្កើនទុនបម្រុងបរទេសដែលបានកើនឡើងដល់ 6.5 ពាន់លានដុល្លារអាមេរិក (អាចនាំចូលបាន 5.4 ខែ) កាលពីឆ្នាំមុន។** ទិដ្ឋភាពនេះកើតឡើងដោយសារទ្រព្យបរទេសសុទ្ធនៅធនាគារកណ្តាលបានកើនឡើងពី 20.4 ភាគរយក្នុងឆ្នាំ 2015 ដល់ 22.3 ភាគរយក្នុងឆ្នាំ 2016 ធៀបនឹងឆ្នាំមុន។

# អតិផរណា

**សម្ពាធអតិផរណាបានកើនឡើងដោយសារមានតម្រូវការក្នុងស្រុកច្រើននាំមុខ ដោយការប្រើប្រាស់កម្រិតគ្រួសារដោយការកើនឡើងនូវប្រាក់ឈ្នួល។** អតិផរណាបានកើនឡើងពី 2.8 ភាគរយក្នុងឆ្នាំ 2015 ដល់ 4.3 ភាគរយក្នុងខែ មីនា ឆ្នាំ 2016 ធៀបនឹងឆ្នាំមុន (រូបលេខ 19)។ សមាសភាគថ្លៃស្បៀងអាហារ ពិសេស ថ្លៃត្រី សាច់ បក្សី បន្លែ និងថ្លៃ ផ្លែឈើ បានបន្តជំរុញអតិផរណា ខណៈដែលសមាសភាគថ្លៃម្ហូបអាហារនៅភោជនីយដ្ឋាន សេវាសុខាភិបាល សង្ហារឹម និងសម្លៀកបំពាក់ (ចំណាត់ថ្នាក់ត្រង់ "ផ្សេងទៀត" ក៏បានកើនឡើងផងដែរ។ ថ្លៃប្រេងឥន្ធនៈដែលនៅតែថោកប៉ុន្តែតម្លៃប្រេងឥន្ធនៈអន្តរជាតិ ត្រូវបានសង្កេតឃើញថាកំពុងតែងើបឡើងវិញ។

រូបលេខ 19: សមាសភាគស្បៀងអាហារបន្តធ្វើឲ្យមានអតិផរណា ការរួមចំណែកធ្វើឲ្យមានអតិផរណារយៈពេល 12 ខែ (ភាគរយ)




ប្រភព: អាជ្ញាធរកម្ពុជា

រូបលេខ 21: អតិផរណាក្នុងតំបន់កើនឡើងបន្តិចម្តងៗ (ភាគរយបំរែបំរួលធៀបឆ្នាំមុន)




ប្រភព: អាជ្ញាធរកម្ពុជា និងស្ថិតិរបស់ប្រទេសដទៃ

**ការកើនឡើងនៃអតិផរណាកាលពីពេលកន្លងទៅថ្មីៗ ត្រូវបានគេជឿថា មួយផ្នែកធំ គឺបណ្តាលមកពីការកើនឡើងនូវតម្រូវការក្នុងស្រុក** ដោយសារការប្រើប្រាស់ដោយសារកំណើនប្រាក់ឈ្នួល។ ទិដ្ឋភាពនេះខុសគ្នាជាខ្លាំងពីអំឡុងពេលមានវិបត្តិថ្លៃស្បៀងអាហារ និងថ្លៃប្រេង ក្រោយពីមានវិបត្តិហិរញ្ញវត្ថុសកលនៅឆ្នាំ 2007/08 ខណៈដែលអតិផរណានាំចូល "ឆ្លងកាត់" តាមរយៈថ្លៃនាំចូលប្រេងឥន្ធនៈ និងថ្លៃគ្រឿងឧបភោគបរិភោគមកកាន់អតិផរណាក្នុងស្រុក គឺជាមូលហេតុចម្បងនៃការកើនឡើងអតិផរណាក្នុងស្រុក (រូបលេខ 20)។

រូបលេខ 20: ក្រោយវិបត្តិហិរញ្ញវត្ថុសកល សម្ពាធអតិផរណាភាគច្រើនបណ្តាលមកពីការប្រើប្រាស់ក្នុងស្រុក




ប្រភព: អាជ្ញាធរកម្ពុជា (CSES, វិទ្យាស្ថានជាតិស្ថិតិ និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

**អតិផរណាក្នុងតំបន់ក៏កើនឡើងផងដែរ (រូបលេខ 21)។** ទោះបីជាអតិផរណានៅតែត្រូវបានរំពឹងថាមានកម្រិតទាបក្នុងពេលខាងមុខ ក្តីរំពឹងអំពីអតិផរណាទំនងជាកើនឡើងដោយសារការងើបឡើងវិញនៃថ្លៃថាមពល និងថ្លៃវត្ថុធាតុដើម និងថ្លៃកសិផល។

## ទិស័យរូបិយវត្ថុ

### a) រូបិយវត្ថុសរុប អត្រាការប្រាក់ និងអត្រាប្តូរប្រាក់

**ដើម្បីគាំទ្រកំណើនសេដ្ឋកិច្ច រូបិយវត្ថុទូទៅបានកើនឡើងពី 14.7 ភាគរយក្នុងឆ្នាំ 2015 ដល់ 17.9 ភាគរយ ក្នុងឆ្នាំ 2016 ធៀបនឹងឆ្នាំមុន ដោយសារការកើនឡើងនូវប្រាក់បញ្ញើរូបិយប័ណ្ណបរទេស ដែលជំរុញដោយការមានទំនុកចិត្តកាន់តែខ្លាំងចំពោះប្រព័ន្ធធនាគារ (រូបលេខ 22)។** ទោះជាយ៉ាងណាក្តី ការរួមចំណែកពីប្រាក់បញ្ញើជាប្រាក់រៀល និងចរាចរប្រាក់រៀលចំពោះកំណើនរូបិយវត្ថុទូទៅ នៅតែមានកម្រិតទាប សឲ្យឃើញ

រូបលេខ 22: កំណើនរូបិយវត្ថុទូទៅកើនឡើងដោយសារបញ្ញើរូបិយបណ្ណបរទេស ការរួមចំណែកធ្វើឲ្យមានកំណើនរូបិយវត្ថុទូទៅ (ភាគរយ)




ប្រភព: អាជ្ញាធរកម្ពុជា

គោលនយោបាយប្រុងប្រយ័ត្នរបស់ធនាគារកណ្តាល ក្នុងការរក្សាស្ថិរភាពអត្រាប្តូរប្រាក់ដើម្បីជួយធ្វើឲ្យថ្លៃក្នុងស្រុកមានស្ថិរភាពក្នុងសេដ្ឋកិច្ចដែលប្រើប្រាស់ប្រាក់ដុល្លារច្រើន។ ចំណែកឯការកើនឡើងនូវប្រាក់បញ្ញើរូបិយប័ណ្ណបរទេសវិញ សឲ្យឃើញការកើនឡើងនូវភាពទាក់ទាញនៃវិស័យធនាគាររបស់កម្ពុជា ហើយក៏បង្ហាញអំពីកំណើននៃលំហូរមូលធនចូលមកក្នុងប្រទេសផងដែរ ។

**ទោះបីជាកំណើនឥណទានធ្លាក់ចុះ មួយផ្នែកបណ្តាលមកពីការថយចុះនៃសកម្មភាពសេដ្ឋកិច្ចក្តី អត្រាផ្តល់កម្ចី និងអត្រាប្រាក់បញ្ញើរយៈពេលខ្លី ជាប្រាក់ដុល្លារអាមេរិកបានកើនឡើង (រូបលេខ 23)។** ដោយសារសេដ្ឋកិច្ចចាយប្រាក់ដុល្លារច្រើន សេដ្ឋកិច្ចនេះរងឥទ្ធិពលជាខ្លាំងពីគោលនយោបាយរូបិយវត្ថុរបស់ធនាគារសហព័ន្ធរបស់សហរដ្ឋអាមេរិក ដែលត្រូវបានរឹតបន្តឹងកាលពីពេលថ្មីៗនេះជាមួយនឹងការដំឡើងអត្រាការប្រាក់ចំនួន 3 លើកចាប់តាំងពីចុងឆ្នាំ 2015 មក[10]។

**រូបលេខ 23: អត្រាការប្រាក់ដុល្លាររយៈពេលខ្លីបានកើនឡើងទោះបីជាកំណើនឥណទានបានធ្លាក់ចុះ**




ប្រភព: អាជ្ញាធរកម្ពុជា

**ប្រាក់រៀលបានឡើងថ្លៃកាលពីពេលថ្មីៗ ធៀបនឹងប្រាក់ដុល្លារអាមេរិក ប្រាក់បាតថៃ និងប្រាក់ដុងវៀតណាម (រូបលេខ 24)។** អត្រាប្តូរប្រាក់រៀល/ដុល្លារអាមេរិកថយពី 4,050រៀលក្នុងខែធ្នូ ឆ្នាំ 2015 ដល់ 3,990 នៅខែមីនា ឆ្នាំ 2017។ ដូចបានពន្យល់ខាងលើ វិនិយោគិនមានទំនុកចិត្តកាន់តែខ្លាំងដែលធ្វើឲ្យមានកំណើនលំហូរចូលមូលធន ចាប់តាំងពីដើមឆ្នាំ 2016 ជាមួយនឹងការកើនឡើងនូវប្រាក់បញ្ញើរូបិយប័ណ្ណបរទេស (សូមអានកិច្ចពិភាក្សាបន្ថែមអំពីលំហូចូលវិនិយោគផ្ទាល់ពីបរទេសត្រង់ផ្នែកវិស័យពាណិជ្ជកម្មក្រៅប្រទេសខាងលើ) ចំណែកឯការរួមចំណែកនៃប្រាក់រៀលក្នុងកំណើនរូបិយវត្ថុទូទៅនៅតែមានកម្រិតទាប។ ទិដ្ឋភាពនេះពន្យល់ពីមូលហេតុនៃការកើនថ្លៃប្រាក់រៀលកាលពីពេលថ្មីៗកន្លងទៅ។

**រូបលេខ 24: ប្រាក់រៀលកើនថ្លៃធៀបនឹងប្រាក់ដុល្លារអាមេរិក ប្រាក់បាតថៃ ប្រាក់ដុងវៀតណាម** សន្ទស្សន៍ប្រាក់រៀលធៀបនឹងប្រាក់ដុង ប្រាក់បាត និងប្រាក់ដុល្លារ (2005=1) និងប្រាក់រៀលក្នុងមួយដុល្លារអាមេរិក (ស្តាំ)




ប្រភព: ធនាគារកណ្តាល (កម្ពុជា និងថៃ) និងក្រសួងហិរញ្ញវត្ថុវៀតណាម

**បន្ថែមពីលើនេះ កិច្ចប្រឹងប្រែងកាលពីពេលថ្មីៗចំពោះការជំរុញការប្រើប្រាស់ប្រាក់រៀល ពីសំណាក់ធនាគារកណ្តាល អាចជួយពង្រឹងទំនុកចិត្ត លើរូបិយវត្ថុក្នុងស្រុក។** ធនាគារកណ្តាលបានកសាងសមិទ្ធផលល្អកន្លងមក ដែលរួមមានការជៀសវាងការធ្វើហិរញ្ញប្បទានពីធនាគារក្នុងស្រុក ចំពោះឱនភាពសារពើពន្ធរបស់រដ្ឋាភិបាល ហើយរក្សាបាននូវអតិផរណាកម្រិតទាបធៀបប្រទេសផ្សេងទៀត (លើកលែងតែក្នុងអំឡុងពេលមានវិបត្តិថ្លៃប្រេងឥន្ធនៈ និងថ្លៃស្បៀងអាហារ ឆ្ពោះទៅកាន់វិបត្តិហិរញ្ញវត្ថុសកលឆ្នាំ 2008-09 )។ របបអត្រាប្តូរប្រាក់ថេរនៃប្រាក់រៀលជាមួយប្រាក់ដុល្លារអាមេរិក ក៏ដូចជាការពឹងផ្អែកលើដុល្លារអាមេរិកសម្រាប់ពាណិជ្ជកម្ម និងហិរញ្ញវត្ថុ នៅតែជាកត្តាដែលនាំមកនូវដុល្លារូបនីយកម្ម[11]។ ភាពប្រកួតប្រជែងក្រៅប្រទេសរបស់កម្ពុជាត្រូវបានរំពឹងថានឹងបន្តធ្លាក់ចុះបន្ថែម

---

10 ធនាគារសហព័ន្ធរបស់សហរដ្ឋអាមេរិកដាក់ផែនការ “Fed fund rate”ជាអត្រាការប្រាក់ដែលគ្រឹះស្ថានទទួលប្រាក់បញ្ញើមួយផ្តល់ឥណទានដែលជាមូលនិធិរក្សាទុកនៅធនាគារសហព័ន្ធរបស់ខ្លួនទៅឲ្យគ្រឹះស្ថានទទួលប្រាក់បញ្ញើមួយផ្សេងក្នុងរយៈពេលខ្លី ដោយប្រើប្រតិបត្តិការទីផ្សារបើកចំហ (សម្រេចដោយ FOMC) សម្រាប់ការទិញ និងលក់មូលបត្ររតនាគារ(បណ្ណ ណូត និងសញ្ញាបណ្ណ)។ ចាប់តាំងពីឆ្នាំ 2006 មក មានការតម្លើងការប្រាក់ចំនួនបីដង: ទីមួយ បង្កើនពី 0.25-0.5 ភាគរយក្នុងមួយឆ្នាំ (20 ធ្នូ 2015) លើកទីពីរ បង្កើនដល់ 0.75 ភាគរយ (18 ធ្នូ 2016) និងលើកទីបីបង្កើនដល់ 1.0 ភាគរយ (15 មីនា 2017)។ គិតត្រឹមថ្ងៃទី 16 ខែ មីនា ឆ្នាំ 2017 អត្រា Fed fund rate សព្វថ្ងៃគឺ 0.91 ភាគរយ ចំណែកឯអត្រា Bank prime loan rate ស្មើ 4 ភាគរយ។

11 ការពង្រឹងមុខងាររបស់រូបិយវត្ថុក្នុងស្រុកនៅក្នុងបេក្ខភាពសហភាពអឺរ៉ុប និងប្រទេសមានសក្តានុពលជាបេក្ខភាពរបស់សហភាពអឺរ៉ុប សំនេរឯកសារជាស៊េរី ធនាគារកណ្តាលអឺរ៉ុប លេខ 170 ខែមេសា2016

ទៀត ប្រសិនបើកម្ពុជានៅប្រកាន់យកគោលនយោបាយអត្រាប្តូរប្រាក់ថេរ ខណៈដែលប្រាក់ដុល្លារបន្តឡើងថ្លៃ។ ការផ្តល់តម្លៃលើសដល់អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិត នៅពេលអវត្តមានរបបអត្រាប្តូរប្រាក់ឯករាជ្យតម្រូវឲ្យមានគោលនយោបាយដើម្បីបង្កើនផលិតភាព និងភាពប្រកួតប្រជែង[12]។

## b) វិស័យធនាគារ

**កំណើនឥណទានរបស់វិស័យធនាគារបានបង្អង់ល្បឿនបន្តិច ឆ្លុះបញ្ចាំងពីការថមថយខ្លះនៃសកម្មភាពសេដ្ឋកិច្ច។** វិធានការប្រុងប្រយ័ត្នផ្នែកម៉ាក្រូ ដែលទើបដាក់ឲ្យអនុវត្តដោយធនាគារកណ្តាលក៏អាចជួយពន្យឺតកំណើនឥណទានក្នុងស្រុកផងដែរ។ កំណើនឥណទានវិស័យធនាគារបានចុះថយពី 28.6 ភាគរយក្នុងឆ្នាំ 2015 មកត្រឹម 25.8 ភាគរយនៅចុងឆ្នាំ 2016 (រូបលេខ 25)។ ឥណទានដែលបានផ្តល់ឲ្យវិស័យឯកជនបានកើនឡើងពី 9.8 ពាន់លានដុល្លារ ឬ 54.7 ភាគរយនៃ ផសស នៅឆ្នាំ 2015 ដល់ 12.4 ពាន់លានដុល្លារ ឬ 62.3 ភាគរយ នៃ ផសស នៅឆ្នាំ 2016។ កំណើនទំនុកចិត្តបានទាក់ទាញប្រាក់បញ្ញើបន្ថែមពីវិស័យឯកជន ដែលបានកើនឡើងពី 16.6 ភាគរយ ក្នុងឆ្នាំ 2015 ដល់ 19.3 ភាគរយក្នុងឆ្នាំ 2016 ធៀបនឹងឆ្នាំមុន។ អនុបាតកម្ចីធៀបនឹងប្រាក់បញ្ញើនៅតែមានកម្រិតខ្ពស់ ស្មើ 100 ភាគរយ នៅចុងឆ្នាំ 2016។ អនុបាតឥណទានមិនដំណើរការចំពោះវិស័យធនាគារបានកើនឡើងបន្តិចពី 2.3 ភាគរយ ក្នុងឆ្នាំ 2015 ដល់ 2.7 ភាគរយក្នុងឆ្នាំ 2016។ ទោះជាយ៉ាងណាក្តី គប្បីប្រយ័ត្នប្រយែងក្នុងការបកស្រាយអនុបាតឥណទានមិនដំណើរការ ព្រោះថាភាពមិនស៊ីសង្វាក់គ្នាក្នុងការធ្វើចំណាត់ថ្នាក់ឥណទាន និងការបន្តបង្វិលឥណទានជាបន្តបន្ទាប់អាចលាក់បាំងបញ្ហាកាន់តែធ្ងន់ធ្ងរឡើងៗ។

**គួរឲ្យកត់សម្គាល់ដែរថាមានការប្តូរវិភាជន៍ឥណទានក្នុងស្រុកទៅកាន់វិស័យមិនមែនសម្រាប់នាំចេញ ដូចជា វិស័យសំណង់ និងពាណិជ្ជកម្មលក់រាយ និងចេញពីវិស័យនាំចេញ ដូចជា អាជីវកម្មទាក់ទងនឹងទេសចរណ៍ និងកម្មន្តសាល (រូបលេខ 26)។** និន្នាការនេះអាចឆ្លុះបញ្ចាំងមួយផ្នែកនូវការកើនថ្លៃប្រាក់ដុល្លារអាមេរិក ដែលធ្វើឲ្យប៉ះពាល់ដល់ភាពប្រកួតប្រជែងនៃវិស័យនាំចេញចម្បង ពោលគឺ វិស័យកាត់ដេរសម្លៀកបំពាក់ និងវិស័យទេសចរណ៍។ ជាលទ្ធផល វិនិយោគិន និងផលិតករអាចនឹងប្តូរទិសវិនិយោគទៅកាន់វិស័យមិនមែននាំចេញ និងសេវាកម្មបម្រើឲ្យតម្រូវការក្នុងស្រុកជាជាងសម្រាប់វិស័យនាំចេញ។ ដោយសារកម្ពុជាមានទីផ្សារតូច ការប្តូរទិសនេះមិនមែនជាសញ្ញាល្អសម្រាប់ធ្វើឲ្យសេដ្ឋកិច្ចមានកំណើនខ្ពស់ដោយចីរភាពឡើយ។

**រូបលេខ 25: កំណើនឥណទានបានធ្លាក់ចុះចាប់តាំងពីពាក់កណ្តាលឆ្នាំ 2016 ចំណែកឯប្រាក់បញ្ញើនៅតែមានកំណើនរឹងមាំ** (បម្រែបម្រួលជា% ធៀបនឹងឆ្នាំមុន)




ប្រភព: អាជ្ញាធរកម្ពុជា

**រូបលេខ 26: ចំណែកឥណទានផ្តល់ឲ្យវិស័យសំណង់បានកើនឡើងផ្ទុយទៅវិញចំណែកឥណទានផ្តល់ឲ្យវិស័យកម្មន្តសាល និងអាជីវកម្មពាក់ព័ន្ធនឹងវិស័យទេសចរណ៍បានធ្លាក់ចុះ** (% នៃឥណទានសរុប)




ប្រភព: អាជ្ញាធរកម្ពុជា

[12] 2016 IMF Article IV staff report

### c) មីក្រូហិរញ្ញវត្ថុ

**បន្ទាប់ពីការកើនឡើងយ៉ាងលឿន អស់រយៈពេលប៉ុន្មានឆ្នាំមក កំណើនឥណទានដែលបានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ក្លាយជានៅទ្រឹងក្នុងឆ្នាំ 2016។** កំណើនឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើបានកើនឡើងខ្ពស់បំផុតក្នុងឆ្នាំ 2014 ក្នុងអត្រាខ្ពស់ជាង 50 ភាគរយធៀបនឹងឆ្នាំកន្លងទៅ (រូបលេខ 27) ប៉ុន្តែបន្ទាប់ត្រូវបានបង្អាក់ជាបន្ទាន់ក្នុងឆ្នាំ 2016។ ឥណទានដែលផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ បានកើនដល់កម្រិតខ្ពស់បំផុតក្នុងខែមីនា ឆ្នាំ 2016 នៅពេលដែលឥណទាននេះឡើងដល់ 3.3 ពាន់លានដុល្លារអាមេរិក ឬទំហំស្មើនឹង 16.7 ភាគរយ នៃ ផសស ប៉ុន្តែបានធ្លាក់ចុះចាប់តាំងពីពេលនោះមក[13]។ នៅខែ វិច្ឆិកា ឆ្នាំ 2016 ឥណទាននោះបានធ្លាក់ចុះមកត្រឹម 3.1 ពាន់លានដុល្លារអាមេរិក ឬស្មើនឹង 15.5 ភាគរយនៃ ផសស។ គួរគូសបញ្ជាក់ថាទីផ្សារឥណទានមីក្រូហិរញ្ញវត្ថុមានលក្ខណៈប្រមូលផ្តុំ និងគ្រប់គ្រងដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមួយចំនួនតូចតែប៉ុណ្ណោះ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន 12 ធំជាងគេគ្របដណ្តប់ទីផ្សារមីក្រូហិរញ្ញវត្ថុចំនួន 98 ភាគរយ បើគិតពីទំហំផលបត្រឥណទាន និង 97 ភាគរយ បើគិតពីចំនួនអ្នកខ្ចី[14]។

**រូបលេខ 27: ឥណទានក្នុងស្រុកដែលផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ/ទទួលប្រាក់បញ្ញើបានធ្លាក់ចុះភ្លាមៗ ផ្ទុយទៅវិញអត្រាការប្រាក់បានកើនឡើង**




ប្រភព: អាជ្ញាធរកម្ពុជា

**ចំនួនគ្រួសារដែលបានប្រើប្រាស់សេវា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើក៏បានធ្លាក់ចុះផងដែរ គឺពី 2.19 លានគ្រួសារក្នុងឆ្នាំ 2015 មកត្រឹម 2.14 លានគ្រួសារ ក្នុងឆ្នាំ 2016។** អនុបាតឥណទានមិនដំណើរការចំពោះវិស័យមីក្រូហិរញ្ញវត្ថុបានកើនឡើងពី 0.7 ភាគរយ ក្នុងឆ្នាំ 2015 ដល់ 1.5 ភាគរយ ក្នុងឆ្នាំ 2016 ។ ក្នុងបរិយាកាសមានការកើនឡើងឥណទានឆាប់រហ័ស ដូចករណីកម្ពុជាក្នុងរយៈពេលប្រាំមួយឆ្នាំកន្លងមក គុណភាពនៃផលបត្រ ច្រើនតែបាំងបិទដោយល្បឿនផលបត្រដែលកំពុងកើនឡើង។ ក្នុងករណីដែលសេដ្ឋកិច្ចមានវិបត្តិ ឬមានការធ្លាក់ចុះក្នុងខ្លាំងតែប៉ុណ្ណោះ ទើបបញ្ហាដូចជា មានអ្នកខ្ចីប្រាក់ជាច្រើននាក់យកកម្ចីថ្មី ទៅសងបំណុលចាស់ ជាដើម អាចមើលឃើញច្បាស់។

**ការយល់ដឹងឲ្យបានប្រាកដអំពីមូលហេតុ ពីក្រោយភាពទ្រឹងនៃកំណើននៃឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើត្រូវការពេលវេលាបន្ថែមទៀត។** ការសង្កេតមើលជំហានបឋមបង្ហាញថាមានការប្រកួតប្រជែងកាន់តែខ្លាំងពីសំណាក់ប្រតិបត្តិករ មីក្រូហិរញ្ញវត្ថុមិនរៀបរយដែលមានចំនួនកាន់តែច្រើនក្នុងការផ្តល់ឥណទានរាប់ទាំងអ្នកចងការប្រាក់ឯកជនផងដែរ។ នៅពេលដែលការប្រកួតប្រជែងកាន់តែតានតឹង លក្ខណៈវិនិច្ឆ័យក្នុងការបានទទួលប្រាក់កម្ចី ក៏ប្រែទៅជាធូររលុង ពិសេសគឺពីសំណាក់អ្នករកស៊ីចងការប្រាក់ក្រៅប្រព័ន្ធ និងមិនរៀបរយ។ ហេតុនេះ គ្រួសារជាច្រើនទំនងជាពឹងផ្អែកលើអ្នករកស៊ីចងការប្រាក់កាន់តែខ្លាំងឡើងក្នុងការបានទទួលសាច់ប្រាក់ឆាប់រហ័ស ដោយពុំចាំបាច់មានវត្ថុបញ្ចាំ ដើម្បីសងប្រាក់កម្ចីចាស់ ក៏ដូចជាយកទៅចំណាយលើថ្នាំពេទ្យ ឬយកទៅជួសជុលផ្ទះសម្បែង[15]។ ទោះជាយ៉ាងណាក្តី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមួយចំនួនបានភ្ជាប់ភាពទ្រឹងនៃតម្រូវការទាបចំពោះឥណទានពីសំណាក់កសិករ និងពីពាណិជ្ជករក្រៅប្រព័ន្ធ ដែលរងផលប៉ះពាល់ជាអវិជ្ជមានដោយការលំបាកក្នុងការនាំចេញទំនិញកសិផល (ក្រៅផ្លូវការ) ទៅកាន់បណ្តាប្រទេសជិតខាង ទៅនឹងការបន្ធ្លាក់ថ្លៃទំនិញកសិផល។ របាយការណ៍មួយចំនួនក៏បានភ្ជាប់ការធ្លាក់ចុះការផ្តល់ឥណទានពីសំណាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើទៅនឹងភាពឆ្អែតរបស់ទីផ្សារ

13 កំណើនខ្ពស់នេះ មួយផ្នែកបណ្តាលមកពីការធ្វើចំណាត់ថ្នាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមួយក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើនានា ឲ្យក្លាយទៅជាធនាគារពាណិជ្ជ។

14 សូមអានបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជាខែមេសាឆ្នាំ2016 ចំពោះការពិភាក្សាលម្អិតអំពីវិស័យមីក្រូហិរញ្ញវត្ថុ

15 អង្កេតសេដ្ឋកិច្ច---- សង្គមកិច្ចកម្ពុជា ឆ្នាំ 2015 ខែតុលាឆ្នាំ 2016 វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ.

ផងដែរ[16]។ ការកំហិតអត្រាការប្រាក់ដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ/គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសំណាក់អាជ្ញាធរពាក់ព័ន្ធនាខែមីនាឆ្នាំ2017ហើយមានប្រសិទ្ធភាពចាប់តាំងពីថ្ងៃ 1 ខែ មេសា ឆ្នាំ 2017 ក៏អាចកាត់បន្ថយកំណើនឥណទានផងដែរ (សូមអានផ្នែកបន្ទាប់)។

### d) ភាពជំពាក់បំណុល

**ក្នុងខែមីនា ឆ្នាំ 2017 ធនាគារកណ្តាលបានចេញប្រកាសមួយដាក់ឲ្យអនុវត្តអំពីអត្រាការប្រាក់ពិតាន ចំពោះការផ្តល់ឥណទាន ក្នុងកម្រិត 18 ភាគរយ ក្នុងមួយឆ្នាំ ដែលចូលជាធរមានកាលពីថ្ងៃទី 1 ខែ មេសា ឆ្នាំ 2017 ចំពោះឥណទានដែលផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ក្រោមការត្រួតពិនិត្យរបស់ធនាគារកណ្តាល**[17]។ គោលបំណងនៃគោលនយោបាយកំណត់អត្រាការប្រាក់ពិតានចំពោះការផ្តល់ឥណទាន គឺដើម្បីបន្ថយការប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដែលបានទទួលអាជ្ញាបណ្ណពីធនាគារកណ្តាល។ ថ្លៃទាបជាងមុននេះនៃការខ្ចីប្រាក់នឹងអាចជួយជម្រុញសកម្មភាពកសិកម្ម ទាក់ទាញវិនិយោគ និងពង្រីកការផលិតក្នុងស្រុក ពុំនោះសោត មិនអាចទៅរួចឡើយ ពិសេសចំពោះកសិករក្រីក្រ និងអាជីវករខ្នាតតូច។ គោលនយោបាយនេះក៏អាចជាការព្យាយាមក្នុងការបន្ទុចបង្អាក់ទម្លាប់ឲ្យខ្ចីដែលមិនបានគិតមុខគិតក្រោយ និងទប់ស្កាត់ការឡើងកំដៅហួសកំរិត ដែលអាចកើតក្នុងទីផ្សារឥណទានអតិថិជនផងដែរ (សូមអានកិច្ចពិភាក្សាខាងក្រោមស្តីពីការប្រើប្រាស់ចំណូលបានមកពីប្រាក់កម្ចីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ)។

**ទោះជាយ៉ាងណាក្តី គេមិនដឹងច្បាស់ទេថាតើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដែលមានអាជ្ញាបណ្ណប៉ុន្មានមានសមត្ថភាពផ្តល់ឥណទានត្រឹមឬក្រោមកម្រិតអត្រាការប្រាក់ពិតាន។** ប្រសិនបើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើជាច្រើនមិនអាចទម្លាក់ការប្រាក់របស់ខ្លួនទេនោះ គោលនយោបាយនេះនឹងអាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះការផ្តល់ឥណទានថ្មីរបស់ពួកគេ (លើកលែងតែគ្រឹះស្ថានទាំងនោះ យកថ្លៃសេវាមិនទាក់ទងនឹងការប្រាក់ ដើម្បីប៉ះប៉ូវទៅនឹងអត្រាពិតាន)។ ហេតុនេះគោលនយោបាយនេះអាចបង្ខំឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទទួលប្រាក់បញ្ញើបោះបង់ទីផ្សារ មីក្រូហិរញ្ញវត្ថុ ប៉ុន្តែជំរុញឲ្យមានការរីកដុះដាលនូវអ្នករកស៊ីចងការឯកជន និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុគ្មានអាជ្ញាបណ្ណ ដែលពុំបានផ្តល់ឥណទានប្រកបដោយការទទួលខុសត្រូវនោះឡើយ។ ប្រសិនបើមានទិដ្ឋភាពនេះ គោលនយោបាយកំណត់អត្រាការប្រាក់ពិតាន មិនអាចផ្តល់ការការពារអ្នកខ្ចីប្រាក់ក្រីក្រនៅជនបទ និងផលប្រយោជន៍របស់ពួកគេដូចការរំពឹងទុកបានឡើយ ។ បន្ថែមពីលើនេះ គោលនយោបាយអត្រាការប្រាក់ពិតាន នឹងផាត់ចេញនូវធនាគារពាណិជ្ជដែលឈានមុខក្នុងការផ្តល់ឥណទានមីក្រូហិរញ្ញវត្ថុ។

**លទ្ធផលនៃអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ឆ្នាំ 2015 (CSES) បង្ហាញថាឥណទានដែលផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល ដែលអាចរួមមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ មានត្រឹមតែ 20 ភាគរយ នៃទឹកប្រាក់កម្ចីសរុបរបស់គ្រួសារទាំងអស់ប៉ុណ្ណោះ ក្នុងឆ្នាំ 2015** ចំណែកឯឥណទានដែលផ្តល់ធនាគារមានចំណែកធំបំផុត ស្ទើរតែជិត 60 ភាគរយ (រូបលេខ 28)។ ប្រការនេះអាចកំហិតផលប៉ះពាល់នៃប្រកាសខែមីនា ឆ្នាំ 2017 ស្តីពីអត្រាការប្រាក់ពិតានលើការផ្តល់ឥណទាន ដែលអនុវត្តសម្រាប់តែគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើទាំងឡាយណា ដែលបានទទួលអាជ្ញាបណ្ណពីធនាគារកណ្តាលតែប៉ុណ្ណោះ។ អត្រាការប្រាក់មធ្យមដែលបង់ដោយ

**រូបលេខ 28: ការប្រើប្រាស់ឥណទានធនាគារបានកើនឡើងយ៉ាងឆាប់រហ័សជំនួសឥណទានផ្តល់ដោយ NGOs /MFIs/MDIs/ អ្នករកស៊ីចងការឯកជន** (ភាគរយនៃឥណទានសរុប)



ប្រភព: អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា

16 សូមអាន MIMOSA, 2016 “Microfinance Index of Market Outreach and Saturation: Cambodia”, MIMOSA Project, May 2016 interim update.

17 ប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី 13 ខែមីនា ឆ្នាំ 2017

គ្រួសារនានានៅកម្ពុជាស្មើនឹង 2.4 ភាគរយ ក្នុងមួយខែ (ឬ 32.9 ភាគរយ ក្នុងមួយឆ្នាំ) ទោះបីជាគ្រួសារប្រើប្រាស់ឥណទានធនាគារកាន់តែច្រើន ស្របពេលបន្ថយការពឹងផ្អែកលើអ្នករកស៊ីចងការប្រាក់។

ទោះជាយ៉ាងណាក្តី អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ 2015 មិនបានបញ្ជាក់ទំហំនៃឥណទានដែលផ្តល់ដោយគ្រឹះស្ថានមីក្រូ-ហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដែលមានអាជ្ញាបណ្ណពីធនាគារកណ្តាលលើតួលេខឥណទានសរុបនោះឡើយ ជាហេតុធ្វើឲ្យមានលំបាកក្នុងការកំណត់ផលប៉ះពាល់ដែលអាចកើតមាន បណ្តាលមកពីការដាក់ឲ្យមានអត្រាប្រាក់ពិតានថ្មី។

**គ្រួសារជនបទទំនងជាប្រឈមការលំបាកក្នុងការខ្ចីប្រាក់ជាងគេ** ដោយសារពួកគេបង់អត្រាការប្រាក់ខ្ពស់បំផុតស្មើនឹង 2.5 ភាគរយ ក្នុងមួយខែ (ឬ 34.5 ភាគរយក្នុងមួយឆ្នាំ) ធៀបនឹង 2.1 ភាគរយក្នុងមួយខែ (ឬ 2.3 ភាគរយក្នុងមួយឆ្នាំ) បង់ដោយគ្រួសារនៅតំបន់ទីប្រជុំជនឯទៀត (និង 2.4 ភាគរយ ក្នុងមួយខែ បង់ដោយគ្រួសារនៅភ្នំពេញ)។

**គ្រួសារជាប់បំណុលនៅជនបទស្មើនឹង 80 ភាគរយ នៃចំនួនអ្នកជាប់បំណុលសរុបនៅកម្ពុជាចំនួន 1.25 លានគ្រួសារក្នុងឆ្នាំ 2015** (រូបលេខ 29) ឡើងពីចំនួន 80 ភាគរយ ក្នុងឆ្នាំ 2009។ ក្នុងរយៈពេលដូចគ្នា អត្រាការប្រើប្រាស់ឥណទានដោយគ្រួសារជនបទសម្រាប់ការងារផលិតកម្ម ដែលអាចរួមមានផលិតកម្មដែលត្រូវបានចាត់ថ្នាក់ជា "សកម្មភាពកសិកម្ម" និង "សកម្មភាពមិនមែនកសិកម្ម" បានធ្លាក់ចុះពី 38.3 ភាគរយ មកត្រឹម 32 ភាគរយ។ ទំហំឥណទានមធ្យមបានកើនឡើងលើសបួនដងច្រើនជាងអត្រាកំណើននៃប្រាក់ចំណូលជាតិដុលសម្រាប់ពលរដ្ឋម្នាក់ក្នុងរយៈពេលដូចគ្នា[18]។ ការកើនឡើងនូវការប្រើប្រាស់ដោយសារកំណើនក្នុងការទទួលបានឥណទានក្នុងស្រុក ក៏បានរួមចំណែក ក្នុងការធ្វើឲ្យមានសម្ពាធអតិផរណាកើនឡើងជាបន្តកាលពីពេលថ្មីៗដូចដែលយើងបានកត់សម្គាល់រួចមកហើយដែរ។

**ភាពជំពាក់បំណុលបានកើនឡើងខ្ពស់ចាប់តាំងពីឆ្នាំ 2010 ពិសេសសម្រាប់គ្រួសារជនបទ (រូបលេខ 30)។** ចំនួនទឹកប្រាក់បំណុលជាមធ្យមសម្រាប់មួយគ្រួសារ គិតជាភាគរយ នៃប្រាក់ចំណូលក្រោយពន្ធប្រចាំឆ្នាំនៅតំបន់ជនបទ មាននិន្នាការកើនឡើង កើនដល់ 29 ភាគរយ នៃប្រាក់ចំណូលប្រចាំឆ្នាំរបស់ពួកគេ ក្នុងឆ្នាំ 2015 លើកលែងតែក្នុងឆ្នាំ 2013 នៅពេលដែលទឹកប្រាក់បំណុលនោះឡើងខ្ពស់បំផុតដល់ 30 ភាគរយ។[19] ការកើនឡើងនូវភាពជាប់ជំពាក់បំណុលក៏អាចបណ្តាលមកពីការបង្កើនយ៉ាងឆាប់រហ័សនូវផលិតផល និងសេវាហិរញ្ញវត្ថុផងដែរ។ ចំណុចនេះ រួមមាន ភតិសន្យា(ការជួល) ដែលសព្វថ្ងៃគ្របដណ្តប់ទំនិញប្រើប្រាស់បានយូរ ដូចជា យានយន្ត គ្រឿងចក្រ សម្ភារៈបរិក្ខារ ទូរស័ព្ទទំនើប។ល។ ដែលផ្តល់ដោយ

**រូបលេខ 29: ចំណែកគ្រួសារជាប់បំណុលតាមក្របខណ្ឌភូមិសាស្ត្រ** (ពាន់គ្រួសារ ឆ្នាំ 2015)




ប្រភព: អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ 2015

**រូបលេខ 30: ភាពជំពាក់បំណុលរបស់គ្រួសារកំពុងកើនឡើងក្នុងចំណោមគ្រួសារជនបទ កម្ពីពុំទាន់សង** (ភាគរយនៃចំណូលក្រោយកកាត់ពន្ធប្រចាំឆ្នាំ)




ប្រភព: អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច

18 របាយការណ៍ MIMOSA Cambodia, ខែ មិថុនា ឆ្នាំ 2016

19 ចំណូលប្រចាំឆ្នាំ និងចំនួនឥណទានត្រូវបានរាយការណ៍នៅក្នុងអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ 2015(CSES)។ មានភាពខុសគ្នារវាងបរិមាណទឹកប្រាក់ឥណទាននៅក្នុង CSES 2015 និងតួលេខរបស់ធនាគារកណ្តាល។

វិស័យធនាគារ និងមិនមែនធនាគារ ក្នុងការទាញផលពីការកើនឡើងនូវតម្រូវការក្នុងស្រុក ដែលមួយផ្នែកជំរុញដោយសន្ទុះរីកចម្រើននៃវិស័យសំណង់ និងវិស័យអចលនទ្រព្យ។

## វិស័យសារពើពន្ធ

### a) ចំណូលក្នុងស្រុក

**ខណៈដែលការប្រមូលចំណូលនៅតែមានភាពរឹងមាំ អនុបាតចំណូលធៀបនឹង ផសស កំពុងស្ថិតនៅទ្រឹង បន្ទាប់ពីបានកើនឡើងយ៉ាងឆាប់រហ័សក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ (រូបលេខ 31)។** ការប្រមូលពន្ធផ្ទាល់ និងពន្ធមិនផ្ទាល់នៅរក្សាភាពរឹងមាំ ចំណែកឯការប្រមូលចំណូលមិនមែនពន្ធបានធ្លាក់ចុះក្នុងឆ្នាំ 2016 ។ ការប្រមូលចំណូលបច្ចុប្បន្នជារួម គិតជាភាគរយនៃ ផសស ស្ថិតក្នុងសភាពទ្រឹង។ នេះមិនមែនអ្វីគួរឲ្យភ្ញាក់ផ្អើលឡើយ នៅពេលដែលអនុបាតចំណូលធៀបនឹង ផសស បានកើនឡើងយ៉ាងឆាប់រហ័សក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅ ដោយសារការលើកកម្ពស់ការគ្រប់គ្រង និងការអនុវត្តយុទ្ធសាស្ត្រកៀរគរ ចំណូលឆ្នាំ 2014-18 ការកើនឡើងនៃការនាំចូល និងការប្រើប្រាស់ក្នុងស្រុក។ ចំណូលក្នុងស្រុកត្រូវបានប៉ាន់ស្មានថាមានកម្រិតស្មើនឹង 18.5 ភាគរយ នៃ ផសស ធៀបនឹង 18.7 ភាគរយ នៃ ផសស ក្នុងឆ្នាំ 2015 មូលហេតុចម្បងគឺ បណ្ដាលមកពីការធ្លាក់ចុះនូវចំណូលមិនមែនពន្ធ អស់ទំហំ 0.8 ភាគរយ នៃ ផសស មកត្រឹម 2.2 ភាគរយ នៃ ផសស ក្នុងឆ្នាំ 2016។

**ការកើនឡើងនូវការនាំចូលកាលពីពេលថ្មីៗដើម្បីប្រើប្រាស់ក្នុងវិស័យសំណង់ និងការរីកចម្រើនដ៏ឆាប់រហ័សនៃ វិស័យអចលនទ្រព្យ បានទ្រទ្រង់ចំណូលគយ។** ការកើនឡើងនូវការផលិត និងការប្រើប្រាស់ក្នុងស្រុក បានបង្កើនការប្រមូលពន្ធក្នុងស្រុក។ សព្វថ្ងៃ ការប្រមូលចំណូលមិនមែនពន្ធ ជាចម្បងគឺកម្រៃប៉ាតង់ ការចែករំលែកចំណូល និងប្រាក់កម្រៃសេវាផ្សេងៗ ដែលកើនឡើងមួយផ្នែកធំតាមរយៈការដាក់ឲ្យប្រើប្រព័ន្ធវិក្កយបត្រស្តង់ដារ និងប្រកាសអន្តរស្ថាប័នបានធ្លាក់ចុះ។

**ចំណូលរួមគ្នារវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ជាមួយនឹងអគ្គនាយកដ្ឋានពន្ធដារមានចំនួនប្រមាណជា 80ភាគរយនៃការប្រមូលចំណូលសរុប (រូបលេខ 32)។** ការបង្កើនការប្រមូលចំណូល ពីសំណាក់ស្ថាប័នប្រមូលចំណូលសំខាន់ៗ រួមមាន អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារបន្តទ្រទ្រង់ការអនុវត្តចំណូល។ ខណៈដែលអគ្គនាយកដ្ឋានគយនិងរដ្ឋាករ នៅតែជាស្ថាប័នប្រមូលចំណូលបានច្រើនជាងគេ បានប្រមូលពន្ធគយលើស 40 ភាគរយនៃការប្រមូលចំណូលសរុប អគ្គនាយកដ្ឋានពន្ធដារកំពុងតាមប្រកៀកប្រកិតពោលគឺប្រមូលបាន 36 ភាគរយនៃចំណូលសរុបក្នុងឆ្នាំ 2016 ធៀបនឹងត្រឹមតែ 31 ភាគរយ ក្នុងឆ្នាំ 2009។ ក្នុងរយៈពេលដូចគ្នា ការកើនឡើងចំណូលពីពន្ធផ្ទាល់ កើនឡើងពី 1.7 ភាគរយ នៃ ផសស ដល់ 3.8 ភាគរយ នៃ ផសស ក្នុងឆ្នាំ 2016 គឺជាលទ្ធផលគួរឲ្យលើកទឹកចិត្តមួយខណៈដែលកម្ពុជាសន្យាកាត់បន្ថយពន្ធនាំចូលជាបណ្ដើរៗតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន។

**រូបលេខ 31: ក្នុងពេលនៅមានភាពរឹងមាំ ការប្រមូលចំណូលហាក់ដូចជានៅទ្រឹង គិតជាភាគរយនៃ ផសស**




ប្រភព: អាជ្ញាធរកម្ពុជា

**រូបលេខ 32: អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារ នៅតែជាអង្គភាពប្រមូលចំណូលចម្បងដែលចំណូលទាំងពីរអង្គភាពស្មើនឹង 80 ភាគរយនៃការប្រមូលចំណូលសរុប** (ភាគរយ)




ប្រភព: អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

## b) ចំណាយសាធារណៈ

**នយោបាយបង្កើនសារពើពន្ធបានចាប់ផ្តើមក្នុងឆ្នាំ 2016 បន្ទាប់ពីការពង្រឹងសារពើពន្ធអស់រយៈពេលច្រើនឆ្នាំ (រូបលេខ 33)។** ក្នុងឆ្នាំ 2016 ចំណាយសាធារណៈត្រូវបានប៉ាន់ស្មានថាបានកើនឡើង 21.5 ភាគរយ នៃ ផសស ធៀបនឹង 20.5 ភាគរយ នៃ ផសស ក្នុងឆ្នាំ 2015។ ការកើនឡើងនេះមួយផ្នែកធំគឺដោយសារការបង្កើនបៀវត្សនៃវិស័យសាធារណៈ ជាមួយនឹងផែនការបង្កើនប្រាក់ខែមន្ត្រីរាជការយ៉ាងតិចឲ្យឡើងដល់ 1 លានរៀល (សមមូលនឹង 250 ដុល្លារអាមេរិក) ក្នុងមួយខែ នៅត្រឹមឆ្នាំ 2018។ ជាមួយគ្នានោះ ចំណាយវិនិយោគមូលធនសរុបមាននិន្នាការថយចុះ ដោយសារការធ្លាក់ចុះជាបណ្តើរៗនៃផ្នែកមូលនិធិផ្តល់ដោយដៃគូអភិវឌ្ឍន៍ គិតជាភាគរយ នៃ ផសស។

**រូបលេខ 33: ប្រាក់ខែកើនឡើង ប៉ុន្តែវិនិយោគមូលធនធ្លាក់ចុះក្រោមផែនការរបស់ ផយអជ** (ភាគរយនៃ ផសស)




ប្រភព: អាជ្ញាធរកម្ពុជា
សំគាល់: e = ប៉ាន់ស្មាន; b = ថវិកា

**ប្រាក់បៀវត្សនៃវិស័យសាធារណៈ ត្រូវបានប៉ាន់ស្មានថាបានកើនឡើងពី 4 ភាគរយនៃ ផសស ក្នុងឆ្នាំ 2011 ដល់ 7.4 ភាគរយនៃ ផសស ក្នុងឆ្នាំ 2016 រីឯក្នុងអំឡុងពេលដូចគ្នា ចំណាយវិនិយោគមូលធនសាធារណៈ បានធ្លាក់ចុះពី 10.8 ភាគរយនៃ ផសស មកត្រឹម 7.1 ភាគរយ នៃ ផសស**[20]។ ទោះបីជាការកើនឡើងនូវការប្រមូលចំណូល អនុញ្ញាតឲ្យបង្កើនប្រាក់បៀវត្សនៃវិស័យសាធារណៈក្តី ការធ្លាក់ចុះបណ្តើរៗនៃចំណាយមូលធននាពេលថ្មីៗនេះ ពុំមែនជាសញ្ញាល្អសម្រាប់ការបង្កើនភាពប្រកួតប្រជែង និងការរក្សាកំណើនសេដ្ឋកិច្ចឲ្យស្ថិតក្នុងកំរិតខ្ពស់នោះទេ។

មូលហេតុចម្បងនៃនិន្នាការធ្លាក់ចុះនេះ បណ្តាលមកពីការកាត់បន្ថយវិនិយោគមូលធនរបស់ដៃគូអភិវឌ្ឍន៍។ ការបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ជាសេចក្តីត្រូវការចាំបាច់ ដើម្បីបង្កើនលទ្ធផល ទាំងតាមរយៈការជំរុញបង្កើនតម្រូវការសរុបក្នុងរយៈពេលខ្លី និងតាមរយៈការពង្រីកសមត្ថភាពផលិតនៃសេដ្ឋកិច្ច ជាមួយនឹងស្តុកហេដ្ឋារចនាសម្ព័ន្ធដែលខ្ពស់ជាងមុនក្នុងរយៈពេលវែង។

**តារាងលេខ 1:** ចំណាយវិនិយោគមូលធនមាននិន្នាការធ្លាក់ចុះ និងទាបជាងកម្រិត ផយអជ តម្រូវ (ភាគរយនៃ ផសស)

| | 2014 | 2015 | 2016e | 2017b | 2018f |
|---|---|---|---|---|---|
| **ផយអជ** | 7.5 | 7.4 | 7.6 | 7.6 | 7.3 |
| ក្នុងស្រុក | 1.8 | 1.8 | 1.9 | 1.9 | 1.7 |
| បរទេស | 5.7 | 5.6 | 5.7 | 5.7 | 5.6 |
| **ជាក់ស្តែង** | 8.2 | 7.8 | 7.1 | 7.2 | 7.0 |
| ក្នុងស្រុក | 1.9 | 2.6 | 2.4 | 2.4 | 2.4 |
| បរទេស | 6.3 | 5.2 | 4.7 | 4.8 | 4.6 |

ប្រភព: ផយអជ 2014-18 និងការប៉ាន់ស្មាន និងចំណោលរបស់បុគ្គលិកធនាគារពិភព
សំគាល់: e = ប៉ាន់ស្មាន; b = ថវិកា; f = ព្យាករណ៍

**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ (ផយអជ) 2014-2018 កំណត់ផែនការចំណាយវិនិយោគមូលធនប្រមាណជា 7.6 ភាគរយនៃ ផសស ដើម្បីឲ្យមានកំណើនប្រហែល 7 ភាគរយ។** ទោះជាយ៉ាងនេះក្តី ចំណាយវិនិយោគជាក់ស្តែងបានថយចុះមកត្រឹម 7.1 ភាគរយនៃ ផសស ក្នុងឆ្នាំ 2016 (តារាងលេខ 1)។ ក្នុងបរិបទនៃការធ្លាក់ចុះថវិកាមូលធន ដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍ ដែល ផយអជ មិនបានប្រមើលឃើញនោះ ការបង្កើនចំណាយមូលធនរបស់រដ្ឋាភិបាល ដើម្បីជំរុញការវិនិយោគនាំមកនូវកំណើនផ្តល់អត្ថប្រយោជន៍ដល់ពលរដ្ឋក្រីក្រ ជាពិសេសការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធបវន្តគឺជាការចាំបាច់។ ទោះជាយ៉ាងណាក្តី ការលើកកម្ពស់ក្របខណ្ឌគតិយុត្តចំពោះការគ្រប់គ្រងវិនិយោគសាធារណៈ និងការកសាងសមត្ថភាពនៅតាម

20 តារាង 5.1 វិនិយោគមូលធនដែលត្រូវការដើម្បីសម្រេចផែនការកំណើន ផសស និងប្រភពសក្តានុពលនៃហិរញ្ញប្បទានសម្រាប់តម្រូវការវិនិយោគ: ផយអជ 2014-18 រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងសំខាន់ៗ និងនៅតាមក្រសួងពាក់ព័ន្ធគឺជាសេចក្តីចាំបាច់បំផុត ដែលជាបុរេលក្ខខណ្ឌមួយសម្រាប់បង្កើនប្រសិទ្ធភាពវិនិយោគ។ សម្រាប់ព័តមានលម្អិតបន្ថែមស្តីពីការគ្រប់គ្រងវិនិយោគសាធារណៈ សូមអានប្រធានបទជ្រើសរើសស្តីពី "ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ"។

## c) តុល្យភាពសារពើពន្ធ

**ក្នុងពេលជួយជំរុញកំណើន នយោបាយបង្កើនសារពើពន្ធបានធ្វើឲ្យឱនភាពសារពើពន្ធសរុប មានទំហំកាន់តែធំ។** ទោះជាយ៉ាងណាក្តី ការប្រមូលចំណូលបានច្រើនជាបន្តបន្ទាប់បានជួយកាត់បន្ថយឱនភាពសារពើពន្ធ។ ក្នុងឆ្នាំ 2016 ឱនភាពសារពើពន្ធសរុប(គិតទាំងជំនួយឥតសំណង)ត្រូវបានប៉ាន់ស្មានថាបានឡើងដល់ 1.4 ភាគរយនៃ ផសស ធៀបនឹងតុល្យភាពសារពើពន្ធក្នុងឆ្នាំ 2015 (រូបលេខ 34)។ ឱនភាពសារពើពន្ធបានឡើងពី 1.8 ភាគរយនៃ ផសស ដល់ 3.0 ភាគរយនៃ ផសស ក្នុងឆ្នាំ 2016 បើមិនរាប់បញ្ចូលជំនួយឥតសំណង។

**រូបលេខ 34: ការប្រមូលចំណូលបានច្រើនធ្វើឲ្យឱនភាពសារពើពន្ធរួមតូច**
(ភាគរយនៃ ផសស)




ប្រភព: អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

ចំណាត់ថ្នាក់កង្វល់បំណុលរបស់កម្ពុជា នៅក្នុងការវិភាគចុងក្រោយរបស់ធនាគារពិភពលោក/មូលនិធិរូបិយវត្ថុអន្តរជាតិក្នុងឆ្នាំ 2016 ស្តីពីនិរន្តរភាពបំណុល នៅតែមានកម្រិតទាបមួយផ្នែកធំ គឺដោយសារគោលការណ៍ចម្បងនៃការខ្ចីតែក្នុងលក្ខខណ្ឌសម្បទានប៉ុណ្ណោះ។

## d) ថវិកាឆ្នាំ 2017

**ចំណាយសារធារណៈក្នុងថវិកាឆ្នាំ 2017 ត្រូវបានបង្កើនឡើងបន្ថែមទៀត ដោយសារការបង្កើនបញ្ជីប្រាក់បៀវត្សនៃវិស័យសាធារណៈ។** ថវិកាចំណូលទំនងមានទំហំទាបជាងការប្រមូលចំណូលប៉ាន់ស្មានសម្រាប់ឆ្នាំមុន ធ្វើឲ្យឱនភាពសារពើពន្ធសរុបកើនឡើងដល់ 2.3 ភាគរយ នៃ ផសស ។ ថវិកាចំណាយសាធារណៈសម្រាប់ឆ្នាំ 2017 ស្មើនឹង 21.7 ភាគរយនៃ ផសស ធៀបនឹងចំណាយប៉ាន់ស្មាន 21.4 ភាគរយនៃ ផសស ក្នុងឆ្នាំ 2016 នៅពេលដែលបៀវត្សវិស័យសាធារណៈកើនឡើងពី 7.4 ភាគរយនៃ ផសស ដល់ 7.6 ភាគរយនៃ ផសស ក្នុងឆ្នាំ 2016 (តារាងលេខ 2)។ ទោះជាយ៉ាងណាក្តី ផ្នែកមិនមែនបៀវត្សបានធ្លាក់ចុះបន្ថែមទៀត គឺពី 7.1 ភាគរយនៃ ផសស ក្នុងឆ្នាំ 2015 មកត្រឹម 6.9 ភាគរយ នៃ ផសស នៅក្នុងថវិកាឆ្នាំ 2017។

ជាមួយនឹងការធ្លាក់ចុះចំណូលថវិកាក្នុងស្រុកបន្តិចឱនភាពសារពើពន្ធជារួម (គិតទាំងជំនួយឥតសំណង) បានកើនទំហំ 0.9 ភាគរយនៃ ផសស ពង្រីកខ្លួនពីទំហំ 1.4 ភាគរយក្នុងឆ្នាំ 2016 ទៅដល់ 2.3 ភាគរយក្នុងថវិកាឆ្នាំ 2017។ ឱនភាពថវិកាឆ្នាំ 2017 កើនឡើងពី 3.0 ភាគរយនៃ ផសស ក្នុងឆ្នាំ 2016 ដល់ 3.5 ភាគរយនៃ ផសស ប្រសិនបើមិនគិតជំនួយឥតសំណង។

**តារាងលេខ 2:** ថវិកា 2017 ធៀបនឹងថវិកាប៉ាន់ស្មាន 2016 (ភាគរយនៃ ផសស)

| ប្រតិបត្តិការរបស់រដ្ឋាភិបាល | 2016e | 2017b |
|---|---|---|
| **ចំណូលក្នុងស្រុក** | 18.4 | 18.2 |
| **ចំណាយសរុប** | 21.4 | 21.7 |
| ក្នុងនោះប្រាក់ខែ | 7.4 | 7.6 |
| មិនមែនប្រាក់ខែ | 7.1 | 6.9 |
| មូលធន | 7.2 | 7.2 |
| ឱនភាពរួម | -1.4 | -2.3 |

ប្រភព: អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក
e = ប៉ាន់ស្មាន and b = ថវិកា





# C. ទស្សនវិស័យ និងហានិភ័យ

**កំណើនត្រូវបានព្យាករថានៅតែមានភាពរឹងមាំ ក្នុងកម្រិត 6.9 ភាគរយ ក្នុងឆ្នាំនេះ និងឆ្នាំក្រោយ ប៉ុន្តែ រំពឹងថានឹងថយចុះបន្តិចមកត្រឹម 6.7 ភាគរយ ក្នុងឆ្នាំ 2019 (តារាងលេខ 3)។** ខណៈដែលកំណើនត្រូវបានជំរុញមួយផ្នែក តាមរយៈការបង្កើនចំណាយរបស់រដ្ឋាភិបាល សញ្ញាធ្លាក់ចុះមួយចំនួន ជាពិសេសវិស័យសំណង់កំពុងតែលេចឡើង។ ការធ្លាក់ចុះបន្តិចបន្តួចនៃវិស័យកាត់ដេរសម្លៀកបំពាក់ ត្រូវបានរំពឹងថានឹងប៉ះប៉ូវដោយការរីកចម្រើននៃវិស័យកសិកម្ម (អាស្រ័យដោយកិច្ចប្រឹងប្រែងក្នុងពេលថ្មីៗក្នុងការធ្វើឲ្យវិស័យនេះសន្ទុះឡើងវិញ) និងវិស័យកម្មន្តសាល ដូចជា ស្បៀងអាហារ ភេសជ្ជៈ និងការកែច្នៃកសិផល។ វិស័យទេសចរណ៍ក៏អាចងើបឡើងវិញជាបណ្តើរៗផងដែរ មួយផ្នែកគឺដោយសារការបង្កើតជើងហោះហើរត្រង់ និងគំនិតផ្តួចផ្តើម ព្រមទាំងកិច្ចប្រឹងប្រែងលើកកម្ពស់ថ្មីៗក្នុងការធ្វើពិពិធកម្មគោលដៅទេសចរក្រៅពីប្រាសាទអង្គរ ដើម្បីបង្កើនសន្ទុះនៃការមកដល់នៃភ្ញៀវទេសចរ។

**តារាងលេខ 3:** សូចនាករសេដ្ឋកិច្ចសំខាន់- ចំណោលឆ្នាំ 2017 - 2019

| | 2015 | 2016e | 2017p | 2018f | 2019f |
|---|---|---|---|---|---|
| កំណើនពិតនៃ ផសស ថ្លៃទីផ្សារថេរ | 7.0 | 6.9 | 6.9 | 6.9 | 6.7 |
| កំណើនពិតនៃ ផសស តាមកត្តាថ្លៃថេរ | 6.9 | 6.8 | 6.8 | 6.8 | 6.6 |
| កសិកម្ម | 0.2 | 1.2 | 1 | 0.8 | 0.7 |
| ឧស្សាហកម្ម | 11.7 | 10.4 | 9.8 | 8.9 | 8.8 |
| សេវាកម្ម | 7.1 | 6.8 | 7.1 | 8 | 7.2 |
| វិស័យសាធារណៈ (% នៃ ផសស) | | | | | |
| ចំណូលក្នុងស្រុករបស់រដ្ឋាភិបាល | 18.7 | 18.4 | 18.2 | 17.7 | 17.1 |
| ចំណាយរដ្ឋាភិបាល | 20.5 | 21.4 | 23.3 | 22.5 | 21.6 |
| តុល្យភាពសារពើពន្ធគិតទាំងជំនួយឥតសំណង | -1.8 | 0.0 | -1.4 | -3.5 | -3.4 |
| អតិផរណា (មធ្យមភាគតាមគ្រា) | 1.3 | 3.5 | 3.7 | 4.2 | 5.2 |
| តុល្យភាពគណនីចរន្ត (% នៃ ផសស) | -9.7 | -10.6 | -9.5 | -9.2 | -8.9 |
| វិនិយោគផ្ទាល់ពីបរទេស (% នៃ ផសស) | 9.1 | 10.2 | 9.4 | 7.7 | 6.5 |
| បំណុលបរទេស(% នៃ ផសស) | 32.1 | 32.9 | 33.5 | 33.8 | 33.6 |

ប្រភព: អាជ្ញាធរកម្ពុជា ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ
សំគាល់: e = ប៉ាន់ស្មាន; f = ព្យាករណ៍; p = ចំណោល

**ទស្សនវិស័យសម្រាប់កំណើនក្នុងរយៈពេលមធ្យម នៅតែមានភាពប្រសើរ ទ្រទ្រង់ភាគច្រើនដោយពិពិធកម្មនាំចេញ ។** ទោះជាយ៉ាងណាក្តី ដូចបានពិភាក្សានៅក្នុងប្រធានបទ ជំពីស ក្នុងផ្នែកខាងក្រោម ការជំរុញសន្ទុះវិនិយោគ ដែលមានផលិតភាព ជាពិសេសការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលជាការប្តេជ្ញាដើម្បីជំរុញកំណើន និងផលប្រយោជន៍របស់ពលរដ្ឋក្រីក្រ ចែងនៅក្នុង ផយអជ ឆ្នាំ 2014-18 និងបង្កើនប្រសិទ្ធភាពចំណាយ គឺជាកិច្ចការសំខាន់ ខណៈដែលកង្វះខាតហេដ្ឋារចនាសម្ព័ន្ធត្រូវបានមើលឃើញថាជាឧបសគ្គចម្បងមួយអស់រយៈជាយូរមកហើយ និងក៏ជាបញ្ហាដែលធ្វើឲ្យរាំងស្ទះដល់ការអភិវឌ្ឍន៍មួយគួរឲ្យកត់សំគាល់។ ការលើកកម្ពស់ផលិតភាពការងារ និងសមិទ្ធកម្មនៃវិស័យសាធារណៈមានសារសំខាន់ ដើម្បីរក្សាលក្ខណៈប្រកួតប្រជែង ខណៈមានកំណើនប្រកួតប្រជែងពីបណ្តាប្រទេសនាំចេញសម្លៀកបំពាក់ដែលមានឈ្នួលពលកម្មថោក។

**ស្ថានភាពពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជាត្រូវបានរំពឹងថានឹងនៅអាចទ្រទ្រង់បាន ជាមួយនឹងការកើនឡើងនូវលំហូរវិនិយោគផ្ទាល់ពីបរទេស ប្រេងឥន្ធនៈមានតម្លៃថោក និងការនាំចូលធ្លាក់ចុះក្នុងរយៈពេលខ្លី។** ការកែតម្រូវក្នុងវិស័យសំណង់ក្រោយពីមានវិបត្តិហិរញ្ញវត្ថុពិភពលោកនឹងធ្វើឲ្យការនាំចូលធ្លាក់ចុះក្នុងរយៈពេលខ្លី ក្នុងពេលដែលដំណាក់កាលនៃគម្រោងសំណង់លំនៅដ្ឋាន និងអគារពាណិជ្ជកម្មទំនើបខ្ពស់ៗជាច្រើនឈានចូលដំណាក់កាលបញ្ចប់។ វឌ្ឍនភាព ក្នុងការជំរុញផលិតកម្មក្នុងស្រុកបន្តិចម្តងៗ ក៏ជួយជំនួសការនាំចូលក្នុងរយៈពេលមធ្យមផងដែរ។

**គោលនយោបាយពង្រីកសារពើពន្ធ ទំនងជានឹងបន្តរហូតដល់ឆ្នាំ 2018 ខណៈកំណើនបញ្ជីបៀវត្សនៃវិស័យ សាធារណៈ ចំណាយទាក់ទងនឹងការបោះឆ្នោត និងតម្រូវការក្នុងការជំរុញវិនិយោគសាធារណៈ ទំនងជាធ្វើឲ្យចំណាយសាធារណៈកើនឡើង។** ផ្ទុយទៅវិញ ជាមួយនឹងការកែតម្រូវ នៃវិស័យសំណង់ និងអចលនទ្រព្យ ដែលធ្វើឲ្យតម្រូវការប្រើប្រាស់ក្នុងស្រុក និងការនាំចូលធ្លាក់ចុះ ចំណូលរឹងមាំ ដែលកម្ពុជាទទួលបានរហូតមកដល់ពេលថ្មីៗនេះ អាចថយចុះជាបណ្តើរៗ។ បញ្ហានេះនឹងកើតមានឡើង ប្រសិនបើគ្មានវិធានការគោលនយោបាយពន្ធត្រូវបានដាក់ចូលដើម្បីពង្រីកមូលដ្ឋានពន្ធ និងពង្រឹងការគ្រប់គ្រងចំណូលបន្ថែមទៀតក្នុងរយៈពេលខ្លី និងរយៈពេលមធ្យម។

**សេដ្ឋកិច្ចមិនមែនកសិកម្មនៅជនបទ អាចជាកត្តារួមចំណែកមួយយ៉ាងសំខាន់ ចំពោះការកាត់បន្ថយភាពក្រីក្រ និងធ្វើឲ្យមានវិបុលភាពជារួមនៅកម្ពុជា ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ។** ប្រទេសកម្ពុជាមានលក្ខណៈស្រដៀងប្រទេសវៀតណាម ការធ្វើពិពិធកម្មការចិញ្ចឹមជីវិតនៅជនបទបានរួមចំណែករួចមកហើយក្នុងការកាត់បន្ថយភាពក្រីក្រជាខ្លាំង និងនាំមកនូវវិបុលភាពរួម ហើយប្រាក់ចំណូលមិនមែនកសិកម្មមានទំហំប្រមាណជា 36 ភាគរយនៃប្រាក់ចំណូលរបស់ប្រជាពលរដ្ឋក្រីក្រ 40 ភាគរយក្នុងឆ្នាំ 2015។

**ហានិភ័យអវិជ្ជមានចំពោះទស្សនវិស័យនេះ រួមមាន បច្ច័យអវិជ្ជមានពីការតម្លើងអត្រាការប្រាក់របស់សហរដ្ឋអាមេរិក ភាពយឺតយ៉ាវក្នុងការងើបឡើងវិញយឺតជាងការរំពឹងទុកនៃសេដ្ឋកិច្ចនៅអឺរ៉ុប និងភាពមិនប្រាកដប្រជានៃពាណិជ្ជកម្មសកល ។** ចំណែកក្នុងស្រុកវិញ ភាពមិនប្រាកដប្រជាទាក់ទងនឹងការបោះឆ្នោតអាចកើតឡើងក្នុងពេល និងក្រោយពេលការបោះឆ្នោតសកល ដែលគ្រោងប្រព្រឹត្តទៅនៅពាក់កណ្តាលឆ្នាំ 2018។ ការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុរបស់សហរដ្ឋអាមេរិកត្រូវបានរំពឹងថានឹងធ្វើឲ្យប្រាក់ដុល្លារអាមេរិកកើនថ្លៃធៀបនឹងប្រាក់អឺរ៉ូ និងធៀបនឹងរូបិយប័ណ្ណដទៃទៀត ដែលធ្វើឲ្យការនាំចេញ និងទេសចរណ៍របស់កម្ពុជាឡើងថ្លៃ និងមិនសូវមានភាពប្រកួតប្រជែងធៀបនឹងប្រទេសដទៃ។ ការតម្លើងអត្រាការប្រាក់ជាបន្តនៅសហរដ្ឋអាមេរិក អាចធ្វើឲ្យប៉ះពាល់ដល់លំហូរចូលមូលធនពីបរទេសមកកាន់ប្រទេសកម្ពុជា។ រាល់ការបង្អាក់លំហូរពាណិជ្ជកម្មសកល នឹងធ្វើឲ្យប៉ះពាល់ជាអវិជ្ជមានយ៉ាងខ្លាំងមកលើប្រទេសកម្ពុជា ខណៈដែលកម្ពុជាពឹងផ្អែកខ្លាំងលើការនាំចេញ ពិសេសគឺការនាំចេញសម្លៀកបំពាក់ និងស្បែកជើង ដែលជាកត្តាចម្បងមួយក្នុងការជំរុញកំណើនសេដ្ឋកិច្ច។





# D. សារៈនិងជម្រើសគោលនយោបាយសំខាន់ៗ

**ការរក្សាឲ្យមានភាពប្រកួតប្រជែង ដោយបង្កើនផលិតភាពការងារគឺជាគន្លឹះ ក្នុងការទូទាត់ជាមួយការតម្លើងប្រាក់ឈ្នួលពិតឆាប់រហ័ស។** កិច្ចការអាទិភាពខ្ពស់រួមមានការលើកកម្ពស់គុណភាពនៃការអប់រំមូលដ្ឋាន និងការបង្កើនជំនាញវិជ្ជាជីវៈ និងជំនាញបច្ចេកទេស ទន្ទឹមជាមួយការកាត់បន្ថយថ្លៃថាមពលដើម្បីទាក់ទាញ និងប្រកួតប្រជែងក្នុងផលិតកម្មដែលមានតម្លៃបន្ថែមខ្ពស់ ហើយមានលក្ខណៈកាន់តែស្មុគស្មាញ។ ការវិនិយោគក្នុងពេលបច្ចុប្បន្ន លើការលើកកម្ពស់លទ្ធផលនៃការរៀនសូត្រជាមួយនឹងការបង្កើនអត្រាចូលរៀន នៅសាលាមធ្យមសិក្សាគឺជាលក្ខណៈសំខាន់ចាំបាច់ សម្រាប់ឲ្យការធ្វើពិពិធកម្មនៃវិស័យឧស្សាហកម្មបានជោគជ័យទៅអនាគត។

**កំណែទម្រង់រដ្ឋបាលសាធារណៈដើម្បីកែលម្អការផ្តល់សេវាសាធារណៈមានសារសំខាន់ ពិសេសក្រោយពេលបង្កើនប្រាក់បៀវត្សរបស់មន្ត្រីរាជការកាលពេលថ្មីៗនេះ។** ខណៈដែលវិស័យសាធារណៈគឺជាវិស័យផ្តល់សេវា និងសម្របសម្រួលជាភារកិច្ចចាំបាច់ គឺត្រូវផ្សារភ្ជាប់ការបង្កើនប្រាក់បៀវត្សយ៉ាងច្រើនរបស់វិស័យសាធារណៈជាមួយនឹងការកែលម្អការផ្តល់សេវានៃវិស័យនេះ។ ការបង្កើនផលិតភាពក្នុងវិស័យសាធារណៈទ្រទ្រង់កិច្ចអភិវឌ្ឍវិស័យឯកជនដោយសារការបង្កើនផលិតភាពនេះ ជួយជំរុញវិនិយោគ និងសម្រួលពាណិជ្ជកម្មដែលធ្វើឲ្យមានកំណើន និងការកាត់បន្ថយភាពក្រីក្រ។

**ក្នុងបរិបទនៃការថយចុះនូវថវិកាមូលធន ដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍ កម្ពុជាត្រូវពង្រឹងការគ្រប់គ្រងវិនិយោគសាធារណៈដើម្បីបង្កើនចំណាយមូលធនរបស់រដ្ឋាភិបាល។** ការវិនិយោគដើម្បីជំរុញកំណើន និងផ្តល់ផលប្រយោជន៍ដល់ពលរដ្ឋក្រីក្រ ពិសេសការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត អាចផ្តល់ផលប្រយោជន៍ពីវិភាជន៍បន្ថែម ដើម្បីទូទាត់ជាមួយការកាត់បន្ថយថវិការបស់ដៃគូអភិវឌ្ឍន៍។ ទោះជាយ៉ាងណាក្តី ការលើកកម្ពស់ក្របខណ្ឌគតិយុត្តចំពោះការគ្រប់គ្រងវិនិយោគសាធារណៈ និងការកសាងសមត្ថភាពនៅតាមក្រសួងសំខាន់ៗ និងក្រសួង

ពាក់ព័ន្ធ គឺជាអាទិភាពចម្បង និងជាបុរេលក្ខខណ្ឌសម្រាប់បង្កើនប្រសិទ្ធភាពវិនិយោគ។ សម្រាប់ព័ត៌មានបន្ថែមស្តីពីការគ្រប់គ្រងវិនិយោគសាធារណៈ សូមអានប្រធានបទជ្រើសរើសស្តីពី "ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈ"។

**ការវាយតម្លៃកាលពីពេលថ្មីៗនេះ ស្នើឲ្យមានការកែលម្អគ្រប់ដំណាក់កាលនៃការគ្រប់គ្រងវិនិយោគសាធារណៈ ដូចជាដំណាក់កាលមុនការវាយតម្លៃគម្រោង ការវាយតម្លៃគម្រោង ការកំណត់អាទិភាពគម្រោង និងការរៀបចំថវិកា ដែលគាំទ្រដោយការធ្វើសេចក្តីសម្រេចចិត្ត មុនពេលគម្រោងចាប់ផ្តើម។** កិច្ចការសំខាន់ត្រូវបង្កើតគោលការណែនាំ ដែលមានលក្ខណៈស្តង់ដារ និងមានការត្រួតពិនិត្យលើប្រសិទ្ធភាពចំណាយ ក្នុងការអនុវត្តគម្រោង ហើយលើកកម្ពស់សមត្ថភាពរបស់បណ្តាក្រសួង និងស្ថាប័ននានាក្នុងការរៀបចំ និងវាយតម្លៃគម្រោងវិនិយោគប្រកបដោយប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលផ្សាភ្ជាប់ដោយខានមិនបាន ជាមួយអាទិភាពជាយុទ្ធសាស្ត្រនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា និងក្របខណ្ឌចំណាយរយៈពេលមធ្យម។

**ការយកចិត្តទុកដាក់បន្ថែមក្នុងការលើកកម្ពស់ការយល់ដឹងផ្នែកហិរញ្ញវត្ថុរបស់អតិថិជន ជាពិសេសសម្រាប់ក្រុមប្រជាពលរដ្ឋដែលមានការអប់រំតិចតួច គួរតែជាអាទិភាពមួយ។** បន្ថែមពីលើនេះ ដើម្បីជៀសវាងការជំពាក់បំណុលច្រើនជ្រុលហួសកម្រិតការដាក់កម្រិតលើការផ្តល់ឥណទាន ធៀបនឹងទំហំផលបត្រអាចជាវិធានការចាំបាច់មួយ ដើម្បីទប់ស្កាត់ការឡើងកំដៅជ្រុលនៃទីផ្សារឥណទាន។ ការកំណត់អត្រាការប្រាក់ពិតាននាពេលថ្មីៗនេះ ទំនងជាមានលទ្ធភាពជួយកាត់បន្ថយថ្លៃខ្ចី មានប្រយោជន៍សម្រាប់កម្ចីដែលមានផលិតភាព ជាពិសេសចំពោះកសិករក្រីក្រ និងអាជីវកម្មខ្នាតតូច។ ក៏ប៉ុន្តែ ការកំណត់អត្រាការប្រាក់ពិតាននេះ អាចធ្វើឲ្យប៉ះពាល់ដល់លទ្ធភាពទទួលបានឥណទានផងដែរ នៅក្នុងតំបន់ដែលគ្មានសេវាឥណទានគ្រប់គ្រាន់។







# E. ប្រធានបទជម្រើស: ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ

## ការលើកទឹកចិត្ត

**ការវិនិយោគលើទំនិញ និងសេវាសាធារណៈ ដូចជា ហេដ្ឋារចនាសម្ព័ន្ធ សុខាភិបាល និងអប់រំ គឺជាការវិនិយោគសំខាន់ដើម្បីឲ្យមានកំណើនសេដ្ឋកិច្ច។** ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធគឺជាការចាំបាច់ ដើម្បីឲ្យសេដ្ឋកិច្ចនានាដំណើរការប្រកបដោយប្រសិទ្ធភាព។ ការបង្កើនចំណាយលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ពោលគឺចំណាយមូលធនរូបវន្ត មានឥទ្ធិពលទៅលើសេដ្ឋកិច្ចទាំងក្នុងរយៈពេលខ្លី តាមរយៈការបង្កើនតម្រូវការក្នុងស្រុក និងទាំងក្នុងរយៈពេលវែង តាមរយៈការពង្រីកសមត្ថភាពផលិតនៃសេដ្ឋកិច្ច និងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចនោះ។ ការវិនិយោគលើសុខភាពសាធារណៈ (រាប់ទាំងវិធានការបង្ការ និងការពារ) អាចជាចំណាយដែលមានប្រសិទ្ធភាពនិងផ្តល់ផលខ្ពស់មកលើសុខភាពមនុស្ស និងការផ្តល់ហិរញ្ញប្បទានលើសេវានានា[21]។ ការផ្តល់មូលនិធិលើវិស័យអប់រំគឺជាការកសាងមូលធនមនុស្ស រួមចំណែកធ្វើឲ្យមានផលប្រយោជន៍ សេដ្ឋកិច្ចរយៈពេលវែង តាមរយៈការផ្តល់កម្លាំងពលកម្មដែលបានទទួលការបណ្តុះបណ្តាលបានល្អ។ ឆ្លងតាមការផ្តល់ហេដ្ឋារចនាសម្ព័ន្ធទាំងសង្គម និងសេដ្ឋកិច្ច ចំណាយសាធារណៈលើវិស័យសំខាន់ៗ អាចជាកាតាលីករសំខាន់ដើម្បីនាំមកនូវកំណើនសេដ្ឋកិច្ច[22]។

**ចំណាយសាធារណៈដ៏មានប្រសិទ្ធភាព គឺជាគន្លឹះដើម្បីធានាគុណតម្លៃ រីឯបញ្ហាប្រឈមដែលពិបាកដោះស្រាយគឺការធានាប្រសិទ្ធភាព លើការវិនិយោគមូលធនសាធារណៈ។** ជាញឹកញាប់ ចំណាយមូលធនគឺជា ការវិនិយោគសាធារណៈដែលមានរយៈពេលវែង ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា ផ្លូវថ្នល់ និងស្ពាន ជាដើម។ ហេតុនេះ ជាការចាំបាច់ត្រូវធ្វើការជ្រើសរើសគម្រោងដែលងាយអនុវត្តហើយនាំមកនូវអត្ថប្រយោជន៍សង្គម និងសេដ្ឋកិច្ចជាអតិបរមា។ ពុំមែនត្រឹមតែថ្លៃចំណាយវិនិយោគមូលធនដំបូងតែប៉ុណ្ណោះទេ ប៉ុន្តែរួមទាំងចំណាយប្រតិបត្តិការ និងការផ្តល់មូលនិធិថែទាំផងដែរ មានសារសំខាន់ជាខ្លាំង។ ការខ្ចីប្រាក់សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដោយមិនបានវាយតម្លៃលទ្ធភាពផ្នែកសេដ្ឋកិច្ច និងបច្ចេកទេសទំនងជានាំមកនូវលទ្ធផលមិនល្អ (ឧទាហរណ៍ ផ្លូវមានគុណភាពមិនល្អ ឆាប់ខូចដោយសារចរាចរណ៍យានយន្តធុនធ្ងន់)។ ដូច្នេះការកែលម្អ ការគ្រប់គ្រងវិនិយោគសាធារណៈ

21 ករណីសម្រាប់វិនិយោគលើសុខភាពសាធារណៈ អង្គការសុខភាពពិភពលោក ឆ្នាំ 2014។សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមអាន http://www.euro.who.int/__data/assets/pdf_file/0009/278073/Case-Investing-Public-Health.pdf

22 Why Public Investment Matters, IMF. សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមអាន http://www.imf.org/external/np/fad/publicinvestment/

អាចបង្កើនផលប្រយោជន៍នៃការវិនិយោគសាធារណៈ[23] ។ ប្រទេសដែលមានស្ថាប័នគ្រប់គ្រង វិនិយោគសាធារណៈរឹងមាំ មានការវិនិយោគសាធារណៈដែលអាចព្យាករបាន គួរទុកចិត្តបាន មានប្រសិទ្ធភាព និង ផលិតភាពជាងប្រទេសដែលមានស្ថាប័នគ្រប់គ្រងវិនិយោគសាធារណៈមិនសូវរឹងមាំ។

## និន្នាការនៃចំណាយសាធារណៈ

**ដើម្បីកែលម្អលទ្ធភាពក្នុងការទទួលបានសេវាសាធារណៈ ក៏ដូចជាកែលម្អគុណភាព និងវិសាលភាពនៃសេវាសាធារណៈ ប្រទេសកម្ពុជាបានបង្កើនចំណាយសាធារណៈយ៉ាងច្រើនពីហិរញ្ញប្បទានក្នុងស្រុក (ផ្តល់ដោយរដ្ឋាភិបាល) ក្នុងទសវត្សកន្លងមក សម្រាប់ប៉ះប៉ូវការធ្លាក់ចុះថវិកាដែលផ្តល់ហិរញ្ញប្បទានពីបរទេស (ផ្តល់ដោយដៃគូអភិវឌ្ឍន៍)។** ដោយមានការគាំទ្រពីការប្រមូលចំណូលដែលមានការកើនឡើងយ៉ាងឆាប់រហ័សជាបន្តបន្ទាប់ គេឃើញមានកិច្ចប្រឹងប្រែងក្នុងការលើកកម្ពស់ចំណាយ ដែលផ្តល់ហិរញ្ញប្បទានក្នុងស្រុក តាមរយៈការបង្កើនថវិកាប្រចាំឆ្នាំសម្រាប់វិស័យសំខាន់ៗមួយចំនួន ទន្ទឹមនឹងការព្យាយាមបង្កើនប្រសិទ្ធភាពចំណាយ តាមរយៈការដាក់ឲ្យអនុវត្តថវិកាតាមកម្មវិធីដែលជំរុញទំនាក់ទំនងរវាងធាតុចូល និងធាតុចេញ ក៏ដូចជារវាងថវិកា និងគោលនយោបាយផងដែរ។

**ជាលទ្ធផល ថវិកាហិរញ្ញប្បទានក្នុងស្រុកសម្រាប់វិស័យអប់រំ និងវិស័យដឹកជញ្ជូនកើនឡើងពី 1.5 ភាគរយ និង 0.4 ភាគរយ នៃ ផសស ក្នុងឆ្នាំ 2007 ដល់ 2.3 ភាគរយ និង 0.9 ភាគរយ ក្នុងឆ្នាំ 2016 រៀងៗគ្នា (រូបលេខ S1)**[24]។ ចំណាយសាធារណៈសរុបចំពោះវិស័យអប់រំ និងដឹកជញ្ជូនបានកើនឡើងខ្ពស់បំផុត ពី 2.6 ភាគរយនិង 1.6 ភាគរយ នៃ ផសស ក្នុងឆ្នាំ 2007 ដល់ 3.3 ភាគរយ និង 1.9 ភាគរយ នៃ ផសស ក្នុងឆ្នាំ 2016 (រូបលេខ S2)។ ខុសពីថវិកាចំណាយវិស័យអប់រំដែលមួយផ្នែកធំជំរុញដោយថវិកាក្នុងស្រុក (ពីរដ្ឋាភិបាល) ថវិកាចំណាយសាធារណៈនៃវិស័យដឹកជញ្ជូនមានប្រភពមកពីក្នុងស្រុក និងបរទេស (ផ្តល់ដោយដៃគូអភិវឌ្ឍន៍)។

**រូបលេខ S1: កំណើនខ្ពស់ជាភាគរយនៃ ផសស ចំពោះចំណាយវិស័យអប់រំពីហិរញ្ញប្បទានក្នុងស្រុក** (ភាគរយនៃ ផសស)




ប្រភព: អាជ្ញាធរកម្ពុជា

**រូបលេខ S2: ចំណាយឧត្តមសិក្សា និងដឹកជញ្ជូនកើនឡើងដោយហិរញ្ញប្បទានក្នុងស្រុក** (ភាគរយនៃ ផសស)




ប្រភព: អាជ្ញាធរកម្ពុជា

**ទោះបីជាមានការបង្កើនក្នុងការបែងចែកថវិកាសរុបក៏ដោយ ថវិកាមូលធននៅតែមានចំនួនតិចហើយធ្លាក់ចុះ។** កំណើននៃការបែងចែកថវិកាពីសំណាក់អាជ្ញាធរដែលបានពិភាក្សាខាងលើ បានកើតជាចម្បងលើចំណាយចរន្ត (រូបលេខ S3) និងជាពិសេសបៀវត្សនៃវិស័យសាធារណៈតែប៉ុណ្ណោះ ធ្វើឲ្យវិនិយោគមូលធនរូបវន្តហិរញ្ញប្បទានក្នុងស្រុកមួយផ្នែកធំមិនប្រែប្រួល។ ឧទាហរណ៍ វិភាជន៍ថវិកាមូលធនហិរញ្ញប្បទានក្នុងស្រុកសម្រាប់វិស័យអប់រំ និង សុខភាពសាធារណៈនៅតែមានកម្រិតទាបជាង 5 ភាគរយ នៃតួលេខថវិកាសរុបរបស់វិស័យនីមួយៗ។

23 ការធ្វើឲ្យវិនិយោគសាធារណៈកាន់តែមានប្រសិទ្ធភាព (Making public investment more efficient), IMF, ខែ មិថុនា ឆ្នាំ 2015

24 ចំណាយសាធារណៈលើវិស័យអប់រំ រួមមានវិភាជន៍ចំពោះក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ខណៈដែលចំណាយលើវិស័យកសិកម្មរួមមានថវិកាចំណាយសំរាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងអភិវឌ្ឍន៍ជនបទ។

**គេសង្កេតឃើញថាមានការថយចុះ នៃចំណាយមូលធនសាធារណៈក្នុងរយៈ 5 ឆ្នាំកន្លងទៅខណៈដែលចំណាយមូលធនទូទៅរបស់រដ្ឋាភិបាលកំពុងធ្លាក់ចុះ ហើយបច្ចុប្បន្ននេះមានកម្រិតទាមជាងបណ្តាប្រទេសដទៃទៀតក្នុងតំបន់ (រូបលេខ S4)។** កម្ពុជានៅតែមិនបានវិនិយោគគ្រប់គ្រាន់នៅឡើយ បើពិនិត្យមើលវិនិយោគមូលធនសរុប ដែលរួមមានទាំងវិនិយោគមូលធនសាធារណៈ និងវិនិយោគមូលធនឯកជន ។ ទោះជាផយអជ ឆ្នាំ 2014-18 លើកផែនការវិនិយោគមូលធនសរុបខ្ពស់ជាង 26 ភាគរយ នៃ ផសស វិនិយោគមូលធនសរុបជាក់ស្តែងនៅមានកម្រិតទាបជាង 22 ភាគរយ នៃ ផសស[25]។

**រូបលេខ S3: សន្ទុះវិភាជន៍កាលពីពេលថ្មីៗចំពោះការដឹកជញ្ជូនមានទំនោរទៅរកចំណាយចរន្ត** (ភាគរយ)




ប្រភព: អាជ្ញាធរកម្ពុជា

**រូបលេខ S4: ចំណាយមូលធនរបស់រដ្ឋាភិបាលកម្ពុជាកំពុងធ្លាក់ចុះ និងមានកម្រិតទាបជាងបណ្តាប្រទេសក្នុងតំបន់** (ភាគរយនៃ ផសស)




ប្រភព: ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ

## ការចំណាយ និងប្រសិទ្ធភាពនៃការវិភាជន៍ ជាមួយការប្រៀបធៀបក្នុងតំបន់

**ការប្រៀបធៀបក្នុងតំបន់បង្ហាញថា ចំណាយតាមវិស័យជារួម (មិនគិតថវិកាហិរញ្ញប្បទានពីបរទេស) លើវិស័យ អប់រំ សុខាភិបាល កសិកម្ម និងវិស័យដឹកជញ្ជូន ជាទូទៅអាចប្រៀបធៀបជាមួយបណ្តាប្រទេសដទៃទៀត ក្នុងតំបន់ (តារាង S1)។** ក្នុងទសវត្សកន្លងទៅ កំណើនចំណាយធំបំផុតមានអត្រា 0.8 ភាគរយ និង 0.7 ភាគរយ នៃ ផសស រៀងគ្នាសម្រាប់វិស័យដឹកជញ្ជូន និងវិស័យអប់រំ។ ផ្ទុយទៅវិញ ចំណាយសុខភាពសាធារណៈបានធ្លាក់ចុះ 0.7 ភាគរយនៃ ផសស។

**ការវាយតម្លៃចំនួនសូចនាករមួយចំនួន បង្ហាញថាប្រសិទ្ធភាពចំណាយសាធារណៈរបស់កម្ពុជា ទំនងជាមានលក្ខណៈចម្រុះ[26]។** ទោះជាយ៉ាងណាក៏ដោយ ការប្រើប្រាស់សូចនាករមួយចំនួន ក្នុងការវាយតម្លៃប្រសិទ្ធភាពចំណាយសាធារណៈតាមវិស័យ ជារួម ទំនងជាមិនគ្រប់គ្រាន់ទេ។ បញ្ហានេះ មួយផ្នែកធំគឺដោយសារ ចំនួនសូចនាករដែលមានចំនួនតិច និងការពិតដែលសូចនាករសម្រាប់វាយតម្លៃទាំងអស់នោះជារឿយៗ អាចរងឥទ្ធិពលពីកត្តាជាច្រើន លើសពីប្រសិទ្ធភាពនៃការវិភាជន៍ទៅទៀត។ ឧទាហរណ៍ ការកាត់បន្ថយអត្រាក្រិនចំពោះកុមារដែលមានអាយុតិចជាង 5 ឆ្នាំ មិនមែនអាស្រ័យតែទៅលើលទ្ធភាពទទួលបានសេវាថែទាំសុខភាពនៃសាធារណជនតែប៉ុណ្ណោះទេ ថែមទាំងលើអាហារូបត្ថម្ភផងដែរ។ ដូចគ្នាដែរ ផលបានមកពីចំណាយមូលធន ពុំមែនគ្រាន់តែអាស្រ័យលើវិនិយោគមូលធនរូបវន្តគ្រាដំបូង ដែលភាគច្រើនផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍នោះទេ ប៉ុន្តែក៏អាស្រ័យលើប្រតិបត្តិការ និងការថែទាំដែលផ្តល់ដោយថវិកាក្នុងស្រុកផងដែរ។

25 វិនិយោគមូលធនជាក់ស្តែងក្នុងស្ថិតិគណនីជាតិគឺជាការបង្កើតមូលធនថេរដុល ដែលនៅតែមានកម្រិតទាបជាង 22 ភាគរយនៃ ផសស។ ចំពោះ ការវិនិយោគមូលធនកាតព្វកិច្ច សូមអាន ជំពូក ៥ ស្តីពី ថ្លៃចំណាយ ធនធាន និងការរៀបចំកម្មវិធី ផយអជ 2014-18 (ទំព័រ 202-209)។

26 ដូចក្នុងបាយការណ៍របស់បុគ្គលិក IMF ស្តីពី “Making public investment more efficient-ការធ្វើឲ្យវិនិគសាធារណៈកាន់តែមានប្រសិទ្ធភាព” ផ្នែកនេះប្រើប្រាស់អញ្ញត្តិតំណាងធាតុចូល (កម្រិតនៃការចំណាយ) និងធាតុចេញ/លទ្ធផល (ផ្លូវថ្នល់ មរណភាពមាតា) ក្នុងការព្យាយាមប៉ាន់ប្រមាណអំពីប្រសិទ្ធភាព។ គួរកត់សំគាល់នូវផលលំបាកសំខាន់ៗផ្នែកទិន្នន័យក្នុងការជ្រើសរើសសូចនាករ។ ផលលំបាកមួយទៀតគឺអញ្ញត្តិតំណាងមិនអាចតាងឲ្យទាំងស្រុង ឬតាងតែឯងឲ្យកម្រិតនៃការចំណាយទាំងនោះឡើយ។

| **តារាងលេខ S1:** ចំណាយតាមវិស័យ-ការប្រៀបធៀបក្នុងតំបន់ | | | | |
|---|---|---|---|---|
| % នៃ ផសស | អប់រំ | សុខាភិបាល* | កសិកម្ម | ដឹកជញ្ជូន |
| *2016 ឬឆ្នាំដែលមានព័ត៌មានចុងក្រោយបំផុត* | | | | |
| កម្ពុជា | 3.3 | 2.0 | 2.0 | 1.9 |
| ហ្វីលីពីន | 3.4 | 1.6 | 1.0 | 2.6 |
| សឹង្ហបុរី | 3.0 | 2.1 | 0.0 | 0.9 |
| ថៃ | 3.8 | 5.6 | 1.6 | 1.4 |
| ម៉ាឡេស៊ី | 5.0 | 2.3 | 0.7 | 1.3 |
| សាធារណរដ្ឋកូរ៉េ | 3.4 | 4.0 | 0.8 | 1.2 |
| បង់ក្លាដែស | 2.0 | 0.8 | 1.3 | 1.1 |
| *2007* | | | | |
| កម្ពុជា | 2.5 | 2.7 | 1.8 | 1.2 |
| ហ្វីលីពីន | 2.4 | 1.4 | 1.0 | 1.8 |
| សឹង្ហបុរី | 3.9 | 1.0 | 0.1 | 2.3 |
| ថៃ | 3.7 | 4.6 | 1.0 | 0.6 |
| ម៉ាឡេស៊ី | 5.5 | 2.0 | 0.9 | 2.0 |
| សាធារណរដ្ឋកូរ៉េ | 2.9 | 3.3 | 1.0 | 1.6 |
| បង់ក្លាដែស | 1.8 | 1.0 | 0.6 | 0.5 |
| *កើនឡើង ឬថយចុះ* | | | | |
| កម្ពុជា | 0.7 | -0.7 | 0.1 | 0.8 |
| ហ្វីលីពីន | 1.0 | 0.2 | 0.0 | 0.7 |
| សឹង្ហបុរី | -0.9 | 1.1 | -0.1 | -1.4 |
| ថៃ | 0.2 | 1.0 | 0.6 | 0.8 |
| ម៉ាឡេស៊ី | -0.6 | 0.3 | -0.2 | -0.7 |
| សាធារណរដ្ឋកូរ៉េ | 0.5 | 0.7 | -0.2 | -0.4 |
| បង់ក្លាដែស | 0.2 | -0.2 | 0.7 | 0.6 |

ប្រភព: ធនាគារអភិវឌ្ឍន៍អាស៊ី និងអាជ្ញាធរកម្ពុជា* សូចនាករអភិវឌ្ឍន៍ពិភពលោក

- **ជាទូទៅ អត្រាចុះឈ្មោះចូលរៀនសុទ្ធសម្រាប់កម្រិតបឋមសិក្សារបស់ប្រទេសកម្ពុជា** អាចប្រៀបធៀបគ្នាបានជាមួយបណ្តាប្រទេសជាច្រើនក្នុងតំបន់ ហើយមានកម្រិតខ្ពស់ជាងលទ្ធផលអនុវត្តជាមធ្យម នៅបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច និងប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប (រូបលេខ S5)។ ទោះជាយ៉ាងណាក៏ដោយ អត្រាចុះឈ្មោះចូលរៀនសុទ្ធ សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ ទោះបីត្រូវធ្វើបានល្អប្រសើរក្នុងឆ្នាំ 2007-14 ក៏ដោយក៏នៅតែមានកម្រិតទាប ជាងបណ្តាប្រទេសនានាក្នុងតំបន់យ៉ាងខ្លាំងនៅឡើយ (រូបលេខ S6)។

**រូបលេខ S5: អត្រាចុះឈ្មោះចូលរៀនសុទ្ធ(កែតម្រូវ) បឋមសិក្សា (%)**




ប្រភព: ធនាគារពិភពលោក

**រូបលេខ S6: អត្រាចុះឈ្មោះចូលរៀនសុទ្ធ(កែតម្រូវ) មធ្យមសិក្សាបឋមភូមិ (%)**




ប្រភព: ធនាគារពិភពលោក

- **ទោះបីជាស្ថិតក្នុងចំណោមប្រទេសចំណាយខ្ពស់បំផុតលើសុខភាពសាធារណៈក៏ដោយ** កម្ពុជាមិនសូវទទួលជោគជ័យដូច ប្រទេសវៀតណាម និងម៉ុងហ្គោលីឡើយ ក្នុងការកាត់បន្ថយអត្រាក្រិន និងអត្រាស្លាប់របស់កុមារអាយុក្រោម 5 ឆ្នាំនោះឡើយ ថ្វីបើកម្ពុជាទទួលបានលទ្ធផលល្អប្រសើរជាងប្រទេសមួយចំនួន ដូចជា ប្រទេសឡាវ ឥណ្ឌូនេស៊ី និងហ្វីលីពីន (រូបលេខ S7 និង S8)។

**រូបលេខ S7: កុមារក្រិនអាយុក្រោម 5 ឆ្នាំ**




ប្រភព: អង្គការសុខភាពពិភពលោក

**រូបលេខ S8: អត្រាស្លាប់< 5 ឆ្នាំ(ក្នុង 1,000 កំណើតរស់)**




ប្រភព: អង្គការសុខភាពពិភពលោក

- **ទោះជាវិនិយោគសាធារណៈលើវិស័យដឹកជញ្ជូនមានទំហំធំជាងប្រទេសមួយចំនួនក៏ដោយ កម្ពុជាគ្រាន់តែអាចធ្វើឲ្យមានវឌ្ឍនភាពតិចតួចប៉ុណ្ណោះ ក្នុងការកែលម្អប្រវែងផ្លូវកៅស៊ូ គិតជាភាគរយនៃប្រវែងផ្លូវសរុប** (រូបលេខ S9)។

ដូចគ្នាដែរ ពិន្ទុប្រៀបធៀបគុណភាពផ្លូវថ្នល់របស់កម្ពុជា ដែលចាត់ថ្នាក់ដោយសន្ទស្សន៍នៃភាពប្រកួតប្រជែងសកល (Global Competitiveness Index) បានធ្លាក់ចុះពី 3.8 ក្នុងឆ្នាំ 2010 មកត្រឹម 3.4 ក្នុងឆ្នាំ 2016[27]។ ក្នុងកំឡុងពេលនេះកម្ពុជាបានអនុវត្តបានល្អធៀបនឹងប្រទេសដទៃក្នុងការលើកកម្ពស់ប្រសិទ្ធភាពដឹកជញ្ជូន (LPI) ដែលបង្ហាញដោយការកើនពិន្ទុសន្ទស្សន៍ដឹកជញ្ជូនរបស់កម្ពុជាក្នុងអំឡុងឆ្នាំ 2010-16 ។ នេះគឺជាលទ្ធផលនៃភាពជោគជ័យ ក្នុងការអនុវត្តកំណែទម្រង់គ្រប់គ្រង ព្រំដែនជាមូលដ្ឋាន ថ្វីបើកម្ពុជាមិនទាន់ជោគជ័យក្នុងការកាត់បន្ថយចំណាយក្នុងការនាំចេញដែលជាចំណុចធ្វើឲ្យមិនសូវមានភាពប្រកួតប្រជែងនៅឡើយ។ ចំណាយចំពោះការនាំចេញនៅកម្ពុជាក្នុងមួយកុងតឺន័រនៅតែមិនប្រែប្រួលចាប់ពីឆ្នាំ 2005 ដល់ 2014 (រូបលេខ S10)។

**រូបលេខ S9: ផ្លូវក្រាលកៅស៊ូ(ភាគរយនៃផ្លូវសរុប)**




ប្រភព: សូចនាករអភិវឌ្ឍន៍ពិភពលោក

**រូបលេខ S10: ចំណាយក្នុងការនាំចេញ** (US$ /កុងតឺន័រ)




ប្រភព: សូចនាករអភិវឌ្ឍន៍ពិភពលោក

27 Global Competitiveness index reports, 2010-11 and 2016-17.(របាយការណ៍ស្តីពីសន្ទស្សន៍នៃភាពប្រកួតប្រជែងសកល ឆ្នាំ 2010-11 និង 2016-17)

## ការគ្រប់គ្រងវិនិយោគសាធារណៈ

### a) មុខងារនៃវិនិយោគមូលធន

**ខណៈមានភស្តុតាងដែលថាចំណាយមូលធនជំរុញឲ្យមានសន្ទុះកំណើនច្រើនជាចំណាយចរន្ត ឥទ្ធិពលពហុគុណសារពើពន្ធនៃ ចំណាយមូលធន អាចពុំមានទំហំធំ ដូចបានរំពឹងទុកឡើយ ប្រសិនបើចំណាយទាំងនោះមានការបែកធ្លាយ ។** Ilzetzki et al. (2011) រកឃើញថា នៅប្រទេសកំពុងអភិវឌ្ឍន៍ ឥទ្ធិពលពហុគុណនៃវិនិយោគរបស់រដ្ឋាភិបាលមានទំហំខ្ពស់ជាងយ៉ាងច្រើនធៀបឥទ្ធិពលនៃចំណាយលើការប្រើប្រាស់របស់រដ្ឋាភិបាលក្នុងរយៈពេលពីរឆ្នាំ[28]។ ចំណុចនេះបង្ហាញថាចំណាយមូលធន គឺជាកត្តាសំខាន់មួយក្នុងការជំរុញ កំណើននៅប្រទេសកំពុងអភិវឌ្ឍន៍។ ទោះជាយ៉ាងណាក្តី ឥទ្ធិពលពហុគុណសារពើពន្ធនៃចំណាយមូលធន អាចពុំមានទំហំធំដូចដែលបានរំពឹងទុក ប្រសិនមានការបែកធ្លាយ។ ការខ្ជះខ្ជាយបណ្តាលមកពីអប្រសិទ្ធភាព នៅក្នុងបណ្តាប្រទេសដែលមានសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ត្រូវបានប៉ាន់ស្មានថាមានទំហំស្មើ 50 ឬ 60 ភាគរយនៃមូលនិធិដែលបានវិនិយោគ ជាកម្រិតដែលរំខានជាខ្លាំងនូវការប្រឹងប្រែង ក្នុងកិច្ចជំរុញផ្នែកសារពើពន្ធ (Riera-Crichton et al., 2014) ។ ឥទ្ធិពលជំរុញវិជ្ជមានដោយគោលនយោបាយសារពើពន្ធ នៅបណ្តាប្រទេសឧស្សាហកម្មអភិវឌ្ឍ មានទំហំធំជាងយ៉ាងច្រើនធៀបនឹងប្រទេសកំពុងអភិវឌ្ឍន៍ ដោយសារតែប្រទេសឧស្សាហកម្មច្រើនតែមានប្រសិទ្ធភាពក្នុងការវិភាជ និងក្នុងការអនុវត្តចំណាយសាធារណៈ។

**ចំពោះប្រទេសកម្ពុជា ការធ្លាក់ចុះវិនិយោគនឹងមានផលប៉ះពាល់យ៉ាងច្រើនចំពោះភាពប្រកួតប្រជែងរបស់ខ្លួន ព្រោះកង្វះខាតហេដ្ឋារចនាសម្ព័ន្ធ គឺជាបញ្ហាចម្បងមួយរបស់កម្ពុជាអស់រយៈពេលជាយូរមកហើយ និងជាឧបសគ្គាំងស្ទះដ៏ធំមួយ[29]។** ការបង្កើនចំណាយសាធារណៈពីសំណាក់ រដ្ឋាភិបាលកម្ពុជាកាលពីពេលថ្មីៗ ហាក់ដូចជាផ្អៀងទៅរកការបង្កើនប្រាក់បៀវត្សនៃវិស័យសាធារណៈ ខណៈដែលចំណាយមូលធនដែលហិរញ្ញប្បទានពីប្រភពក្នុងស្រុក នៅតែមានកម្រិតទាបប្រមាណជា 2.0 ទៅ 2.5 ភាគរយនៃ ផសស ក្នុងកំឡុងឆ្នាំ 2009-16។ ហេតុនេះដោយប្រទេសកម្ពុជានឹងត្រូវត្រៀមខ្លួនបង្កើនវិនិយោគ ដែលផ្តល់ហិរញ្ញប្បទានដោយរដ្ឋាភិបាលទៅអនាគត ប្រទេសកម្ពុជាចាំបាច់ពង្រឹងប្រសិទ្ធភាព និងប្រសិទ្ធផលនៃការគ្រប់គ្រងវិនិយោគសាធារណៈ។ ក្នុងឆ្នាំ 2011 សន្ទស្សន៍មួយនៃប្រសិទ្ធភាពវិនិយោគសាធារណៈបានចាត់ថ្នាក់កម្ពុជា ចូលក្នុងបណ្តាប្រទេសដែលមានសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍40ភាគរយដែលទន់ខ្សោយបំផុត សំខាន់ដោយសារកំសោយក្នុងការជ្រើសរើស និងការវាយតម្លៃគម្រោងវិនិយោគ (Dabla-Norris et al., 2011)។

### b) កិច្ចប្រតិបត្តិអំពីការគ្រប់គ្រងវិនិយោគសាធារណៈបច្ចុប្បន្នរបស់កម្ពុជា

**ការវាយតម្លៃមួយកាលពីពេលថ្មីៗបានរកឃើញថា ក្រប-ខណ្ឌគតិយុត្ត និងបទប្បញ្ញត្តិកំពុងស្ថិតនៅជាធរមាន សម្រាប់ការគ្រប់គ្រងវិនិយោគសាធារណៈ គ្រប់គ្រងដោយច្បាប់ថវិកា និងច្បាប់វិនិយោគ និងដោយបទប្បញ្ញត្តិដទៃទៀតរបស់រដ្ឋាភិបាល មានសភាពធូររលុងជាខ្លាំង[30]។** ខណៈកម្ពុជាមានច្បាប់ពាក់ព័ន្ធមួយចំនួន ដូចជា ច្បាប់ថវិកាប្រចាំឆ្នាំ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់លទ្ធកម្មសាធារណៈ បទប្បញ្ញត្តិជាក់លាក់ទាក់ទងនឹងការគ្រប់គ្រងវិនិយោគសាធារណៈទំនងជាមិនទាន់មានចែងគ្រប់គ្រាន់។ ច្បាប់ថវិកាពុំមានជំពូក ឬមាត្រាណាមួយអំពីការធ្វើនិយ័តកម្មចំណាយមូលធន និងគ្រប់គ្រងវិនិយោគសាធារណៈនោះទេ ចំណែកឯច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈមានចំណុចយោងតែមួយគត់ ចំពោះការរៀបចំថវិកាមូលធន និងដំណើរការគ្រប់គ្រងវិនិយោគសាធារណៈ។ ជាលទ្ធផល ការបែងចែកមុខងារ និងភារកិច្ចក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗមានភាពធូររលុង ឬអាចនិយាយថា មិនស្ថិតក្នុងកម្រងច្បាប់។

**បញ្ហាប្រឈមជាច្រើន កើតឡើងនៅក្នុងដំណាក់កាលពីដំបូងនៃការរៀបចំគ្រោងដំណាក់កាលមុនពេលជ្រើសរើស ដំណាក់កាលវាយតម្លៃ និងដំណាក់កាលរៀបចំថវិកា។** ជាពិសេសចំពោះគម្រោងវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុកគឺគ្មានការគ្រប់គ្រងវិនិយោគសាធារណៈ ដែលមានលក្ខណៈស្តង់ដារឡើយ។ ការគ្មានស្តង់ដារូបនីយកម្ម និង អវត្តមាននៃគោល

28 ឯកសាររបស់មូលនិធិរូបិយវត្ថុអន្តរជាតិឆ្នាំ 2011 ក្រោមចំណងជើងថាតើមេគុណមានធំហំធំ(តូច)ប៉ុណ្ណា

29 ឧបសគ្គចម្បងៗដែលកម្ពុជាប្រឈមមុខរួមមាន ថ្លៃថាមពល កង្វះខាតហេដ្ឋារចនាសម្ព័ន្ធ និងការរារាំងផ្នែកបទប្បញ្ញត្តិក្នុងការធ្វើអាជីវកម្ម (Doing Business 2016, ធនាគារពិភពលោក).

30 ការវាយតម្លៃរបស់ធនាគារពិភពលោកលើការគ្រប់គ្រងវិនិយោគសាធារណៈរបស់កម្ពុជា ឆ្នាំ 2017

ការណ៍ណែនាំ សៀវភៅណែនាំ និងទម្រង់គំរូឯកភាព រៀបចំនៅថ្នាក់កណ្តាលសម្រាប់ការរៀបចំសំណើគម្រោង និងការវាយតម្លៃគម្រោង និងការតាមដានការអនុវត្ត នាំមកនូវការប្រតិបត្តិខុសគ្នាជាខ្លាំងនៅតាមក្រសួងពាក់ព័ន្ធនានា។ បន្ថែមពីលើនេះ ដោយមុខងារនៃការពិនិត្យមើលឡើងវិញឯករាជ្យ (នៃឯកសារគម្រោង) មិនត្រូវបានរៀបចំជាផ្លូវការនៅឡើយនោះ មុខងារត្រួតពិនិត្យចំពោះការវិភាជន៍ និងការប្រើប្រាស់ថវិកាមូលធន ក៏ពុំទាន់មានវត្តមានដែរ។

**គុណភាពនៃការអនុវត្ត និងការតាមដានថវិកាមូលធនក្នុងដំណាក់កាលអនុវត្តត្រូវបានពិនិត្យឃើញថា មិនគ្រប់គ្រាន់មួយចំណែក គឺមកពីកង្វះគោលការណ៍ណែនាំប្រតិបត្តិការដែលមានលក្ខណៈស្តង់ដារ និងដែលបានរៀបចំនៅថ្នាក់កណ្តាល។** គេអាចឃើញបញ្ហានេះ ក្នុងដំណាក់កាលនានា នៃការអនុវត្តគម្រោង កែតម្រូវគម្រោង ដំណើរការសម្របសម្រួល និងការពិនិត្យតាមក្រោយ។ ខណៈដែលគម្រោងដែលផ្តល់មូលនិធិដោយដៃគូអភិវឌ្ឍន៍ អនុវត្តតាមនីតិវិធីអនុវត្តស្តង់ដារ គេពុំឃើញមានគោលការណ៍ណែនាំដែលមានលក្ខណៈស្តង់ដារសម្រាប់ការវិនិយោគដែលប្រើប្រាស់ថវិការបស់រដ្ឋាភិបាលឡើយ ធ្វើឲ្យស្ថាប័នអនុវត្តៗផ្សេងៗគ្នា។ ក្នុងទិដ្ឋភាពបែបនេះ ពុំមានមធ្យោបាយ ឬឧបករណ៍ណាដែលមានប្រសិទ្ធភាពដើម្បីធានាឲ្យមានការតាមដានឲ្យមានប្រសិទ្ធភាព បញ្ជាក់ថាហិរញ្ញប្បទាននៃវិនិយោគសាធារណៈកំពុងត្រូវបានប្រើប្រាស់ដោយប្រសិទ្ធភាព និងត្រឹមត្រូវឬទេ។ ហេតុនេះ ក្របខណ្ឌលទ្ធកម្មថ្មីចាំបាច់ត្រូវបំពេញដោយបញ្ញត្តិជាក់លាក់ស្តីពីការគ្រប់គ្រងវិនិយោគសាធារណៈ ដើម្បីធានាបានថាកិច្ចការនេះអាចសម្រេចបាននូវគុណតម្លៃចំពោះថវិកាក្នុងគម្រោងមូលធននានា។

### c) វិធានការកែលម្អការគ្រប់គ្រងវិនិយោគសាធារណៈ

**ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះតទៅមុខ អនុសាសន៍ទូទៅនិងគ្រប់ជ្រុងជ្រោយ គួរតែមានកំណែទម្រង់ដែលមានលក្ខណៈជាយុទ្ធសាស្ត្រ។** អនុសាសន៍ទាំងនោះ រួមមានការអភិវឌ្ឍស្ថាប័ន និងនីតិវិធីបំពេញបន្ថែមដោយសកម្មភាពកំណែទម្រង់អាទិភាព ពីរយៈពេលខ្លីទៅមធ្យមនៅគ្រប់ដំណាក់កាលនៃការគ្រប់គ្រងការវិនិយោគសាធារណៈ។

a. **មុខងារត្រួតពិនិត្យ។** ការដាក់ឲ្យមានមុខងារត្រួតពិនិត្យជាមួយនឹងមុខងារពិនិត្យឡើងវិញ ដោយឯករាជ្យនៅក្នុងការធ្វើការសម្រេចចិត្តមុនការចាប់ផ្តើមគម្រោង ចំពោះដំណាក់កាលបុរេវាយតម្លៃ វាយតម្លៃ ចាត់អាទិភាពគម្រោង និងរៀបចំថវិកា។

b. **គោលការណ៍ណែនាំដែលមានលក្ខណៈស្តង់ដារ ។** ការបង្កើតគោលការណ៍ណែនាំដែលមានលក្ខណៈស្តង់ដារ និងការត្រួតពិនិត្យចំណាយដែលមានប្រសិទ្ធភាព នៅក្នុងការអនុវត្តគម្រោង។ ជំនួសឲ្យការបង្កើតគោលការណ៍ណែនាំ និងនីតិវិធីគ្រប់គ្រងការគ្រប់គ្រងវិនិយោគសាធារណៈថ្មីស្រឡាងនោះ យុទ្ធសាស្ត្រដែលត្រូវការចាំបាច់គឺការពិនិត្យឡើងវិញ និងការអនុម័តគោលការណ៍សំខាន់ៗនៃនីតិវិធីប្រតិបត្តិស្តង់ដារ (SOP) នៅពេលណាដែលអាចអនុវត្តបាន។ ការអនុវត្តគោលការណ៍ណែនាំ និងគោលនយោបាយឯកភាពជាបណ្តើរៗ ចំពោះវិនិយោគសាធារណៈ ដែលផ្តល់ហិរញ្ញប្បទានពីប្រភពក្នុងស្រុក និងពីបរទេស នឹងទ្រទ្រង់កិច្ចប្រឹងប្រែងរបស់អាជ្ញាធរនានា ក្នុងការសម្រេចបាននូវសមាហរណកម្មថវិកា និងទំនាក់ទំនងរវាងគោលនយោបាយ និងថវិកាផងដែរ។

c. **ការបង្កើនសមត្ថភាព។** ការបង្កើនសមត្ថភាពរបស់ក្រសួង និងស្ថាប័ននានាដើម្បីរៀបចំ និងវាយតម្លៃគម្រោងវិនិយោគប្រកបដោយប្រសិទ្ធផល និងប្រសិទ្ធភាព ជាចាំបាច់ត្រូវភ្ជាប់ជាមួយអាទិភាពយុទ្ធសាស្ត្រ នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា និងក្របខណ្ឌចំណាយរយៈពេលមធ្យម ដើម្បីសម្រេចគោលដៅ ឆ្ពោះទៅកាន់ការបង្កើតទំនាក់ទំនងដែលមានប្រសិទ្ធភាពរវាងគោលនយោបាយ ការរៀបចំផែនការ និងការរៀបចំថវិកា។ ក្នុងន័យនេះ ការពង្រឹងបន្ថែមនូវភាពគ្រប់ជ្រុងជ្រោយនៃថវិកា នឹងជួយទ្រទ្រង់ប្រសិទ្ធភាពនៃវិនិយោគសាធារណៈ តាមរយៈការធ្វើសមាហរណកម្មពេញលេញនៃថវិកាដែលផ្តល់ហិរញ្ញប្បទានពីក្នុងស្រុក និងពីបរទេស។

អនុសាសន៍សំខាន់ៗទាំងបី ដូចបានគូសបញ្ជាក់ខាងលើ នឹងឆ្លើយតបនឹងវត្ថុបំណងសំខាន់សម្រាប់កំណែទម្រង់ការគ្រប់គ្រងវិនិយោគសាធារណៈនៅកម្ពុជា តាមរយៈការបង្កើតឲ្យមានការពិនិត្យឡើងវិញដោយឯករាជ្យ ឬមុខងារត្រួតពិនិត្យចម្បងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



# សន្និដ្ឋាន

**ខណៈដែលចំណាយសាធារណៈរបស់កម្ពុជាលើវិស័យសំខាន់ៗក្នុងពេលបច្ចុប្បន្នអាចប្រៀបធៀបគ្នាបានជាមួយបណ្តាប្រទេសក្នុងតំបន់ ការបង្កើនប្រសិទ្ធភាពចំណាយសាធារណៈគឺជាជំហានសំខាន់ក្នុងពេលបន្ទាប់។** បន្ថែមពីលើនេះ កិច្ចប្រឹងប្រែងកាលពីពេលថ្មីៗ ក្នុងការជំរុញចំណាយហិរញ្ញប្បទានក្នុងស្រុកលើវិស័យសំខាន់ៗ ដូចជា វិស័យអប់រំសុខាភិបាល ដឹកជញ្ជូន និងវិស័យកសិកម្មមានទំនោរទៅរកការបង្កើនចំណាយចរន្ត ពិសេសលើបៀវត្សនៃវិស័យសាធារណៈ។ ហេតុនេះ ការងារសំខាន់គឺត្រូវធានាឲ្យមានការវិភាជន៍ថវិកាគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការ និងការថែទាំ។

**ការវិនិយោគលើមូលធនរូបវន្តជាបន្តបន្ទាប់ ដែលក្នុងពេលកន្លងមក ត្រូវបានផ្តល់ហិរញ្ញប្បទានជាចម្បងដោយដៃគូអភិវឌ្ឍន៍ នឹងទ្រទ្រង់ឲ្យប្រទេសកម្ពុជាមានកំណើន ព្រោះការរក្សាភាពប្រកួតប្រជែងតទៅមុខគឺជាតម្រូវការចាំបាច់។** ហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់ គឺជាបញ្ហាចម្បងរបស់កម្ពុជា អស់រយៈពេលជាយូរមកហើយ ហើយត្រូវបានចាត់ទុកជាឧបសគ្គរាំងស្ទះមួយគួរឲ្យកត់សំគាល់។ ខណៈសេដ្ឋកិច្ចមានទំហំតូច និងបើកចំហលទ្ធភាពធ្វើឲ្យមានកំណើនរបស់កម្ពុជា អាស្រ័យលើភាពប្រកួតប្រជែងរបស់ខ្លួន ដែលជួបការលំបាកដោយសារឡើងថ្លៃនៃប្រាក់ឈ្នួល ធាតុចូល ការកើនថ្លៃនៃប្រាក់ដុល្លារអាមេរិក និងបញ្ហាប្រឈមអំពីសមត្ថភាពស្ថាប័ន និងអភិបាលកិច្ច។ កំណែទម្រង់ជាយុទ្ធសាស្ត្រ នៅគ្រប់ដំណាក់កាល នៃការគ្រប់គ្រងវិនិយោគសាធារណៈមានភាពចាំបាច់ ដើម្បីពង្រឹងការធ្វើសេចក្តីសម្រេចចិត្ត មុនការចាប់ផ្តើមនៃគម្រោង ចំពោះការធ្វើបុរេនិច្ឆ័យគម្រោងការវាយតម្លៃគម្រោង ការកំណត់អាទិភាពគម្រោង និងការរៀបចំថវិកា និងការពង្រឹងការធ្វើសេចក្តីសម្រេចចិត្តពេលអនុវត្តគម្រោង ដូចជា ការបង្កើតការអនុវត្ត និងការតាមដានគម្រោង ដែលមានលក្ខណៈស្តង់ដារ អាចតាមរយៈការអនុម័តគោលការណ៍សំខាន់នៃនីតិវិធីប្រតិបត្តិស្តង់ដារនៅពេលដែលអាចអនុវត្តបាន។

**ដើម្បីសម្រេចបានគោលដៅនេះ ចាំបាច់ត្រូវបន្តកសាងសមត្ថភាពដើម្បីអាចរៀបចំ និងវាយតម្លៃគម្រោងវិនិយោគកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល ដាច់ខាតផ្សាភ្ជាប់ជាមួយផែនការយុទ្ធសាស្ត្រថវិកា និងក្របខណ្ឌចំណាយរយៈពេលមធ្យម។** សម្រាប់គម្រោងបែបនេះគេគប្បីធ្វើសមាហរណកម្មថវិកាហិរញ្ញប្បទានពីបរទេស និងពីប្រភពក្នុងស្រុកឲ្យបានពេញលេញ ដើម្បីសម្រេចបាននូវគោលដៅនៃការបង្កើតទំនាក់ទំនងមានប្រសិទ្ធភាពរវាងផ្នែកគោលនយោបាយ ការកសាងផែនការ និងការរៀបចំថវិកា។ ក្នុងករណីគ្មានក្របខណ្ឌចំណាយរយៈពេលមធ្យម គ្មានការបម្រុងទុកធនធានបានគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធ ដែលអាចនាំឲ្យមានចំណាយមូលធនខ្ពស់ក្នុងរយៈពេលវែង ហើយនាំឲ្យវិនិយោគសាធារណៈមានប្រសិទ្ធភាពតិចតួចប៉ុណ្ណោះ[31]។

31 គោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រងចំណាយសាធារណៈដោយ Barry H. Potter និង Kack Diamond នៃមូលនិធិរូបិយវត្ថុអន្តរជាតិ

# F. កម្ពុជា: សូចនាករសំខាន់ៗ

| | 2014 | 2015e | 2016p | 2017f | 2018f | 2019f |
|---|---|---|---|---|---|---|
| ផលិតផលតម្រូវការក្នុងស្រុក និងថ្លៃ | | | | | | |
| ផសស ពិត (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 7.1 | 7.0 | 6.9 | 6.9 | 6.9 | 6.7 |
| តម្រូវការក្នុងស្រុក (%ប្រែប្រួលធៀបនឹងឆ្នាំមុន) | 10.1 | 8.5 | 9.5 | 10.3 | 10.2 | 10.7 |
| សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (%ប្រែប្រួលចុងគ្រាធៀបនឹងឆ្នាំមុន | 1.7 | 1.3 | 3.5 | 3.7 | 4.2 | 5.2 |
| វិស័យសាធារណៈ (%នៃផសស) | | | | | | |
| ចំណូលក្នុងស្រុករបស់រដ្ឋាភិបាល | 17.7 | 18.7 | 18.4 | 18.2 | 17.7 | 17.1 |
| ចំណាយក្នុងស្រុករបស់រដ្ឋាភិបាល | 21.6 | 20.5 | 21.4 | 23.3 | 22.5 | 21.6 |
| តុល្យការសារពើពន្ធសរុប មិនគិតជំនួយឥតសំណង | -4.2 | -1.8 | -3.0 | -5.1 | -4.8 | -4.5 |
| តុល្យការសារពើពន្ធសរុប រួមទាំងជំនួយឥតសំណង | -1.8 | 0.0 | -1.4 | -3.5 | -3.4 | -3.3 |
| ពាណិជ្ជកម្មបរទេស ជញ្ជីងទូទាត់ និងបំណុលបរទេស | | | | | | |
| ជញ្ជីងពាណិជ្ជកម្ម (លានដុល្លារអាមេរិក) | -2,023.6 | -2,261.8 | -2,276.0 | -2,451.1 | -2,570.7 | -2,690.1 |
| នាំចេញទំនិញ (លានដុល្លារអាមេរិក) | 7,636.0 | 8,280.2 | 9,115.2 | 10,044.2 | 10,994.9 | 12,026.7 |
| (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 10.9 | 8.4 | 10.1 | 10.2 | 9.5 | 9.4 |
| ការនាំចេញសំខាន់ៗ (% ប្រែប្រួលធៀបនឹងឆ្នាំមុន)1/ | 11.7 | 14.5 | 12.0 | 11.5 | 10.8 | 10.8 |
| ការនាំចូលទំនិញ (លានដុល្លារអាមេរិក) | 9,659.6 | 10,542.0 | 11,391.2 | 12,495.2 | 13,565.6 | 14,716.9 |
| (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 8.7 | 9.1 | 8.1 | 9.7 | 8.6 | 8.5 |
| សមតុល្យគណនីចរន្ត (លានដុល្លារអាមេរិក) 2/ | -1,630.5 | -1,925.0 | -1,911.4 | -2,036.1 | -2,204.8 | -2,470.6 |
| (% GDP) | -9.7 | -10.6 | -9.5 | -9.2 | -8.9 | -8.9 |
| វិនិយោគផ្ទាល់ពីបរទេស (លានដុល្លារអាមេរិក) | 1,679.9 | 1,668.8 | 2,036.0 | 2,078.3 | 1,904.2 | 1,795.0 |
| បំណុលបរទេស (លានដុល្លារអាមេរិក) | 5,555.4 | 5,860.9 | 6,578.1 | 7,426.9 | 8,338.3 | 9,295.2 |
| (% នៃផសស) | 33.0 | 32.1 | 32.9 | 33.5 | 33.8 | 33.6 |
| អនុបាតសេវាបំណុល (% ការនាំចេញទំនិញនិងសេវា) | 1.2 | 1.5 | 1.6 | 1.9 | 2.1 | 2.3 |
| ទុនបំរុងជារូបិយបណ្ណបរទេសដុល(លានដុល្លារអាមេរិក) | 4,657.9 | 5,672.1 | 6,457.0 | 6,980.8 | 7,407.7 | 7,810.9 |
| (ចំនួនខែនៃការនាំចូលទំនិញនិងសេវា) | -4.6 | -5.2 | -5.4 | -5.4 | -5.3 | -5.1 |
| ទីផ្សារហិរញ្ញវត្ថុ | | | | | | |
| ឥណទានក្នុងស្រុក (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 28.4 | 28.6 | 25.8 | 23.2 | 21.5 | 20.2 |
| អត្រាការប្រាក់រយៈពេលខ្លី (%ក្នុងមួយឆ្នាំ) | 11.5 | 11.6 | 11.8 | 11.8 | 11.9 | 11.9 |
| អត្រាប្តូរប្រាក់(រៀល/ដុល្លារអាមេរិក មធ្យមភាគប្រចាំឆ្នាំ) | 4,030.0 | 4,025.0 | 4,058.0 | 4,062.0 | 4,067.0 | 4,075.0 |
| ចំណាំ: ផសស ណូមីណាល់ (លានដុល្លារអាមេរិក) | 16,809 | 18,241.7 | 20,020.2 | 22,157.7 | 24,663.3 | 27,623.3 |

ប្រភព: អាជ្ញាធរកម្ពុជា ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ
សំគាល់: e = ប៉ាន់ស្មាន; f = ព្យាករណ៍; p = ចំណោល
1/ ការនាំចេញសម្លៀកបំពាក់និងស្បែកជើង
2/ មិនគិតបង្វែរផ្លូវការ

ក្រុមធនាគារពិភពលោក

ធនាគារពិភពលោក
ការិយាល័យប្រចាំកម្ពុជា
អគារ Exchange Square
ជាន់ទី 10 IBRD និងទី 11 IFC
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
ភ្នំពេញ កម្ពុជា
គេហទំព័រ: www.worldbank.org/cambodia